# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## បញ្ចកនិបាត

## ភាគ ៤៥

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

បញ្ចកនិបាត មាន ៣ បណ្ណាសកៈ

ចែកជា ១៥ វគ្គ និងសូត្រមិនសង្គ្រោះក្នុងវគ្គ មាន ១៦៦ សូត្រ

ព្រះអដ្ឋកថាកែសេចក្តី ១១៤ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

# មនោរថបូរណី

## បញ្ចកនិបាត

## ភាគ ៤៥

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

បញ្ចកនិបាត មាន ៣ បណ្ណាសកៈ

ចែកជា ១៥ វគ្គ និងសូត្រមិនសង្គ្រោះក្នុងវគ្គ មាន ១៦៦ សូត្រ

ព្រះអដ្ឋកថាកែសេចក្តី ១១៤ សូត្រ

# អង្គុត្តរនិកាយ បញ្ចកនិបាត
## រួមមាន
## ៣ បណ្ណាសកៈ និង ១៥ វគ្គ និងសូត្រមិនសង្គ្រោះក្នុងវគ្គ
## ព្រះអដ្ឋកថាកែសេចក្តី ១១៤ សូត្រ

### តតិយបណ្ណាសកៈ

| | | | |
|---|---|---|---|
| ១ ផាសុវិហារវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៩ សូត្រ |
| ២ អន្ធកវិន្ទវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៧ សូត្រ |
| ៣ គិលានវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៧ សូត្រ |
| ៤ រាជវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |
| ៥ តិកណ្ឌកីវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៨ សូត្រ |

### ចតុត្ថបណ្ណាសកៈ

| | | | |
|---|---|---|---|
| ១ សទ្ធម្មវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៨ សូត្រ |
| ២ អាឃាតវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៦ សូត្រ |
| ៣ ឧបាសកវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ១០ សូត្រ |
| ៤ អរញ្ញវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០១ សូត្រ |
| ៥ ព្រាហ្មណវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៨ សូត្រ |

### បញ្ចមបណ្ណាសកៈ

| | | | |
|---|---|---|---|
| ១ កិមិលវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៩ សូត្រ |
| ២ អក្កោសកវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៥ សូត្រ |
| ៣ ទីឃចារិកវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៨ សូត្រ |
| ៤ អាវាសិកវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៤ សូត្រ |
| ៥ ទុច្ចរិតវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី | ០៧ សូត្រ |

**សូត្រមិនសង្គ្រោះក្នុងវគ្គ** អដ្ឋកថាកែសេចក្តី ០៧ សូត្រ

# ស្រៈនិស្ស័យ

# *Signes et accents:*



# ស្រៈពេញតួ

# Voyelles:

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រ៉ូម Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | ไอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໄອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
# *Consonnes.*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| ឡូប<br>Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម<br>Siamois | ก | ข | ค | ฆ | ง |
| លាវ<br>Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា<br>Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា<br>Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| ឡូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| [illegible]<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | [illegible] | [illegible] | [illegible] | [illegible] | [illegible] |
| សង្ហល<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

## ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

**ឥតិវុត្តក** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភូតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

**វេទល្ល** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដី

រីករាយ និងស្នួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានធនុះក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្អក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ភាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្ពាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដា អាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើង ហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែក ចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះ របស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បី ជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍- សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធ-គយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិ-សម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថាពុទ្ធមន្ត ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនាបានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្ដើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុជៈ ) ខ្វះ ( សិរិកូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ ព្រះសង្ឃលង្កាទទួលស្ដាប់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណានីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់ លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធា-នឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋ-កថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

*លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។*

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស
លោកគ្រូធម្មបណ្ឌិត រស់ សុជាត
លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ន ឧបាសក ណាក់ម៉ៅ
ឧបាសក ឌុំ ធួន ឧបាសក ហុក សីងហួត
ឧបាសក ជីម ជំនិត ឧបាសក កើត ធិត្យ
ឧបាសក សន ម៉ារឌី ឧបាសក ហាយ ចំរើន
ឧបាសក អ៊ុម រ៉ៃយ៉ា ឧបាសក សុក្រ ហ៊ត
ឧបាសក សោម រតនៈ ឧបាសក សំ ណាយ
ឧបាសក ម៉ៅ ដុន ឧបាសក ជា ស៊ុថាន
ឧបាសិកា ជាប់ លឿម ឧបាសិកា ហាយ សារ៉ាត់
ឧបាសិកា ប៊ុត សុម៉ាលី ឧបាសិកា យស សម្បត្តិ
ឧបាសិកា ពូ ហ៊ាង ឧបាសិកា ប៊ុត សេដាដួង
ឧបាសិកា ប៉ែន រមណី

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គធិរ្ទោ | នូវ ប៉ូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ជុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ដុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុតេជធរោ | ធាវ ធាន | ធម្មាចារ្យ |

សាមណេរ កោវិទោ ឡោះស្វៀត សមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជីម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់៥.០០០ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ–

ឧទ្ទិសថ្វាយ និងគោរពជូនៈ

–ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

–ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

–សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

–មាតាបិតានៃយើងទាំងអស់គ្នា

–លោកគ្រូអគ្គបណ្ឌិតធម្មចារ្យ ប៊ុត សាវង្ស

–លោកគ្រូធម្មបណ្ឌិត រស់ សុជាត

–សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

–សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | | ទំព័រ |
|---|---|---|
| **បញ្ចកនិបាត តតិយបណ្ណាសកៈ** | | |
| **ផាសុវិហារវគ្គ ទី ១** | | |
| អដ្ឋកថា សារជ្ជសូត្រ | ទី ១ | ១ |
| អដ្ឋកថា សង្កិតសូត្រ | ទី ២ | ២ |
| អដ្ឋកថា ចោរសូត្រ | ទី ៣ | ៤ |
| អដ្ឋកថា សុខមាលសូត្រ | ទី ៤ មិនមានអដ្ឋកថា | ៥ |
| អដ្ឋកថា ផាសុវិហារសូត្រ | ទី ៥ | ៦ |
| អដ្ឋកថា អានន្ទសូត្រ | ទី ៦ | ៨ |
| អដ្ឋកថា សីលសូត្រ | ទី ៧ | ១០ |
| អដ្ឋកថា អសេក្ខិយសូត្រ | ទី ៨ | ១១ |
| អដ្ឋកថា ចាតុទិសសូត្រ | ទី ៩ | ១២ |
| អដ្ឋកថា អរញ្ញសូត្រ | ទី ១០ | ១៣ |
| **អន្ធកវិន្ទវគ្គ ទី ២** | | |
| អដ្ឋកថា កុលូបកសូត្រ | ទី ១ | ១៤ |
| អដ្ឋកថា បច្ឆាសមណសូត្រ | ទី ២ | ១៥ |
| អដ្ឋកថា សមាធិសូត្រ | ទី ៣ | ១៦ |
| អដ្ឋកថា អន្ធកាវិន្ទសូត្រ | ទី ៤ | ១៧ |
| អដ្ឋកថា មច្ឆរិយសូត្រ | ទី ៥ | ១៨ |
| អដ្ឋកថា វណ្ណនាសូត្រ | ទី ៦ | ១៩ |
| អដ្ឋកថា ឥស្សាសូត្រ | ទី ៧ | ២០ |
| អដ្ឋកថា ទិដ្ឋិសូត្រ | ទី ៨ មិនមានអដ្ឋកថា | ២១ |
| អដ្ឋកថា វាចាសូត្រ | ទី៩ មិនមានអដ្ឋកថា | ២២ |
| អដ្ឋកថា វាយាមសូត្រ | ទី ១០ មិនមានអដ្ឋកថា | ២៣ |

## គិលានវគ្គ ទី ៣


| | | |
|---|---|---|
| អដ្ឋកថា គិលានសូត្រ | ទី ១ | ២៤ |
| អដ្ឋកថា សតិប្បដ្ឋានសូត្រ | ទី ២ មិនមានអដ្ឋកថា | ២៥ |
| អដ្ឋកថា បឋមឧបដ្ឋាកសូត្រ | ទី ៣ មិនមានអដ្ឋកថា | ២៦ |
| អដ្ឋកថា ទុតិយឧបដ្ឋាកសូត្រ | ទី ៤ | ២៧ |
| អដ្ឋកថា បឋមអនាយុស្សសូត្រ | ទី ៥ | ២៨ |
| អដ្ឋកថា ទុតិយអនាយុស្សសូត្រ | ទី ៦ | ២៩ |
| អដ្ឋកថា អវប្បកាសសូត្រ | ទី ៧ | ៣០ |
| អដ្ឋកថា សមណទុក្ខសូត្រ | ទី ៨ មិនមានអដ្ឋកថា | ៣១ |
| អដ្ឋកថា បរិកុប្បសូត្រ | ទី ៩ | ៣២ |
| អដ្ឋកថា សម្បទាសូត្រ | ទី ១០ | ៣៣ |


## រាជវគ្គ ទី ៤


| | | |
|---|---|---|
| អដ្ឋកថា ចក្កសូត្រ | ទី ១ | ៣៤ |
| អដ្ឋកថា អនុវត្តនសូត្រ | ទី ២ | ៣៦ |
| អដ្ឋកថា រាជសូត្រ | ទី ៣ | ៣៧ |
| អដ្ឋកថា យស្សទិសសូត្រ | ទី ៤ | ៣៨ |
| អដ្ឋកថា បឋមបត្ថនាសូត្រ | ទី ៥ | ៤៣ |
| អដ្ឋកថា ទុតិយបត្ថនាសូត្រ | ទី ៦ | ៤៤ |
| អដ្ឋកថា អប្បសុបតិសូត្រ | ទី ៧ | ៤៥ |
| អដ្ឋកថា ភត្តាទកសូត្រ | ទី ៨ | ៤៦ |
| អដ្ឋកថា អក្ខមសូត្រ | ទី ៩ | ៤៧ |
| អដ្ឋកថា សោតរសូត្រ | ទី ១០ | ៤៨ |


## តិកណ្ឌកីវគ្គ ទី ៥


| | | |
|---|---|---|
| អដ្ឋកថា ទត្វាអវជានាតិសូត្រ | ទី ១ | ៥០ |
| អដ្ឋកថា អារភតិសូត្រ | ទី ២ | ៥៣ |
| អដ្ឋកថា សារន្ទទសូត្រ | ទី ៣ | ៥៦ |
| អដ្ឋកថា តិកណ្ឌកីសូត្រ | ទី ៤ | ៥៧ |
| អដ្ឋកថា និរយសូត្រ | ទី ៥ មិនមានអដ្ឋកថា | ៥៩ |

| | | | |
|---|---|---|---|
| អដ្ឋកថា មិត្តសូត្រ | ទី ៦ | | ៦០ |
| អដ្ឋកថា អសប្បុរិសទានសូត្រ | ទី ៧ | | ៦១ |
| អដ្ឋកថា សប្បុរិសទានសូត្រ | ទី ៨ | | ៦៣ |
| អដ្ឋកថា បឋមសមយវិមុត្តសូត្រ | ទី ៩ | | ៦៤ |
| អដ្ឋកថា ទុតិយសមយវិមុត្តសូត្រ | ទី ១០ | មិនមានអដ្ឋកថា | ៦៥ |

## ចតុត្ថបណ្ណាសកៈ

### សទ្ធម្មវគ្គ ទី ១

| | | | |
|---|---|---|---|
| អដ្ឋកថា បឋមសទ្ធម្មនិយាមសូត្រ | ទី ១ | | ៦៦ |
| អដ្ឋកថា ទុតិយ.......សូត្រ | ទី ២ | | ៦៨ |
| អដ្ឋកថា តតិយ.......សូត្រ | ទី ៣ | | ៦៩ |
| អដ្ឋកថា បឋមសទ្ធម្មសម្មោសសូត្រ | ទី ៤ | | ៧០ |
| អដ្ឋកថា ទុតិយ.......សូត្រ | ទី ៥ | មិនមានអដ្ឋកថា | ៧១ |
| អដ្ឋកថា តតិយ.......សូត្រ | ទី ៦ | | ៧២ |
| អដ្ឋកថា ទុក្កថាសូត្រ | ទី ៧ | | ៧៣ |
| អដ្ឋកថា សារជ្ជសូត្រ | ទី ៨ | មិនមានអដ្ឋកថា | ៧៤ |
| អដ្ឋកថា ឧទាយិសូត្រ | ទី ៩ | | ៧៥ |
| អដ្ឋកថា ទុប្បដិវិនោទយសូត្រ | ទី ១០ | | ៧៧ |

### អាឃាតវគ្គ ទី ២

| | | | |
|---|---|---|---|
| អដ្ឋកថា បឋមអាឃាតវិនយសូត្រ | ទី ១ | | ៧៨ |
| អដ្ឋកថា ទុតិយ.......សូត្រ | ទី ២ | | ៨០ |
| អដ្ឋកថា សាកច្ឆាសូត្រ | ទី ៣ | មិនមានអដ្ឋកថា | ៨៦ |
| អដ្ឋកថា សាជីវសូត្រ | ទី ៤ | មិនមានអដ្ឋកថា | ៨៧ |
| អដ្ឋកថា បញ្ហាបុច្ឆាសូត្រ | ទី ៥ | | ៨៨ |
| អដ្ឋកថា និរោធសូត្រ | ទី ៦ | | ៨៩ |
| អដ្ឋកថា ចោទនាសូត្រ | ទី ៧ | | ៩៣ |
| អដ្ឋកថា សីលសូត្រ | ទី ៨ | មិនមានអដ្ឋកថា | ៩៥ |

| | | |
|---|---|---|
| អដ្ឋកថា និសន្តិសូត្រ | ទី ៩ | ៩៦ |
| អដ្ឋកថា ភទ្ទជិសូត្រ | ទី ១០ មិនមានអដ្ឋកថា | ៩៩ |

**ឧបាសកវគ្គ ទី ៣**

| | | |
|---|---|---|
| អដ្ឋកថា សារជ្ជសូត្រ | ទី ១ | ១០២ |
| អដ្ឋកថា វិសារទសូត្រ | ទី ២ | ១០៣ |
| អដ្ឋកថា និរយសូត្រ | ទី ៣ | ១០៤ |
| អដ្ឋកថា វេរសូត្រ | ទី ៤ | ១០៥ |
| អដ្ឋកថា ចណ្ឌាលសូត្រ | ទី ៥ | ១០៦ |
| អដ្ឋកថា បីតិសូត្រ | ទី ៦ | ១០៧ |
| អដ្ឋកថា វណិជ្ជសូត្រ | ទី ៧ | ១០៩ |
| អដ្ឋកថា រាជសូត្រ | ទី ៨ | ១១០ |
| អដ្ឋកថា គិហិសូត្រ | ទី ៩ | ១១១ |
| អដ្ឋកថា ភវេសិសូត្រ | ទី ១០ | ១១៣ |

**អរញ្ញវគ្គ ទី ៤**

| | | |
|---|---|---|
| អដ្ឋកថា អរញ្ញកសូត្រ | ទី ១ | ១១៧ |
| អដ្ឋកថា បង្សុកូលិកសូត្រ | ទី ២ មិនមានអដ្ឋកថា | ១១៩ |
| អដ្ឋកថា រុក្ខមូលិកសូត្រ | ទី ៣ មិនមានអដ្ឋកថា | ១២០ |
| អដ្ឋកថា សោសានិកសូត្រ | ទី ៤ មិនមានអដ្ឋកថា | ១២១ |
| អដ្ឋកថា អព្ភោកាសិកសូត្រ | ទី ៥ មិនមានអដ្ឋកថា | ១២២ |
| អដ្ឋកថា នេសជ្ជិកសូត្រ | ទី ៦ មិនមានអដ្ឋកថា | ១២៣ |
| អដ្ឋកថា យថាសន្ថតិកសូត្រ | ទី ៧ មិនមានអដ្ឋកថា | ១២៤ |
| អដ្ឋកថា ឯកាសនិកសូត្រ | ទី ៨ មិនមានអដ្ឋកថា | ១២៥ |
| អដ្ឋកថា ខលុបច្ឆាភត្តិកសូត្រ | ទី ៩ មិនមានអដ្ឋកថា | ១២៦ |
| អដ្ឋកថា បត្តបិណ្ឌិកសូត្រ | ទី ១០ មិនមានអដ្ឋកថា | ១២៧ |

**ព្រាហ្មណវគ្គ ទី ៥**

| | | |
|---|---|---|
| អដ្ឋកថា សោណសូត្រ | ទី ១ | ១២៨ |
| អដ្ឋកថា ទោណសូត្រ | ទី ២ | ១៣០ |

| | | |
|---|---|---|
| អដ្ឋកថា សង្គារវសូត្រ | ទី ៣ | ១៣៦ |
| អដ្ឋកថា ការណបាលីសូត្រ | ទី ៤ | ១៤០ |
| អដ្ឋកថា បិង្គិយានីសូត្រ | ទី ៥ | ១៤៥ |
| អដ្ឋកថា សុបិនសូត្រ | ទី ៦ | ១៥១ |
| អដ្ឋកថា វស្សសូត្រ | ទី ៧ | ១៦១ |
| អដ្ឋកថា វាចាសូត្រ | ទី ៨ មិនមានអដ្ឋកថា | ១៦៣ |
| អដ្ឋកថា កុលសូត្រ | ទី ៩ មិនមានអដ្ឋកថា | ១៦៤ |
| អដ្ឋកថា និស្សារណិយសូត្រ | ទី ១០ | ១៦៥ |


## បញ្ចមបណ្ណាសកៈ

### កិមិលវគ្គ ទី ១


| | | |
|---|---|---|
| អដ្ឋកថា កិមិលសូត្រ | ទី ១ | ១៧០ |
| អដ្ឋកថា ធម្មស្សវនសូត្រ | ទី ២ មិនមានអដ្ឋកថា | ១៧៣ |
| អដ្ឋកថា អាជានិយសូត្រ | ទី ៣ | ១៧៤ |
| អដ្ឋកថា ពលសូត្រ | ទី ៤ | ១៧៥ |
| អដ្ឋកថា ចេតោខិលសូត្រ | ទី ៥ | ១៧៦ |
| អដ្ឋកថា វិនិពន្ធសូត្រ | ទី ៦ | ១៧៩ |
| អដ្ឋកថា យាគុសូត្រ | ទី ៧ | ១៨១ |
| អដ្ឋកថា ទន្តកដ្ឋសូត្រ | ទី ៨ | ១៨២ |
| អដ្ឋកថា គីតសូត្រ | ទី ៩ | ១៨៣ |
| អដ្ឋកថា មុដ្ឋស្សតិសូត្រ | ទី ១០ | ១៨៤ |


### អក្កោសកវគ្គ ទី ២


| | | |
|---|---|---|
| អដ្ឋកថា អក្កោសកសូត្រ | ទី ១ | ១៨៥ |
| អដ្ឋកថា ភណ្ឌនសូត្រ | ទី ២ មិនមានអដ្ឋកថា | ១៨៦ |
| អដ្ឋកថា សីលសូត្រ | ទី ៣ | ១៨៧ |
| អដ្ឋកថា ពហុភាណិសូត្រ | ទី ៤ មិនមានអដ្ឋកថា | ១៩០ |
| អដ្ឋកថា បឋមអក្ខន្តិសូត្រ | ទី ៥ | ១៩១ |

អដ្ឋកថា ទុតិយអក្ខន្តិសូត្រ ទី ៦ ១៩២
អដ្ឋកថា បឋមអចាសាទិកសូត្រ ទី ៧ ១៩៣
អដ្ឋកថា ទុតិយអចាសាទិកសូត្រ ទី ៨ មិនមានអដ្ឋកថា ១៩៤
អដ្ឋកថា អគ្គិសូត្រ ទី ៩ មិនមានអដ្ឋកថា ១៩៥
អដ្ឋកថា មធុរាសូត្រ ទី ១០ មិនមានអដ្ឋកថា ១៩៦

## ទីឃចារិកវគ្គ ទី ៣

អដ្ឋកថា បឋមទីឃចារិកសូត្រ ទី ១ ១៩៨
អដ្ឋកថា ទុតិយទីឃចារិកសូត្រ ទី ២ មិនមានអដ្ឋកថា ១៩៩
អដ្ឋកថា អតិនិវាសសូត្រ ទី ៣ ២០០
អដ្ឋកថា មច្ឆរសូត្រ ទី ៤ ២០១
អដ្ឋកថា បឋមកុលុបកសូត្រ ទី ៥ ២០២
អដ្ឋកថា ទុតិយកុលុបកសូត្រ ទី ៦ ២០៣
អដ្ឋកថា ភោគសូត្រ ទី ៧ មិនមានអដ្ឋកថា ២០៤
អដ្ឋកថា ភត្តសូត្រ ទី ៨ ២០៥
អដ្ឋកថា បឋមសប្បសូត្រ ទី ៩ ២០៧
អដ្ឋកថា ទុតិយសប្បសូត្រ ទី ១០ ២០៨

## អាវាសិកវគ្គ ទី ៤

អដ្ឋកថា អាវាសិកសូត្រ ទី ១ ២០៩
អដ្ឋកថា បិយសូត្រ ទី ២ មិនមានអដ្ឋកថា ២១០
អដ្ឋកថា សោភណសូត្រ ទី ៣ ២១១
អដ្ឋកថា ពហុបការសូត្រ ទី ៤ មិនមានអដ្ឋកថា ២១២
អដ្ឋកថា អនុកម្បកសូត្រ ទី ៥ ២១៣
អដ្ឋកថា យថាភតអវណ្ណសូត្រ ទី ៦ មិនមានអដ្ឋកថា ២១៤
អដ្ឋកថា យថាភតគេធសូត្រ ទី ៧ ២១៥
អដ្ឋកថា បឋមភតមច្ឆេរសូត្រ ទី ៨ មិនមានអដ្ឋកថា ២១៦
អដ្ឋកថា ទុតិយភតមច្ឆេរសូត្រ ទី ៩ មិនមានអដ្ឋកថា ២១៧
អដ្ឋកថា តតិយភតមច្ឆេរសូត្រ ទី ១០ មិនមានអដ្ឋកថា ២១៨

**ទុច្ចរិតវគ្គ ទី ៥**


| | | |
|---|---|---|
| អដ្ឋកថា ទុច្ចរិសូត្រ | ទី ១ អដ្ឋកាថាក្រៃម | ២១៩ |
| អដ្ឋកថា កាយទុច្ចរិតសូត្រ | ទី ២ ពីសូត្រទី១ ដល់ទី៥ | |
| អដ្ឋកថា វចីទុច្ចរិតសូត្រ | ទី ៣ | |
| អដ្ឋកថា មនោទុច្ចរិតសូត្រ | ទី ៤ | |
| អដ្ឋកថា អបរទុច្ចរិតសូត្រ | ទី ៥ | |
| អដ្ឋកថា អបរកាយទុច្ចរិតសូត្រ | ទី ៦ មិនមានអដ្ឋកថា | ២២០ |
| អដ្ឋកថា អបរវចីទុច្ចរិតសូត្រ | ទី ៧ មិនមានអដ្ឋកថា | ២២១ |
| អដ្ឋកថា អបរមនោទុច្ចរិតសូត្រ | ទី ៨ មិនមានអដ្ឋកថា | ២២២ |
| អដ្ឋកថា សីវថិកាសូត្រ | ទី ៩ | ២២៣ |
| អដ្ឋកថា បុគ្គលប្បសាទសូត្រ | ទី ១០ | ២២៤ |
| **វគ្គាសង្គហិតសុត្តន្តះ** | មាន ១៦ សូត្រ អដ្ឋកថាកែសេចក្តី ចំនួន ០៧ សូត្រ ។ | ២២៥ |

# អង្គុត្តរនិកាយ បញ្ចកនិបាត

# តតិយបណ្ណាសកៈ

## ផាសុវិហារវគ្គវណ្ណនាទី ១

### អដ្ឋកថា សារជ្ជសូត្រទី ១

*"ធម៌ធ្វើឲ្យក្លៀវក្លា ៥ ប្រការ"*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សារជ្ជសូត្រទី ១ ដូចតទៅនេះ ៖*

[១] *បទថា **វេសារជ្ជករណា** (ជាគ្រឿងធ្វើឲ្យក្លៀវក្លា) បានដល់ ជាគ្រឿងនាំមកនូវសេចក្តីក្លៀវក្លា ។ បទថា **សារជ្ជំ ហោតិ** (មានសេចក្តីអៀនអន់) បានដល់ រមែងមានទោមនស្ស ។*

ចប់អដ្ឋកថា សារជ្ជសូត្រទី ១

# អដ្ឋកថា សង្កិតសូត្រទី ២

## “ធម៌ធ្វើឲ្យគួររង្កៀស”

*គប្បីជ្រាបវិនិច្ឆ័យក្នុង សង្កិតសូត្រទី ២ ដូចតទៅនេះ ៖*

*[២] បទថា* ***ឧស្សង្កិតបរិសង្កិតោ*** *(ក៏រមែងត្រូវគេរង្កៀសសង្ស័យ) បានដល់ ត្រូវរង្កៀស និងត្រូវសង្ស័យ ។ បទថា* ***អបិ អកុប្បធម្មោ*** *(ថាជាភិក្ខុអាក្រក់ដែរ) សេចក្តីថា នឹងជាព្រះខីណាស្រពអ្នកមានធម៌មិនកម្រើកក៏ពិត រមែងនឹងត្រូវពួកភិក្ខុអាក្រក់ដទៃរង្កៀសសង្ស័យបាន ។*

*បទថា* ***វេសិយគោចរោ*** *(ជាអ្នកត្រាច់ទៅកាន់សម្នាក់ស្រីពេស្យា) ជាដើម អធិប្បាយថា ពួកស្រីដែលអាស្រ័យរូបរាងចិញ្ចឹមជីវិត ហៅថា* ***វេ-សិយា*** *(ស្រីពេស្យា) ស្រីទាំងនោះជាគោចររបស់ភិក្ខុនោះ ព្រោះហេតុនោះទើបឈ្មោះថា មានស្រីពេស្យាជាគោចរ គឺ ទៅផ្ទះរបស់ស្រីទាំងនោះរឿយៗ ។ ក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។*

*ក៏បណ្តាបទទាំងនោះ បទថា* ***វិធវា*** *(ស្រីមេម៉ាយ) បានដល់ ស្រីដែលប្តីស្លាប់ ។ បទថា* ***ថុល្លកុមារី*** *(ស្រីក្រមុំចាស់) បានដល់ ស្រី*

ចាស់ ។

ចប់អដ្ឋកថា សង្ខិត្តសូត្រទី ២

# អដ្ឋកថា ចោរសូត្រទី ៣

## (អង្គរបស់មហាចោរ ៥ យ៉ាង)

គប្បីជ្រាបវិនិច្ឆ័យក្នុង ចោរសូត្រទី ៣ ដូចតទៅនេះ ៖

[៣] បទថា *ឥតោ ភោគេន បដិសន្ថរិស្សាមិ (នឹងយកភោគអំពីទ្រព្យនេះទៅស្តូក)* សេចក្តីថា យើងនឹងកាន់យកភោគៈអំពីសម្បត្តិរបស់យើងនេះ ធ្វើបដិសណ្ឋារៈបិទបាំងដោយភោគៈនោះ អធិប្បាយថា នឹងបិទបាំងសេចក្តីក្លាំងក្លាត់រវាងគេនិងយើង ។ បទថា *និគ្គហណានិ (តែងធ្វើការសង្កត់សង្កិន)* បានដល់ ការកាន់យកវត្ថុរបស់របរអ្នកដទៃ ។ បទថា *គុយ្ហមន្តា (អាថ៌កំបាំង)* បានដល់ មន្តដែលត្រូវបិទបាំង ។ បទថា *អន្តគ្គាហិកាយ (ប្រកបដោយអន្តគ្គាហិកាទិដ្ឋិ)* បានដល់ ទិដ្ឋិដែលប្រកាន់មាំ គឺ សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ បទដ៏សេសក្នុងសូត្រនេះ មានសេចក្តីងាយទាំងអស់ ។

ចប់អដ្ឋកថា ចោរសូត្រទី ៣

# អដ្ឋកថា សុខុមាលសូត្រទី ៤

*(ធម៌របស់សមណៈអ្នកល្អិតល្អន់)*

[៤] *សុខុមាលសូត្រគ្រប់បទ មានន័យដូចដែលពោលហើយខាងក្រោយនោះឯង ។*

ចប់អដ្ឋកថា សុខុមាលសូត្រទី ៤

# អដ្ឋកថា ផាសុវិហារសូត្រទី ៥

## (ធម៌ជាគ្រឿងនៅជាសុខ ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង ផាសុវិហារសូត្រទី ៥ ដូចតទៅនេះ ៖

[៥] បទថា **មេត្តំ កាយកម្មំ** (តាំងទុកនូវកាយកម្មប្រកបដោយមេត្តា) បានដល់ កាយកម្មដែលប្រព្រឹត្តទៅដោយចិត្តប្រកបដោយមេត្តា ។ បទថា **អាវិ ចេវ រហោ ច** (ក្នុងទីចំពោះមុខ និងទីកំបាំងមុខ) បានដល់ ទាំងក្នុងទីចំពោះមុខ និងក្នុងទីកំបាំងមុខ ។ សូម្បីក្នុងបទក្រៅពីនេះ ក៏ន័យនេះឯង ។

បទថា **យានិ តានិ សីលានិ** (ជាភិក្ខុប្រកបដោយសីលស្មើគ្នា) ជាដើម ត្រាស់ដោយចតុប្បារិសុទ្ធិសីល ។ បទថា **សមាធិសំវត្តនិកានិ** (ប្រព្រឹត្តទៅដើម្បីសមាធិ) បានដល់ ដែលធ្វើឲ្យមគ្គសមាធិ និងផលសមាធិកើតឡើង ។ បទថា **សីលសាមញ្ញគតោ** (ដោយសីលស្មើគ្នា) បានដល់ ដល់ភាពជាអ្នកមានសីលស្មើគ្នា អធិប្បាយថា ជាអ្នកមានសីលដូចគ្នា ។ បទថា **តក្ករស្ស** (នាំជនឲ្យធ្វើតាម) បានដល់ អ្នកធ្វើតាមការឃើញនោះ ។

ក្នុងព្រះសូត្រនេះ ព្រះដ៏មានព្រះភាគត្រាស់ការមានសីលស្មើគ្នា ត្រាស់ទិដ្ឋិ គឺ សម្មាទិដ្ឋិក្នុងវិបស្សនា ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា ផាសុវិហារសូត្រទី ៥

# អដ្ឋកថា អានន្ទសូត្រទី ៦

## (ធម៌ជាហេតុឲ្យសង្ឃនៅជាសុខ)

គប្បីជ្រាបវិនិច្ឆ័យក្នុង អានន្ទសូត្រទី ៦ ដូចតទៅនេះ ៖

[៦] បទថា **នោ បរំ អធិសីលេ សម្បវត្តា ហោតិ (មិនតិះដៀលភិក្ខុដទៃ ព្រោះតែអធិសីល)** សេចក្តីថា មិនតិះដៀល មិនពោលប្រទូស្តអ្នកដទៃ (ព្រោះសីលរបស់ខ្លួន) ដល់រឿងសីល ។ បទថា **អត្តានុបេក្ខី (ជាអ្នកពិនិត្យតែខ្លួនឯង)** បានដល់ សម្លឹងមើលតែខ្លួនឯង ព្រោះដឹងកិច្ចដែលខ្លួនធ្វើហើយ និងមិនទាន់បានធ្វើ ។ បទថា **នោ បរានុបេក្ខី (មិនពិនិត្យភិក្ខុដទៃ)** បានដល់ មិនដាក់ចិត្តក្នុងកិច្ចដែលអ្នកដទៃធ្វើហើយ និងមិនទាន់បានធ្វើ ។ បទថា **អប្បញ្ញាតោ (គឺមានបុណ្យតិច)** បានដល់ អ្នកមិនប្រាកដ (មិនល្បីឈ្មោះ) គឺ មានបុណ្យតិច ។ បទថា **អប្បញ្ញាតិកេន (ព្រោះតែខ្លួនមិនល្បីឈ្មោះ)** បានដល់ ព្រោះភាពជាអ្នកមិនប្រាកដ គឺ មិនមានឈ្មោះល្បី ព្រោះមានបុណ្យតិច ។ បទថា **នោ បរិតស្សតិ (ក៏មិនរន្ធត់)** បានដល់ មិនដល់នូវសេចក្តីតក់ស្លុត ។ ដោយព្រះសូត្រនេះ

ព្រះដ៏មានព្រះភាគ ត្រាស់ចំពោះព្រះទីណាស្រេពប៉ុណ្ណោះ ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា អានន្ទសូត្រទី ៦

# អដ្ឋកថា សីលសូត្រទី ៧

*(គុណសម្បត្តិរបស់សង្ឃដែលជាស្រែបុណ្យ)*

[៧] *ក្នុងសីលសូត្រ ទ្រង់ត្រាស់សីល សមាធិ និងបញ្ញា (ទាំងលោកិយៈ និងលោកុត្តរៈ) ។* ***វិមុត្តិ*** *គឺ អរហត្តផល* ***វិមុត្តិញ្ញាណទស្សនៈ*** *គឺ បច្ចវេក្ខណញ្ញាណ ដែលជាលោកិយៈ ។*

ចប់អដ្ឋកថា សីលសូត្រទី ៧

# អដ្ឋកថា អសេក្ខិយសូត្រទី ៨

*(គុណសម្បត្តិរបស់សង្ឃដែលជាស្រែបុណ្យ)*

*[៨] ក្នុងសេក្ខិយសូត្រ ក៏ន័យដូចគ្នា (ដូចសូត្រទី ៧) តែក្នុងអសេក្ខិយសូត្រទី ៨ នេះ ត្រាស់បច្ចវេក្ខណញាណថា ជារបស់អសេក្ខៈ ព្រោះជាការប្រព្រឹត្តរបស់ព្រះអសេក្ខៈ ។*

ចប់អដ្ឋកថា សេក្ខិយសូត្រទី ៨

# អដ្ឋកថា ចាតុទ្ទិសសូត្រទី ៩

*(ធម៌របស់ភិក្ខុអ្នកត្រាច់ទៅក្នុងទិសទាំង ៤)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចាតុទ្ទិសសូត្រទី ៩ ដូចតទៅនេះ ៖*

[៩] *បទថា* ចាតុទ្ទិសោ *(ជាអ្នកត្រាច់ទៅក្នុងទិសទាំង ៤)* *បានដល់ទៅណា ក៏មិនជាប់ជំពាក់ក្នុងទិសទាំង ៤ ។ សូម្បីក្នុងសូត្រនេះ ក៏ត្រាស់ចំពោះព្រះខីណាស្រពប៉ុណ្ណោះ ។*

ចប់អដ្ឋកថា ចាតុទ្ទិសសូត្រទី ៩

# អដ្ឋកថា អរញ្ញសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងអរញ្ញសូត្រទី ១០ ដូចតទៅនេះ ៖*

[១០] *បទថា អលំ (គួរ) បានដល់ សមគួរ ។ សូម្បីក្នុងសូត្រនេះ ក៏ត្រាស់ចំពោះព្រះខីណាស្រពប៉ុណ្ណោះឯង ។*

ចប់អដ្ឋកថា អរញ្ញសូត្រទី ១០

## ចប់ផាសុវិហារវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# អន្ធកវិន្ទវគ្គវណ្ណនាទី ២

## អដ្ឋកថា កុលូបកសូត្រទី ១

*(ធម៌ធ្វើឲ្យជាទីគោរព និងមិនគោរពក្នុងត្រកូល)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កុលុបកសូត្រទី ១ ដូចតទៅនេះ ៖*

[១១] *បទថា **អសន្ថវវិស្សាសី (គឺជាអ្នកស្និទ្ធស្នាល)** បានដល់ សម្តែងសេចក្តីស្និទ្ធស្នាលជាមួយមនុស្ស ដែលមិនធ្លាប់ស្និទ្ធស្នាលជាមួយខ្លួន គឺ មិនធ្លាប់ស្និទ្ធស្នាលពីមុនទុំះឯង ។ បទថា **អនិស្សរវិកប្បី (ខ្លួនមិនមែនជាឥស្សរៈ តែលើកខ្លួនជាឥស្សរៈ)** បានដល់ មិនមែនអ្នកជាធំ តែធ្វើជាអ្នកធំ ដោយបង្គាប់ថា ពួកលោកចូរធ្វើវត្ថុនេះ ចូរទទួលវត្ថុនេះ ។ បទថា **ព្យត្តុបសេវី (ជាអ្នកចូលទៅរកប់រក ដើម្បីផ្សះផ្សាត្រកូលដែលបែកបាក់គ្នា)** បានដល់ ចូលទៅរកប់រកត្រកូលដែលបែកបាក់គ្នា មិនប្រាថ្នាចំពោះគ្នា ដើម្បីសម្រុះសម្រួលការបែកបាក់គ្នា ។ បទថា **ឧបកណ្ណកជប្បី (ជាអ្នកច្រើនខ្សឹបជិតត្រចៀកអ្នកឯទៀត)** បានដល់ សូត្រមន្តទីជិតត្រចៀក (ខ្សឹប) ។ ធម៌ចំណែកស គប្បីជ្រាបការផ្ទុយគ្នាជាមួយបទពោលហើយ ។*

ចប់អដ្ឋកថា កុលុបកសូត្រទី ១

# អដ្ឋកថា បច្ចាសមណសូត្រទី ២

## (ធម៌របស់អ្នកគួរ និងមិនគួរជាបច្ឆាសមណៈ)

គប្បីជ្រាបវិនិច្ឆ័យក្នុង បច្ឆាសមណសូត្រទី ២ ដូចតទៅនេះ ៖

[១២] បទថា **បត្តបរិយាបន្នំ ន គណ្ហាតិ** (មិនទទួលយកបាត្រ ឬវត្ថុដែលនៅក្នុងបាត្រ) សេចក្តីថា កាលឧបជ្ឈាយ៍បែរត្រឡប់មកឈរ នឹងថ្វាយបាត្រទទេរបស់ខ្លួនហើយ ទទួលបាត្ររបស់ឧបជ្ឈាយ៍ក៏ទេ ឬមិនទទួលបាត្រដែលឧបជ្ឈាយ៍បញ្ជូនឲ្យអំពីទីនោះ ។ បទថា **ន និវារេតិ** (មិនហាមឃាត់) បានដល់ មិនដឹងថាពាក្យនេះ ជាពាក្យកន្លងអាបត្តិ សូម្បីដឹង ក៏មិនបានហាមថា លោកម្ចាស់ គប្បីនឹងពោលពាក្យយ៉ាងនេះ ។ បទថា **កថំ ឱបាតេតិ** (ក៏និយាយពាក្យកាត់ត្រង់ចន្លោះ) បានដល់ និយាយកាត់ពាក្យរបស់លោក និយាយជ្រៀតពាក្យរបស់ខ្លួនចូលទៅ ។ បទថា **ជឡោ** (ជាអ្នកអប្បឥតប្រាជ្ញា) បានដល់ ជាមនុស្សល្ងង់ ។ បទថា **ឯឡមូគោ** (ល្ងង់ខ្លៅ) បានដល់ និយាយហៀរទឹកមាត់ចេញមក។

ចប់អដ្ឋកថា បច្ឆាសមណសូត្រទី ២

# អដ្ឋកថា សមាធិសូត្រទី ៣

*(ធម៌របស់អ្នកគួរ និងអ្នកមិនគួរលុះសម្មាសមាធិ)*

[១៣] *សូត្រទី ៣ នេះ មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា សមាធិសូត្រទី ៣

# អដ្ឋកថា អន្ធកវិន្ទសូត្រទី ៤

## (ធម៌របស់ភិក្ខុថ្មី ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង អន្ធកវិន្ទសូត្រទី ៤ ដូចតទៅនេះ ៖

[១៤] បទថា **សីលវា ហោថ** (ចូរជាអ្នកមានសីល) សេចក្ដីថា ចូរជាអ្នកមានសីល ។ បទថា **អារក្ខសតិនោ (តាំងស្មារតីរក្សា)** បានដល់ ជាអ្នកប្រកបដោយសតិជាគ្រឿងរក្សាទ្វារ ។ បទថា **និបកសតិនោ (តាំងស្មារតីប្រកបដោយញាណ)** បានដល់ មានសតិប្រកបដោយញាណជាគ្រឿងរក្សាខ្លួននុ៎ះឯង ។ បទថា **សតារក្ខេន ចេតសា សមន្នាគតា (ប្រកបដោយចិត្តដែលមានសតិជាគ្រឿងរក្សា)** បានដល់ ប្រកបដោយចិត្តដែលមានគ្រឿងរក្សា គឺ សតិ ។ បទថា **អប្បភស្សា (ចូរជាអ្នកមានពាក្យសម្ដីតិច)** បានដល់ និយាយតិច ។ បទថា **សម្មាទិដ្ឋិកា (ក្នុងការយល់ឃើញត្រូវ)** បានដល់ ប្រកបដោយសម្មាទិដ្ឋិ ៥ យ៉ាង គឺ កម្មស្សកតា ១ ឈាន ១ វិបស្សនា ១ មគ្គ ១ និងផល ១ ។ មួយវិញទៀត សូម្បីបច្ចវេក្ខណញ្ញាណ ក៏គប្បីជ្រាបថា ជាសម្មាទិដ្ឋិ ដូចគ្នា ។

ចប់អដ្ឋកថា អន្ធកវិន្ទសូត្រទី ៤

# អដ្ឋកថា មច្ឆរិយសូត្រទី ៥

*(ធម៌ធ្វើឲ្យភិក្ខុនីធ្លាក់នរក និងឡើងស្ថានសួគ៌)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មច្ឆរិយសូត្រទី ៥ ដូចតទៅនេះ ៖*

[១៥] *បទថា* ***អាវាសមច្ឆរិនី (គឺភិក្ខុនីកំណាញ់អាវាស)*** *បានដល់ រមែងកំណាញ់អាវាស គឺ ឃើញអ្នកដទៃនៅក្នុងអាវាសនោះ អត់ធន់មិនបាន ។ បទថា* ***កុលមច្ឆរិនី (កំណាញ់ត្រកូល)*** *បានដល់ រមែងកំណាញ់ត្រកូលឧបដ្ឋាក គឺ ឃើញអ្នកដទៃចូលទៅរកត្រកូលនោះ អត់ធន់មិនបាន ។ បទថា* ***លាភមច្ឆរិនី (កំណាញ់លាភ)*** *បានដល់ រមែងកំណាញ់លាភ គឺ ឃើញលាភកើតឡើងដល់អ្នកដទៃ ក៏អត់ទ្រាំមិនបាន ។ បទថា* ***វណ្ណមច្ឆរិនី (កំណាញ់គុណ)*** *បានដល់ រមែងកំណាញ់គុណ គឺ សេចក្តីល្អ គឺ ឃើញគេពោលគុណ គឺ សេចក្តីល្អរបស់អ្នកដទៃ អត់ទ្រាំមិនបាន ។ បទថា* ***ធម្មមច្ឆរិនី (កំណាញ់ធម៌)*** *បានដល់ រមែងកំណាញ់បរិយត្តិធម៌ គឺ មិនប្រាប្ឋានីងឲ្យដល់អ្នកដទៃ ។*

ចប់អដ្ឋកថា មច្ឆរិយសូត្រទី ៥

# អដ្ឋកថា វណ្ណនាសូត្រទី ៦

*(ធម៌ធ្វើឲ្យភិក្ខុនីធ្លាក់នរក និងឡើងស្ថានសួគ៌)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វណ្ណនាសូត្រទី ៦ ដូចតទៅនេះ ៖*

[១៦] *បទថា* សទ្ធាទេយ្យំ វិនិបាតេតិ *(ធ្វើសទ្ធាទេយ្យឲ្យធ្លាក់ចុះ) បានដល់ មិនកាន់យករបស់ល្អអំពីបាត្រដែលអ្នកដទៃថ្វាយដោយសទ្ធាមុន ហើយឲ្យដល់អ្នកដទៃ ។*

ចប់អដ្ឋកថា វណ្ណនាសូត្រទី ៦

# អដ្ឋកថា ឥស្សាសូត្រទី ៧

## *(ធម៌ធ្វើឲ្យធ្លាក់នរក និងឡើងស្ថានសួគ៌)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឥស្សាសូត្រទី ៧ ដូចតទៅនេះ ៖*

[១៧] *បទថា* ***ឥស្សុកិនី*** *(ជាអ្នកប្រចណែន) បានដល់ ជាអ្នកប្រកប ដោយសេចក្តីប្រចណែន ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ហើយ ។*

ចប់អដ្ឋកថា ឥស្សាសូត្រទី ៧

# អដ្ឋកថា និដ្ឋិសូត្រទី ៨

*(ធម៌ធ្វើឲ្យធ្លាក់នរក និងឡើងស្ថានសួគ៌)*

[១៨] *ក្នុងទិដ្ឋិសូត្រ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា និដ្ឋិសូត្រទី ៨

# អដ្ឋកថា វាចាសូត្រទី ៩

*(ធម៌ធ្វើឲ្យធ្លាក់នរក និងឡើងស្ថានសួគ៌)*

[១៩] *ក្នុងវាចាសូត្រ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា វាចាសូត្រទី ៩

# អដ្ឋកថា វាយាមសូត្រទី ១០

*(ធម៌ធ្វើឲ្យធ្លាក់នរក និងឡើងស្ថានសួគ៌)*

[២០] *ក្នុងវាយាមសូត្រ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា វាយាមសូត្រទី ១០

## ចប់អង្គុត្តរនិកាយវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៧ សូត្រ

# គិលានវគ្គវណ្ណនាទី ៣

## អដ្ឋកថា គិលានសូត្រទី ១

*(គុណធម៌របស់ភិក្ខុអាពាធ)*

[២១] *ក្នុងគិលានសូត្រ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា គិលានសូត្រទី ១

# អដ្ឋកថា សតិប្បដ្ឋានសូត្រទី ២

*(ធម៌ជាហេតុឲ្យភិក្ខុលុះអរិយផលក្នុងបច្ចុប្បន្ន)*

[២២] *ក្នុងសតិប្បដ្ឋានសូត្រ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា សតិប្បដ្ឋានសូត្រទី ២

# អដ្ឋកថា បឋមឧបដ្ឋាកសូត្រទី ៣

*(ធម៌របស់ភិក្ខុឈឺដែលព្យាបាលលំបាក និងងាយស្រួល)*

[២៣] *ក្នុងសតិប្បដ្ឋានសូត្រ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា បឋមឧបដ្ឋាកសូត្រទី ៣

# អដ្ឋកថា ទុតិយឧបដ្ឋាកសូត្រទី ៤

*(ធម៌របស់ភិក្ខុគួរ និងមិនគួរព្យាបាលភិក្ខុឈឺ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយឧបដ្ឋាកសូត្រទី ៤ ដូចតទៅនេះ ៖*

[២៤] *បទថា* ***ន បដិពលោ*** *(អ្នកមិនអាច) បានដល់ អ្នកមិនប្រកប ដោយកម្លាំងកាយ និងកម្លាំងញាណ ។ បទថា* ***អាមិសន្តរោ*** *(អ្នកសម្លឹង អាមិស) បានដល់ ជាអ្នកឃើញដល់អាមិស គឺ ប្រាថ្នាបច្ច័យ មានចីវរ ជាដើម ។*

ចប់អដ្ឋកថា ទុតិយឧបដ្ឋាកវគ្គទី ៤

# អដ្ឋកថា បឋមអនាយុស្សសូត្រទី ៥

*(ធម៌ជាហេតុអាយុខ្លី និងអាយុវែង)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអនាយុស្សសូត្រទី ៥ ដូចតទៅនេះ ៖*

[២៥] *បទថា* ***អនាយុស្សា*** *(ធម៌ធ្វើឲ្យអាយុខ្លី) បានដល់ ចូលទៅកាត់អាយុ គឺ មិនធ្វើឲ្យអាយុវែង ។*

ចប់អដ្ឋកថា បឋមអនាយុស្សសូត្រទី ៥

# អដ្ឋកថា ទុតិយអនាយុស្សសូត្រទី ៦

*(ធម៌ជាហេតុអាយុខ្លី និងអាយុវែង)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអនាយុស្សសូត្រទី ៤ ដូចតទៅនេះ ៖*

[២៦] *សូម្បីទុតិយអនាយុស្សសូត្រទី ៦ ក៏ន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា ទុតិយអនាយុស្សសូត្រទី ៦

# អដ្ឋកថា អវប្បកាសសូត្រទី ៧

*(ធម៌របស់ភិក្ខុដែលគួរ និងមិនគួរនៅម្នាក់ឯង)*

គប្បីជ្រាបវិនិច្ឆ័យក្នុង អវប្បកាសសូត្រទី ៧ ដូចតទៅនេះ ៖

[២៧] បទថា **នាលំ សង្ឃម្ហាវបកាសិតុំ** *(មិនគួរនឹងចេញចាកសង្ឃនៅម្នាក់ឯងទេ)* សេចក្តីថា មិនគួរគេចចេញអំពីសង្ឃ ទៅនៅតែម្នាក់ឯងទេ តែលោកក៏មិនគួរនៅសូម្បីត្រង់កណ្តាលសង្ឃ ព្រោះមិនធ្វើសង្ឃឲ្យបរិសុទ្ធ ដូច្នេះ ក៏មិនគួរចាកចេញអំពីសង្ឃ ដោយនិប្បិយាយ ព្រោះទាក់ទងដោយឱវាទានុសាសនី ។ បទថា **អលំ សង្ឃម្ហាវបកាសិតុំ** *(ទើបគេចចេញពីសង្ឃ ទៅនៅតែម្នាក់ឯងបាន)* សេចក្តីថា នឹងចៀសចេញអំពីសង្ឃ នៅតែម្នាក់ឯងប៉ុណ្ណោះ ដោយអាស្រ័យនៅក្នុងទិសទាំង ៤ ក៏គួរ និងនៅសូម្បីក្នុងពួកក៏គួរដូចគ្នា ព្រោះធ្វើសង្ឃឲ្យស្អាតបរិសុទ្ធ ។

ចប់អដ្ឋកថា អវប្បកាសសូត្រទី ៧

# អដ្ឋកថា សមណទុក្ខសូត្រទី ៧

*(ទុក្ខ និងសុខរបស់សមណៈ ៥ ប្រការ)*

[២៨] *សមណទុក្ខសូត្រ មានសេចក្ដីងាយយល់ហើយ ។*

ចប់អដ្ឋកថា សមណទុក្ខសូត្រទី ៨

# អដ្ឋកថា បរិកុប្បសូត្រទី ៩

*(ទុក្ខ និងសុខរបស់សមណៈ ៥ ប្រការ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បរិកុប្បសូត្រទី ៩ ដូចតទៅនេះ ៖*

[២៩] *បទថា* ***អាបាយិកា*** *(ជាអ្នកទៅកាន់អបាយ) បានដល់ ជាអ្នកមានប្រក្រតីទៅកាន់អបាយ ។ បទថា* ***នេរយិកា*** *(ទៅកាន់នរក) បានដល់ មានប្រក្រតីទៅកាន់នរក ។ បទថា* ***បរិកុប្បា*** *(ជាបុគ្គលកែប្រែមិនបាន) បានដល់ នរណាៗ នឹងធ្វើឲ្យប្រឡប់មកវិញមិនបាន ។*

ចប់អដ្ឋកថា បរិកុប្បសូត្រទី ៩

# អដ្ឋកថា សម្បទាសូត្រទី ១០

*(សេចក្តីវិនាស ៥ និងសម្បត្តិ ៥)*

[៣០] *សម្បទាសូត្រទី ១០ មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា សម្បទាសូត្រទី ១០

## ចប់គិលានវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៤ សូត្រ

# រាជវគ្គវណ្ណនាទី ៤

## អដ្ឋកថា ចក្កសូត្រទី ១

*(គុណរបស់ព្រះពុទ្ធ និងស្តេចចក្រពត្តិ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចក្កសូត្រទី ១ ដូចតទៅនេះ ៖*

*[៣១] បទថា* ***ធម្មេន*** *(ដោយកុសលធម៌) បានដល់ ដោយកុសលធម៌ ១០ ។ បទថា* ***ចក្កំ*** *(ចក្រ) បានដល់ ចក្រ គឺ ប្រាជ្ញា ។ បទថា* ***អត្ថញ្ញូ*** *(ទ្រង់ឈ្វេងយល់ប្រយោជន៍) បានដល់ ទ្រង់ដឹងប្រយោជន៍នៃរាជសម្បត្តិ ។ បទថា* ***ធម្មញ្ញូ*** *(ទ្រង់ចាំនូវប្រវេណីធម៌) បានដល់ ទ្រង់ដឹងធម៌ គឺ ប្រវេណី ។ បទថា* ***មត្តញ្ញូ*** *(ទ្រង់ស្គាល់ប្រមាណ) បានដល់ ទ្រង់ដឹងប្រមាណក្នុងការដាក់រាជអាជ្ញាក្នុងការរក្សាពន្ធអាករ ។ បទថា* ***កាលញ្ញូ*** *(ទ្រង់ស្គាល់កាល) បានដល់ ដឹងវេលាសោយសុខក្នុងរាជសម្បត្តិ វេលាធ្វើការវិនិច្ឆ័យ និងវេលាជាការគួរទៅកាន់ជនបទ ។ បទថា* ***បរិសញ្ញូ*** *(ទ្រង់ស្គាល់បរិសទ្យ) បានដល់ ទ្រង់ដឹងថា នេះជាក្សត្រិយ៍ នេះជាព្រាហ្មណ៍ នេះជាវេស្សៈ នេះជាសូទ្រៈ នេះជាសមណៈ ។*

ក្នុងវាវៈពោលដោយព្រះតថាគត គប្បីជ្រាបសេចក្តីដូចតទៅនេះ ។ បទថា **អត្ថញ្ញូ** (ទ្រង់ដឹងផល) បានដល់ ទ្រង់ដឹងប្រយោជន៍ ៥ ។ បទថា **ធម្មញ្ញូ** (ទ្រង់ដឹងហេតុ) បានដល់ ទ្រង់ដឹងធម៌ ៤ យ៉ាង ។ បទថា **មត្តញ្ញូ** (ទ្រង់ដឹងប្រមាណ) បានដល់ ទ្រង់ដឹងប្រមាណក្នុងការទទួល និងការបរិភោគបច្ច័យ ៤ ។ បទថា **កាលញ្ញូ** (ទ្រង់ដឹងកាល) បានដល់ ទ្រង់ដឹងកាលយ៉ាងនេះថា នេះវេលាពួនសម្ងំ នេះវេលាចូលសមាបត្តិ នេះវេលាសម្តែងធម៌ នេះវេលាចារិកទៅក្នុងជនបទ ។ បទថា **បរិសញ្ញូ** (ទ្រង់ដឹងបរិសទ្យ) បានដល់ ទ្រង់ដឹងថា នេះជាក្សត្រិយ៍បរិសទ្យ ។ល។ នេះជាសមណៈបរិ-សទ្យ ។ បទថា **អនុត្តរំ** (ដែលល្អដាច់គេ) បានដល់ ដែលល្អប្រសើរ គឺ លោកុត្តរធម៌ ៩ ។ បទថា **ធម្មចក្កំ** (ធម្មចក្រ) បានដល់ ចក្រ គឺធម៌ដ៏ប្រសើរ ។

ចប់អដ្ឋកថា ចក្កសូត្រទី ១

# អដ្ឋកថា អនុវត្តនសូត្រទី ២

## (គុណរបស់ព្រះសារីបុត្ត និងឱរសស្តេចចក្រពត្តិ)

គប្បីជ្រាបវិនិច្ឆ័យក្នុង អនុវត្តនសូត្រទី ២ ដូចតទៅនេះ ៖

[៣២] បទថា *បិតរា បវត្តិតំ ចក្កំ* (រមែងញុំាងអាណាចក្រដែលបិតាធ្លាប់ឲ្យប្រព្រឹត្តទៅ) សេចក្តីថា កាលស្តេចចក្រពត្តិទ្រង់គង់ព្រះជន្មាយុនៅ ឬស្តេចសោយទិវង្គតទៅហើយ ចក្ររតន៍តាំងនៅត្រឹមតែ ៧ ថ្ងៃ ក៏អន្តរធានទៅ ។ សួរថា ព្រះឱរសច្បងគេរបស់ព្រះអង្គនេះ នឹងញុំាងចក្រឲ្យប្រព្រឹត្តទៅតាម បានដូចម្តេច ។ ឆ្លើយថា ព្រះឱរសនោះ កាលទ្រង់តាំងនៅក្នុងប្រវេណីរបស់បិតា បំពេញចក្រ គឺ ប្រតិបត្តិវត្តឲ្យបរិបូរណ៍ ស្តេចគ្រប់គ្រងចក្រពត្តិរាជ្យបាន ក៏ឈ្មោះថា ទ្រង់ញុំាងចក្រដែលបិតាឲ្យវិលហើយ នោះឯង ។

ចប់អដ្ឋកថា អនុវត្តនសូត្រទី ២

# អដ្ឋកថា រាជសូត្រទី ៣

## (ព្រះពុទ្ធ និងស្តេចចក្រពត្តិគោរពធម៌)

[៣៣] រាជសូត្រ មានសេចក្តីដូចពោលហើយក្នុងតិកនិបាតនោះឯង ។ តែក្នុងសូត្រនេះ មានសេចក្តីផ្សេងគ្នា ២ បទក្រោយប៉ុណ្ណោះ គឺ បទថា គួរសេព និងមិនគួរសេព ។ ក្នុង ២ បទនោះ សម្មាអាជីវៈគួរសេព មិច្ឆាអាជីវៈមិនគួរសេព ។ ស្រុក និងនិគម ដែលជាទីសប្បាយគួរសេព ដែលមិនសប្បាយមិនគួរសេព ។

ចប់អដ្ឋកថា រាជសូត្រទី ៣

# អដ្ឋកថា យសសុត្រទី ៤

## (អង្គគុណរបស់ក្សត្រិយ៍ និងរបស់ភិក្ខុ)

គប្បីជ្រាបវិនិច្ឆ័យក្នុង យសសុត្រទី ៤ ដូចតទៅនេះ ៖

[៧៤] បទថា **ឧភតោ** (ទាំងពីរចំណែក) បានដល់ ចំណែកសូម្បីទាំង ២ ។ បទថា **មាតិតោ ច បិតិតោ ច** (គឺខាងព្រះមាតា និងព្រះបិតា) សេចក្តីថា ក៏ព្រះរាជាអង្គណា មានព្រះមាតាជាក្សត្រិយ៍ ព្រះមាតារបស់ព្រះមាតាជាក្សត្រិយ៍ សូម្បីព្រះមាតារបស់ព្រះមាតានោះ ក៏មានព្រះមាតាជាក្សត្រិយ៍ , មានព្រះបិតាជាក្សត្រិយ៍ ព្រះបិតារបស់ព្រះបិតាជាក្សត្រិយ៍ សូម្បីព្រះបិតារបស់ព្រះបិតានោះ ក៏មានព្រះបិតាជាក្សត្រិយ៍ ព្រះរាជាព្រះអង្គនោះ ឈ្មោះថា មានព្រះកំណើតល្អទាំង ២ ចំណែក គឺ ទាំងចំណែកព្រះមាតា ទាំងចំណែកព្រះបិតា ។ បទថា **សំសុទ្ធគហណិកោ** (ប្រសូត្រចាកព្រះគភ៌ដ៏បរិសុទ្ធ) បានដល់ ប្រកបដោយព្រះគភ៌របស់ព្រះមាតាដ៏បរិសុទ្ធ ។ ក៏តេជោធាតុដែលកើតអំពីកម្ម លោកហៅថា **គហណី** (ភ្លើងធាតុ) ។ ក្នុងបទថា **បាកិនីយា គហណិយា** (ភ្លើងធាតុដែលដុតអាហារ

ឲ្យធ្លិនស្មើគ្នា) នេះ ។ បិតារបស់បិតា ឈ្មោះ បិតាមហ ខាងលើបិតា-មហៈ ឈ្មោះ បិតាមហយុគ ក្នុងបទថា យាវ សត្តមា បិតាមហយុគា (អំពីជំណាន់នៃអយ្យកោ និងអយ្យិកា ជាគម្រប់ ៧) ។ ប្រមាណអាយុ លោកហៅថា យុគ ។ ក៏ពាក្យនេះ ត្រឹមតែជាពាក្យហៅគ្នាប៉ុណ្ណោះ ។ តែដោយសេចក្តី បិតាមហៈនុ៎ះឯង ជាបិតាមហយុគ ចាប់ពីបុព្វបុរសទាំង អស់នោះឡើងទៅ លោកកាន់យកដោយសព្ទ បិតាមហៈ សព្ទនោះឯង ទ្រង់មានព្រះគតិដែលបដិសន្ធិដ៏បរិសុទ្ធរហូតដល់ ៧ ជំណា ពីបុព្វបុរស យ៉ាងនេះ ។ មួយ៉ាងវិញទៀត ទ្រង់សម្តែងថា មិនត្រូវរិះគន់ មិនត្រូវ តិះដៀល ដោយអាងដល់ជាតិ កំណើត ។

បទថា អក្ខិត្តោ (រិះគន់) បានដល់ មិនត្រូវបណ្តេញចេញ គឺ មិន ត្រូវបណ្តេញយ៉ាងនេះថា ចូលនាំវាចេញទៅ ប្រយោជន៍អ្វីដោយវានេះ ។ បទថា អនុបកុដ្ឋោ (តិះដៀល) បានដល់ មិនត្រូវតិះដៀល គឺ មិនធ្លាប់ ជេរ ឬនិន្ទា ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះរឿងកំណើត អធិប្បាយថា ដោយពាក្យបែបនេះថា អ្នកនេះមានកំណើតអាក្រក់ សូម្បី

ដោយប្រការដូច្នេះ ។ ក្នុងបទថា **អឌ្ឍោ** (**ព្រះអង្គជាស្តេចស្តុកស្តម្ភ**) ជាដើម អ្នកណាមួយជាអ្នកស្តុកស្តម្ភ ព្រោះសម្បត្តិដែលជារបស់ខ្លួន តែក្នុងទីនេះ មិនមែនជាអ្នកស្តុកស្តម្ភតែម៉្យាងប៉ុណ្ណោះ ។ បទថា **មហទ្ធនោ** (**មានរាជទ្រព្យច្រើន**) អធិប្បាយថា ជាអ្នកមានទ្រព្យច្រើន គឺ ប្រមាណមិនបាន ។ បទថា **មហាភោគោ** (**មានភោគសម្បត្តិច្រើន**) បានដល់ព្រោះព្រះអង្គមានភោគៈច្រើន គឺ សម្បូរដោយកាមគុណ ៥ ។ **កោសៈ** ក្នុងបទថា **បរិបុណ្ណកោសកោដ្ឋាគារោ** (**មានឃ្លាំង និងជង្រុកដ៏បរិបូរណ៍**) ពោលសំដៅយកឃ្លាំង សេចក្តីថា មានឃ្លាំងបរិបូរណ៍ដោយទ្រព្យ ដែលរក្សាទុក និងមានជង្រុកបរិបូរណ៍ដោយស្រូវ (សាលី) ។ ន័យម៉្យាងទៀត **កោសៈ** មាន ៤ យ៉ាង គឺ ពលដំរី ពលសេះ ពលរថ និងពលថ្មើរជើង ។ **កោដ្ឋាគារ** (ឃ្លាំង) មាន ៣ យ៉ាង គឺ ឃ្លាំងទ្រព្យ ឃ្លាំងស្រូវ ឃ្លាំងសំពត់ ។ ព្រះរាជាដែលមានឃ្លាំង និងស្រូវបរិបូរណ៍ ព្រោះព្រះអង្គមានឃ្លាំង និងស្រូវបរិបូរណ៍គ្រប់គ្រាន់ទាំងអស់ ។

បទថា **អស្សវាយ** (**ដែលអាចស្តាប់បង្គាប់**) សេចក្តីថា កាលព្រះ

រាជទានទ្រព្យសម្បត្តិច្រើនដល់នរណាៗ សេនាក៏មិនស្តាប់បង្គាប់ សេនានោះឈ្មោះថា មិនស្តាប់បង្គាប់ ។ បទថា **ឱវាទប្បដិការាយ (ដែលអាចស្តាប់បង្គាប់ធ្វើតាមព្រះរាជឱវាទ)** បានដល់ ធ្វើតាមព្រះឱវាទដែលព្រះរាជ-ទានថា អ្នកទាំងឡាយគួរធ្វើវត្ថុនេះ មិនគួរធ្វើវត្ថុនេះ ។ បទថា **បណ្ឌិតោ (ជាបណ្ឌិត)** បានដល់ ប្រកបដោយភាពជាបណ្ឌិត ។ បទថា **ព្យត្តោ (ជាអ្នកប្រាជ្ញវាងវៃ)** បានដល់ ប្រកបដោយភាពឈ្លាសវៃនៃបញ្ញា ។ បទថា **មេធាវី (មានប្រាជ្ញា)** បានដល់ ប្រកបដោយប្រាជ្ញាជាគ្រឿងធ្វើឲ្យកើតឡើងនៃតំណែង ។ បទថា **បដិពលោ (អង់អាច)** បានដល់ ជាអ្នកអាច ។ បទថា **អត្ថេ ចិន្តេតុំ (តែគិតឃើញដល់ប្រយោជន៍ដែលជាអតីត អនាគត និងបច្ចុប្បន្ន)** បានដល់ គប្បីគិតដល់ប្រយោជន៍ គឺ សេចក្តីចម្រើន ។ ពិតហើយ បរិនាយកនោះ គិត ដោយអាស្រ័យប្រយោជន៍បច្ចុប្បន្ននោះឯងថា សម្បត្តិអតីតក៏មានហើយយ៉ាងនេះ សម្បត្តិក្នុងអនាគតក៏នឹងមានយ៉ាងនេះ ។ បទថា **វិជិតាវីនំ (ជាទំនៀមរបស់បុគ្គលទាំងឡាយដែលមានជ័យជំនះ)** បានដល់ សម្រាប់អ្នកមានជ័យជំនះ ដែលទ្រង់ឈ្នះ

*វិសេសហើយ ឬទ្រទ្រង់ប្រកបដោយជ័យជំនះដ៏ធំក្រៃលែង ។ បទថា* ***វិមុត្ត-ចិត្តានំ*** *(រមែងស្ថិតនៅដោយវិមុត្តិចិត្តតែម្យ៉ាង) បានដល់ សម្រាប់អ្នកដែលមានចិត្តរួចផុតដោយវិមុត្តិ ៥ ។*

ចប់អដ្ឋកថា យសស្សនិសសូត្រទី ៤

# អដ្ឋកថា បឋមបត្ថនាសូត្រទី ៥

*(អង្គគុណរបស់ព្រះរាជឱរសច្បង និងភិក្ខុ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមបត្ថនាសូត្រទី ៥ ដូចតទៅនេះ ៖*

[៣៥] *បទថា* ***នេគមជានបទស្ស*** ***(ជាទីគាប់ចិត្តរបស់អ្នកនិគម អ្នកជនបទ)*** *បានដល់ នៃជនអ្នកនៅក្នុងនិគម និងអ្នកនៅក្នុងជនបទ ។ បទថា* ***ហត្ថិស្មឹ (ទោះជាសិល្បៈខាងដំរី)*** *ជាដើម ទ្រង់សម្តែងសិល្បៈសំខាន់ ១៦ ប្រការ គឺ សិល្បៈទាក់ដំរី សេះ រថ ធ្នូ ការសរសេរ និងគូរ និងការរាប់លេខជាដើម ។ បទថា* ***អនវយោ (ឥតមានទើសទាល់)*** *បានដល់ សម្រេច បរិបូរណ៍ ។ បទដ៏សេសក្នុងសូត្រនេះ គប្បីជ្រាបតាមន័យដូចដែលបានពោលទុកហើយ ។*

ចប់អដ្ឋកថា បឋមបត្ថនាសូត្រទី ៥

# អដ្ឋកថា ទុតិយបត្ថនាសូត្រទី ៦

*(អង្គគុណរបស់ព្រះរាជឱរសច្បង និងភិក្ខុ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយបត្ថនាសូត្រទី ៦ ដូចតទៅនេះ ៖*

[៣៦] *បទថា* ***ឧបរជ្ជំ*** *(រមែងប្រាថ្នានូវឧបរាជ) បានដល់ ភាពជាឧបរាជ ។*

ចប់អដ្ឋកថា ទុតិយបត្ថនាសូត្រទី ៦

# អដ្ឋកថា អប្បស្សុបតិសូត្រទី ៧

## (បុគ្គលលក់តិច ភ្ញាក់ច្រើន ៥ ពួក)

គប្បីជ្រាបវិនិច្ឆ័យក្នុង អប្បស្សុបតិសូត្រទី ៧ ដូចតទៅនេះ ៖

[៣៧] បទថា **បុរិសាធិប្បាយា** (មានប្រាថ្នាចំពោះបុរស ដោយអសទ្ធម្ម) បានដល់ មានសេចក្ដីប្រាថ្នាក្នុងបុរសកើតឡើង ដោយអំណាចអសទ្ធម្ម គឺ មានសេចក្ដីពេញចិត្តក្នុងបុរស ។ បទថា **អាទានាធិប្បាយោ** (ចោរដែលបំណងកាន់យកទ្រព្យរបស់គេ) បានដល់ អ្នកមានសេចក្ដីប្រាថ្នានឹងលួចយ៉ាងនេះថា ឥឡូវនេះ អញនឹងលួចយកឲ្យបាន ឥឡូវនេះ អញលួចមិនបាន ។ បទថា **វិសញ្ញោគាធិប្បាយោ** (ភិក្ខុដែលមានបំណងដើម្បីអស់សញ្ញោជនៈ "ព្រះនិព្វាន") បានដល់ អ្នកប្រាថ្នាព្រះនិព្វានយ៉ាងនេះថា យើងនឹងសម្រេចព្រះនិព្វានក្នុងកាលឥឡូវនេះ ។

ចប់អដ្ឋកថា អប្បស្សុបតិសូត្រទី ៧

# អដ្ឋកថា ភគ្គោទកសូត្រទី ៨

*(អង្គរបស់ដំរីដែលស៊ីច្រើន និងភិក្ខុឆាន់ច្រើន)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភគ្គោទកសូត្រទី ៨ ដូចតទៅនេះ ៖*

*[៣៨] បទថា **ភគ្គោទកោ** (ស៊ីអាហារ) បានដល់ ចាំតែស៊ី អធិប្បាយថា ស៊ីច្រើន ។ បទថា **ឱកាសផរណោ** (វាតទី) បានដល់ ឈ្មោះថា វាតទី ព្រោះឈរស៊ី ដែលធ្វើឲ្យបង្កៀតដល់ដំរីឯទៀតៗ ។ ដែលឈ្មោះថា **លណ្ឌសាធនោ** (ជម្រះអាចម៍ត្រង់ទីនោះ) បានដល់ ព្រោះដើរជុះអាចម៍រាត់រាយក្នុងទីនោះៗ ។ ឈ្មោះថា **សលាកគ្គាហី** (កាន់យកស្លាក) បានដល់ ព្រោះទទួលយកលទ្ធផលក្នុងពេលរាប់ចំនួនថា ដំរីនេះមានចំនួនប៉ុណ្ណោះ ។ ដែលឈ្មោះថា **បីឋមទ្ទនោ** (ជុសខាត់នូវតាំង) បានដល់ ព្រោះខំធ្វើគ្រែនិងតាំងដោយការជុសខាត់ ។ ដែលឈ្មោះថា **សលាកគ្គាហី** (កាន់យកស្លាក) បានដល់ ព្រោះទទួលលទ្ធផលក្នុងវេលារាប់ចំនួនភិក្ខុ ។*

ចប់អដ្ឋកថា ភគ្គោទកសូត្រទី ៨

# អដ្ឋកថា អក្ខមសូត្រទី ៩

## (លក្ខណៈរបស់ដំរី និងរបស់ភិក្ខុ)

គប្បីជ្រាបវិនិច្ឆ័យក្នុង អក្ខមសូត្រទី ៩ ដូចតទៅនេះ ៖

[៣៩] បទថា *ហត្ថិកាយំ (ពួកពលដំរី)* បានដល់ ទ័ពដំរី ។ សូម្បីក្នុងបទដ៏សេសទាំងឡាយ ក៏ន័យនេះដូចគ្នា ។ បទថា *សង្គាមគតោ (ទៅកាន់សង្គ្រាម)* បានដល់ ព្រោះចូលទៅកាន់សង្គ្រាម ។ បទថា *ឯកិស្សា តិណោទកទត្តិយា វិមានិតោ (មិនមានគេរាប់អានដោយឲ្យស្មៅ និងទឹកមួងក្ដី)* សេចក្ដីថា មិនចិញ្ចឹមថែរក្សាដោយការឲ្យស្មៅ និងទឹកក្នុងមួយថ្ងៃម្ដង អធិប្បាយថា មិនបានស្មៅ និងទឹកក្នុងមួយថ្ងៃសូម្បីត្រឹមតែម្ដង ។ សូម្បីតអំពីនេះ ក៏មានន័យនេះដូចគ្នា ។ បទថា *ន សក្កោតិ ចិត្តំ សមាទហិតុំ (មិនអាចតម្កល់ចិត្តឲ្យនឹងបាន)* បានដល់ មិនអាចតាំងចិត្តទុកដោយប្រពៃក្នុងអារម្មណ៍ ។ បទថាដ៏សេសក្នុងសូត្រនេះ ងាយយល់ទាំងអស់ ។ ក៏ក្នុងសូត្រនេះ គប្បីជ្រាបថា ត្រាស់ទាំងវដ្ដៈ និងវិវដ្ដៈ ។

ចប់អដ្ឋកថា អក្ខមសូត្រទី ៩

# អដ្ឋកថា សោតវសូត្រទី ១០

## (អង្គគុណរបស់ដំរី និងរបស់ភិក្ខុ)

គប្បីជ្រាបវិនិច្ឆ័យក្នុង សោតវសូត្រទី ១០ ដូចតទៅនេះ ៖

[៤០] បទថា **ទុរុត្តានំ** (ពោលពាក្យអាក្រក់) សេចក្ដីថា បានដល់តពាក្យគ្រោតគ្រាតដែលគេពោលមិនល្អ និងឲ្យប្រព្រឹត្តទៅដោយអំណាចទោសៈ ។ បទថា **ទុរាគតានំ** (គួរឲ្យកើតទុក្ខ) បានដល់ ដែលមកកាន់សោតទ្វារ ដោយអាការដែលឲ្យកើតទុក្ខ ។ បទថា **វចនបថានំ** (ចំពោះពាក្យ) បានដល់ ចំពោះពាក្យនិយាយទាំងឡាយ ។ បទថា **ទុក្ខានំ** (ទុក្ខវេទនា) បានដល់ ដែលទ្រាំបានដោយលំបាក ។ បទថា **តិប្បានំ**[១] (ដ៏ខ្លាំងក្លា) បានដល់ ក្លាខ្លាំង ឬមានសភាពធ្វើឲ្យក្ដៅក្រហាយ ។ បទថា **ខរានំ** (ខ្វាចផ្សា) បានដល់ លំបាក ។ បទថា **កដុកានំ** (មិនស្រួល) បានដល់ មិនស្រួលខ្លាំង ។ បទថា **អសាតានំ** (មិនជាទីគាប់ចិត្ត) បានដល់ មិនបានសេចក្ដីសុខ ។ បទថា **អមនាបានំ** (មិនជាទីពេញចិត្ត) បាន

(១) បិដក = តិព្វានំ

ដល់ មិនអាចធ្វើចិត្តឲ្យត្រជាក់ គឺ ធ្វើឲ្យចម្រើនចិត្តបាន ។ បទថា *បាណ-ហរានំ (គួរនាំយកនូវជីវិតដែលកើតឡើងហើយ)* បានដល់ គ្រាជីវិតវិនាស បាត់បង់ទៅ ។ ព្រះនិព្វាន គប្បីជ្រាបថា ឈ្មោះថា ទិស ក្នុងបទថា *យា សា ទិសា (ទៅកាន់ទិស)* បានដល់ ព្រោះប្រកដច្បាស់ហើយក្នុងធម៌ មានធម៌ជាទីរម្ងាប់សង្ខារទាំងពួងជាដើម ។ តែព្រោះហេតុដែលសង្ខារទាំង ពួងអាស្រ័យព្រះនិព្វាននោះហើយ រមែងដល់ការស្ងប់រម្ងាប់ ដូច្នោះ ទើប ត្រាស់ហៅនិព្វាននោះថា *សព្វសង្ខារសមថោ (ធម៌ជាទីរម្ងាប់សង្ខារទាំង ពួង)* ។ បទដ៏សេសគ្រប់កន្លែងងាយយល់ហើយ ។ ក៏ក្នុងសូត្រនេះ ត្រាស់ សីល សមាធិ បញ្ញា (ទាំងលោកិយៈ និងលោកុត្តរៈ លាយគ្នាដូច្នេះ ។

ចប់អដ្ឋកថា សោតវសូត្រទី ១០

## ចប់រាជវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# តិកណ្ឌកីវគ្គវណ្ណនាទី ៥

## អដ្ឋកថា ទត្វាអវជានាតិសូត្រទី ១

(បុគ្គលអាក្រក់ ៥ ពួក)

គប្បីជ្រាបវិនិច្ឆ័យក្នុង ទត្វាអវជានាតិសូត្រទី ១ ដូចតទៅនេះ ៖

[៨១] បទថា **សំវាសេន** (ការនៅរួមគ្នា) បានដល់ ព្រោះការនៅដោយភាពសាមគ្គីតែម្យ៉ាង ។ បទថា **អាទេយ្យមុខោ** (មានការកាន់យកតាមពាក្យគេជាប្រមាណ) បានដល់ ធ្វើទុកចិត្ត អធិប្បាយថា តម្កល់ចិត្តជឿ ។ បទថា **តមេនំ ទត្វា អវជានាតិ** (លុះឲ្យរួចហើយ ត្រឡប់មើលងាយអ្នកទទួលនោះវិញ) បានដល់ រមែងមើលងាយគេយ៉ាងនេះថា បុគ្គលនេះ ដឹងតែទទួលនូវវត្ថុដែលយើងឲ្យប៉ុណ្ណោះ ។ បទថា **តមេនំ សំវាសេន អវជានាតិ** (មើលងាយបុគ្គលនោះ ព្រោះការនៅរួម) សេចក្តីថា ជាអ្នកក្រោធក្នុងបុគ្គលណាៗ ត្រឹមតែបន្តិចបន្តួច ហើយតែងតែពោលពាក្យជាដើមថា យើងដឹងកម្មដែលលោកធ្វើទុក យើងធ្វើអ្វីហើយ រហូតអស់កាលយូរប្រមាណប៉ុណ្ណោះ យើងពិចារណាមើលកម្មដែលលោកធ្វើទុក និងមិនបាន

ធ្វើទុកមិនមែនឬ ទីនោះ បុគ្គលក្រៅអំពីនេះគិតថា ទោសណាៗ របស់យើង នឹងមានដោយពិត ទើបមិនអាចនឹងឆ្លើយតបអ្វីបាន ។ បទថា **តំ ខិប្បញ្ញេវ អធិមុច្ចិតា ហោតិ (រមែងជឿស៊ប់នូវពាក្យនោះមួយរំពេច)** សេចក្តីថា បុគ្គលរមែងជឿទាំងគុណទាំងទោសនោះមួយរំពេច ។ បុគ្គលនេះលោកពោលថា ឈ្មោះថា **អាទិយនមុខោ (ជាអ្នកជឿងាយ)** ព្រោះដោយអត្ថថា ជឿងាយ ។ តែក្នុងព្រះបាលីថា **អាធីយមុខោ**[១] គឺ ជឿស៊ប់ ។ អធិប្បាយថា ជឿស៊ប់ ទទួលយកទាំងគុណ ឬទោស ព្រោះការជឿងាយ ដូចអណ្តូងទឹកដែលគេជីកត្រង់ផ្លូវ រង់ចាំទទួលទឹកដែលហូរមក ។

បទថា **ឥត្តរសទ្ធោ (ជាអ្នកមានសទ្ធាតិច)** បានដល់ មានសទ្ធាតិចតួច ។ ក្នុងបទថា **កុសលាកុសលេ ធម្មេ ន ជានាតិ (មិនដឹងនូវធម៌ជាកុសល និងធម៌ជាអកុសល)** ជាដើម សេចក្តីថា មិនដឹងនូវធម៌ជាកុសលថា ធម៌ទាំងនេះជាកុសល មិនដឹងធម៌ជាអកុសលថា ធម៌ទាំងនេះជាអកុសល ។ម្យ៉ាងទៀត មិនដឹងធម៌មានទោស គឺ ធម៌ដែលប្រព្រឹត្តទៅ

---

(១) បិដក = អធិមុច្ចិតោ ។

ជាមួយទោសថា ធម៌ទាំងនេះមានទោស , មិនដឹងធម៌មិនមានទោស គឺ ធម៌ដែលមិនប្រព្រឹត្តជាមួយទោសថា ធម៌ទាំងនេះមិនមានទោស មិនដឹង ធម៌ថោកទាបថា ថោកទាប មិនដឹងធម៌ប្រណីតថា ប្រណីត ។ បទថា កណ្ហសុក្កសប្បដិភាគេ (ចំណែកប្រៀបដោយខ្មៅ និងស) បានដល់ បុគ្គល រមែងមិនដឹងថា ធម៌ចំណែកខ្មៅទាំងនេះ ឈ្មោះថា ប្រៀបធៀប ព្រោះហាម ធម៌ចំណែកស , ធម៌ចំណែកសទាំងនេះ ឈ្មោះថា ប្រៀបធៀប ព្រោះហាម ធម៌ចំណែកខ្មៅ ដូច្នេះ ។

ចប់អដ្ឋកថា ឧត្វាអវជានាតិសូត្រទី ១

# អដ្ឋកថា អារភតិសូត្រទី ២

## (បុគ្គលដែលគួរជាស់តឿន ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង អារភតិសូត្រទី ២ ដូចតទៅនេះ ៖

[៤២] បទថា **អារភតិ ច វិប្បដិសារី ច ហោតិ** (រមែងប្រារព្ធផង មានសេចក្តីក្តៅក្រហាយផង) សេចក្តីថា បានដល់ការប្រព្រឹត្តកន្លងអាបត្តិហើយក្តៅក្រហាយ ដោយការប្រព្រឹត្តកន្លងនោះ ។ បទថា **ចេតោ-វិមុត្តឹ បញ្ញាវិមុត្តឹ** (នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ) បានដល់ អរហត្ត-សមាធិ និងអរហត្តផលញ្ញាណ ។ បទថា **នប្បជានាតិ** (មិនដឹងច្បាស់តាមពិត) បានដល់ មិនដឹង ព្រោះនៅមិនទាន់បានសម្រេច ។ បទថា **អារភតិ ន វិប្បដិសារី ហោតិ** (រមែងប្រារព្ធ តែមិនមានសេចក្តីក្តៅក្រហាយ) បានដល់ ត្រូវអាបត្តិ តែជាអ្នកមិនក្តៅក្រហាយ ព្រោះចេញចាកអាបត្តិហើយ ។ បទថា **ន អារភតិ វិប្បដិសារី ហោតិ** (រមែងមិនប្រារព្ធ តែមានសេចក្តីក្តៅក្រហាយ) បានដល់ ត្រូវអាបត្តិម្តងហើយ ក៏ចេញចាកអាបត្តិនោះ ខាងក្រោយមិនត្រូវអាបត្តិសូម្បីដទៃទៀត ក៏មិនអាច

បន្ទោបង់សេចក្ដីក្ដៅក្រហាយបាន ។ បទថា **ន អារភតិ ន វិប្បដិសារី ហោតិ** (រមែងមិនប្រារព្ធ មិនមានសេចក្ដីក្ដៅក្រហាយ) បានដល់ ទាំងមិនត្រូវអាបត្តិ ទាំងមិនមានសេចក្ដីក្ដៅក្រហាយ ។ បទថា **តញ្ច ចេតោ-វិមុត្តឹ ។បេ។ និរុជ្ឈន្តិ** (និងរមែងមិនជ្រាបច្បាស់តាមសេចក្ដីពិត នូវចេ-តោវិមុត្តិ បញ្ញាវិមុត្តិ ដែលជាទីរលត់... ) បានដល់ នៅមិនទាន់បានសម្រេចព្រះអរហត្ត ។ ព្រះមានព្រះភាគ ត្រាស់ដល់ព្រះទីណាស្រព ដោយន័យទាំង ៥ ។

បទថា **អារភជា** (ដែលកើតពីសេចក្ដីប្រារព្ធ) បានដល់ កើតព្រោះកន្លងអាបត្តិ ។ បទថា **វិប្បដិសារជា** (ដែលកើតពីសេចក្ដីក្ដៅក្រហាយ) បានដល់ កើតអំពីសេចក្ដីក្ដៅក្រហាយ ។ បទថា **បវឌ្ឍន្តិ** (រមែងចម្រើនឡើង) បានដល់ ច្រើនឡើង ព្រោះកើតឡើងរឿយៗ ។ បទថា **អារភជេ អាសវេ បហាយ** (លះបង់នូវអាសវៈទាំងឡាយ ដែលកើតអំពីសេចក្ដីប្រារព្ធ) បានដល់ លះបង់នូវអាសវៈទាំងឡាយដែលកើតព្រោះកន្លងអាបត្តិ ដោយការសម្ដែងអាបត្តិ ឬដោយការចេញចាកអាបត្តិ ។ បទថា **បដិវិនោ-**

ទេត្វា (បន្ទោបង់) បានដល់ នាំចេញដោយការពិចារណាដល់ភាពជាអ្នកតាំងនៅក្នុងសេចក្តីបរិសុទ្ធ ។ បទថា ចិត្តំ បញ្ញញ្ច ភាវេតុ (ហើយចម្រើននូវចិត្ត និងបញ្ញាដោយល្អចុះ) បានដល់ ចូរបំពេញវិបស្សនាចិត្ត និងបញ្ញាដែលសម្បយុត្តដោយវិបស្សនាចិត្តនោះ ។ បទដ៏សេសគប្បីជ្រាបដោយសេចក្តីឧបមានោះឯង ។

ចប់អដ្ឋកថា អារភតិសូត្រទី ២

# អដ្ឋកថា សារន្ទទសូត្រទី ៣

*(ការប្រាកដនៃកែវដែលរកបានដោយក្រ ៥ ប្រការ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សារន្ទទសូត្រទី ៣ ដូចតទៅនេះ ៖*

[៤៣] *បទថា* **កាមាធិមុត្តានំ** *(ជាអ្នកប្រាថ្នាក្នុងកាម) បានដល់ បង្អោនទៅក្នុងវត្ថុកាម និងកិលេសកាម ។ បទថា* **ធម្មានុធម្មប្បដិបន្នោ** *(ប្រព្រឹត្តធម៌សមគួរដល់ធម៌) បានដល់ បុគ្គលដែលបដិបត្តិបដិបទាចំណែកខាងដើម ព្រមជាមួយសីល ហើយធ្វើវត្តបដិបត្តិឲ្យបរិបូណ៌ ដើម្បីបូរដល់លោកុត្តរៈធម៌ ៩ ឈ្មោះថា ជាបុគ្គលរកបានដោយកម្រក្នុងលោក ។*

ចប់អដ្ឋកថា សារន្ទទសូត្រទី ២

# អដ្ឋកថា តិកណ្ឌកីសូត្រទី ៤

## (វត្ថុបដិកូល និងមិនបដិកូល)

*គប្បីជ្រាបវិនិច្ឆ័យក្នុង តិកណ្ឌកីសូត្រទី ៤ ដូចតទៅនេះ ៖*

*[៤៤] បទថា **អប្បដិកូលេ** (មិនខ្ពើម) បានដល់ ក្នុងអារម្មណ៍ដែលមិនបដិកូល ។ បទថា **បដិកូលសញ្ញី** (ភិក្ខុគប្បីសំគាល់ថា គួរខ្ពើមក្នុងអារម្មណ៍ដែលមិនគួរខ្ពើម) បានដល់ មានសេចក្តីសម្គាល់យ៉ាងនេះថា នេះបដិកូល ។ ក្នុងបទទាំងពួងក៏ន័យនេះដូចគ្នា ។ សួរថា ក៏ភិក្ខុនេះបដិបត្តិយ៉ាងនេះ បានដូចម្តេច ។ ឆ្លើយថា ភិក្ខុបង្អោនទៅក្នុងវត្ថុដែលគួរប្រាថ្នា ថាមិនស្អាត ឬបង្អោនចូរទៅដោយភាពជារបស់មិនទៀង ឈ្មោះថា មានសចក្តីសម្គាល់ក្នុងវត្ថុមិនបដិកូលថា ជាវត្ថុបដិកូល ដោយអាការយ៉ាងនេះឯង ។ ភិក្ខុបង្អោនទៅក្នុងវត្ថុដែលមិនគួរប្រាថ្នាដោយមេត្តា ឬបង្អោនចូលទៅថាជាធាតុ ឈ្មោះថា មានសេចក្តីសម្គាល់ក្នុងវត្ថុបដិកូលថា មិនជាបដិកូល ដោយអាការយ៉ាងនេះ ។ ក៏ព្រះមានព្រះភាគត្រាស់ភាវៈទី ៣ និងភាវៈទី ៤ ដោយន័យខាងដើម និងខាងចុង ដោយវត្ថុទាំង*

២ (ទាំងបដិកូល និងមិនបដិកូល) ។ ព្រះដ៏មានព្រះភាគត្រាស់វារៈទី ៥ ដោយឆឡង្គុបេក្ខា ក៏ឆឡង្គុបេក្ខានេះ ស្រដៀងនឹងឧបេក្ខារបស់ព្រះខីណាស្រព តែមិនមែនឧបេក្ខារបស់ព្រះខីណាស្រព ។ ក្នុងបទទាំងនោះ បទថា **ឧបេក្ខកោ វិហរេយ្យ** (ដឹងខ្លួនតាំងនៅជាកណ្តាល) បានដល់ តាំងនៅដោយភាពជាកណ្តាល ។ បទថា **កូចិនិ** (ក្នុងអារម្មណ៍ណាៗ) បានដល់ ក្នុងអារម្មណ៍នោះៗ ។ បទថា **កត្ថចិ** (ក្នុងចំណែកណា) បានដល់ ក្នុងកន្លែងណាៗ ។ ក្នុងព្រះសូត្រនេះ ត្រាស់ចំពោះវិបស្សនាក្នុងឋានៈ ៥ យ៉ាង ដោយប្រការដូច្នេះ ។ ភិក្ខុរូបណាមួយអ្នកប្រារព្ធវិបស្សនា ក៏អាចបំពេញវិបស្សនានោះបាន សូម្បីសមណៈដែលជាពហូសូត្រ មានញាណ មានប្រាជ្ញាក្រៃលែងក៏អាចបំពេញបាន ។ ព្រះសោតាបន្ន ព្រះសកទាគាមិ ព្រះអនាគាមិ រមែងអាចធ្វើបានទាំងអស់ ។ មិនមានពាក្យដែលគប្បីពោលក្នុងព្រះខីណាស្រពទេ ។

ចប់អដ្ឋកថា តិកណ្ឌកីសូត្រទី ៤

# អដ្ឋកថា និរយសូត្រទី ៥

*(ធម៌ធ្វើឲ្យធ្លាក់នរក និងឡើងឋានសួគ៌)*

[៤៥] *និរយសូត្រទី ៥ មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា និរយសូត្រទី ៥

# អដ្ឋកថា មិត្តសូត្រទី ៦

*(ធម៌របស់ភិក្ខុដែលគួរសេពគប់ និងមិនគួរសេពគប់)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មិត្តសូត្រទី ៦ ដូចតទៅនេះ ៖*

[៤៦] *បទថា* ***កម្មន្តំ ការេតិ*** *(គឺភិក្ខុប្រើឲ្យធ្វើការងារ) បានដល់ ប្រើឲ្យធ្វើការងារ មានធ្វើស្រែជាដើម ។ បទថា* ***អធិករណំ អាទិយតិ*** *(បង្កអធិករណ៍) បានដល់ បង្កអធិករណ៍ ៤ យ៉ាង ។ បទថា* ***បាមោក្ខេសុ*** *(ជាសត្រូវក្នុងពួកភិក្ខុជាប្រធាន) បានដល់ ក្នុងពួកភិក្ខុជាទិសាបាមោក្ខៈ (ប្រធាន) ។ បទថា* ***បដិវិរុទ្ធោ ហោតិ*** *(ត្រាច់ទៅក្នុងទីឆ្ងាយៗ) បានដល់ ជាអ្នកនៅឆ្ងាយពីគ្នា ព្រោះប្រកាន់ថាជាសត្រូវ ។ បទថា* ***អនវត្ថានចារិកំ*** *(និងទីដែលមិនមានកំណត់) បានដល់ ត្រាច់ទៅមិនមានកំណត់ទី ។*

ចប់អដ្ឋកថា មិត្តសូត្រទី ៦

# អដ្ឋកថា អសប្បុរិសទានសូត្រទី ៧

## (ទានរបស់អសប្បុរស និងសប្បុរស)

គប្បីជ្រាបវិនិច្ឆ័យអសប្បុរិសទានសូត្រទី ៧ ដូចត ទៅនេះ៖

[៤៧] បទថា **អសក្កច្ចំ ទានំ ទេតិ**[១] (ឲ្យទានមិនគោរព) បានដល់ មិនបានធ្វើចិត្តឲ្យស្អាតក្នុងការឲ្យទាន ។ បទថា **អចិត្តីកត្វា ទេតិ** (ឲ្យទានដោយមិនមានសេចក្តីគោរព) បានដល់ ឲ្យដោយអាការមិនគោរព គឺ ខ្វះសេចក្តីគោរព ។ បទថា **អបវិទ្ធំ ទេតិ** (ឲ្យទានដូចបោះចោល) បានដល់ មិនឲ្យដោយដៃ ។ ន័យម្យ៉ាងទៀត ឲ្យដូចប្រាថ្នានឹងបោះចោល ។ បទថា **អនាគមនទិដ្ឋិកោ ទេតិ** (ឲ្យទានដោយឃើញថា មិនឲ្យផល) បានដល់ រមែងឲ្យដោយមិនសម្គាល់ឃើញថា ទានមានផលឲ្យកើតយ៉ាងនេះថា ផលនៃកម្មដែលធ្វើនឹងមកដល់ ។

ក្នុងចំណែកធម៌ស គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ។ បទថា **ចិត្តីកត្វា ទេតិ** (ឲ្យទានដោយគោរព) បានដល់ ចូលទៅតាំងសេចក្តីគោរព

---

(១) បិដក = អសក្កច្ចំ ទេតិ ។

ក្នុងទេយ្យធម៌ និងទក្ខិណេយ្យបុគ្គលហើយទើបឲ្យ ។ ក្នុងពីរបទនេះ បុគ្គលធ្វើទេយ្យធម៌ឲ្យប្រណីត មានរសជាតិឆ្ងាញ់ហើយទើបឲ្យ ឈ្មោះថា ចូលទៅតាំងទុកសេចក្តីគោរពក្នុងទេយ្យធម៌ ។ បុគ្គលជ្រើសរើសបុគ្គលហើយទើបឲ្យទាន ឈ្មោះថា ចូលទៅតម្កល់ទុកសេចក្តីគោរពក្នុងទក្ខិណេយ្យ-បុគ្គល ។ បទថា **សហត្ថា ទេតិ** (ឲ្យទានដោយដៃខ្លួនឯង) សេចក្តីថា មិនឲ្យអ្នកដទៃឲ្យជំនួស ឲ្យដោយដៃខ្លួនឯងប៉ុណ្ណោះ ដោយគិតថា វេលាដែលយើងមិនមានដៃ និងជើង ត្រាច់ទៅក្នុងសង្សារវដ្ត ដែលមិនដឹងខាងដើម និងខាងចុងត្រឹមណា ឈ្មោះថា ប្រមាណមិនបានឡើយ យើងនឹងធ្វើសង្សារវដ្តឲ្យអស់ទៅ គឺ ការរួចផុតចាកភព (ខណៈដែលយើងមានដៃ) ។ បទថា **អាគមនទិដ្ឋិកោ** (ឲ្យទានមិនដូចជាបោះចោល) បានដល់ជឿកម្ម និងផលថា នឹងជាបច្ច័យនៃភពក្នុងអនាគត ទើបឲ្យ ។

ចប់អដ្ឋកថា អសប្បុរិសទានសូត្រទី ៧

# អដ្ឋកថា សប្បុរិសទានសូត្រទី ៨

## (ទានរបស់សប្បុរស ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង សប្បុរិសទានសូត្រទី ៨ ដូចតទៅនេះ ៖

[៤៨] បទថា **សទ្ធាយ** (ដោយសទ្ធា) បានដល់ ជឿទាន និង ផលនៃទាន ។ បទថា **កាលេន** (តាមកាលគួរ) បានដល់ តាមកាល ដ៏សមគួរនឹងឲ្យទាន ។ បទថា **អនុគ្គហិតចិត្តោ** (ឲ្យទានដោយចិត្តអនុគ្រោះ) បានដល់ ឲ្យដោយចិត្តមិនស្តាយក្រោយ គឺ លះបង់ដាច់ហើយ ។ បទថា **អនុបហច្ច** (មិនបៀតបៀន) បានដល់ មិនចូលទៅបៀតបៀន គឺ មិនមើល ងាយគុណទាំងឡាយ (លុបបំបាត់គុណអ្នកដទៃ) ។ បទថា **កាលាគតា ចស្ស អត្ថា បរិបូរា ហោន្តិ** (ប្រយោជន៍ គឺ ភោគៈដ៏ពោរពេញ រមែង មកតាមកាលដ៏គួរដល់បុគ្គលនោះផង) សេចក្តីថា ប្រយោជន៍ទាំងឡាយ កាលនឹងមកដល់ មិនបានមកក្នុងកាលចម្រើនវ័យហើយ រមែងមកក្នុងវេលា ដែលគួរដ៏សមគួរក្នុងបឋមវ័យនុ៎ះឯង ទាំងច្រើនផង ។

ចប់អដ្ឋកថា សប្បុរិសទានសូត្រទី ៨

# អដ្ឋកថា បឋមសមយវិមុត្តសូត្រទី ៩

## (ធម៌ជាហេតុឲ្យវិនាស និងមិនឲ្យវិនាស)

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសមយវិមុត្តសូត្រទី ៩ ដូចតទៅនេះ ៖

[៤៩] បទថា *សមយវិមុត្តស្ស (ជាសមយវិមុត្ត)* សេចក្តីថា ភិក្ខុមានចិត្តផុតហើយដោយលោកិយវិមុត្ត គឺ រួចផុតដោយខណៈ ព្រោះផុតចាកកិលេសទាំងឡាយ ដែលគ្របសង្កត់ទុកបាន ក្នុងខណៈដែលចិត្តនៅក្នុងអប្បនានោះឯង ។

ចប់អដ្ឋកថា បឋមសមយវិមុត្តសូត្រទី ៩

# អដ្ឋកថា ទុតិយសមយវិមុត្តសូត្រទី ១០

*(ធម៌ជាហេតុឲ្យវិនាស និងមិនឲ្យវិនាស)*

[៥០] *ក្នុងសូត្រទី ១០ នេះ សេចក្ដីងាយយល់ទាំងអស់ ។*

ចប់អដ្ឋកថា ទុតិយសមយវិមុត្តសូត្រទី ១០

## ចប់តិកណ្ណកីវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៨ សូត្រ

# ចតុត្ថបណ្ណាសកៈ

## សទ្ធម្មវគ្គវណ្ណនាទី ១

## អដ្ឋកថា បឋមសទ្ធម្មនិយាមសូត្រទី ១

*(ធម៌របស់អ្នកចូលដល់កុសល និងមិនចូលដល់កុសល)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសទ្ធម្មនិយាមសូត្រទី ១ ដូចតទៅនេះ ៖*

[៥១] *បទថា* **អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ** *(សូម្បីស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម គឺ មគ្គជាសភាពដ៏ប្រពៃក្នុងកុសលធម៌ទាំងឡាយបាន) សេចក្តីថា កិច្ចមិនគួរដើម្បីឈានចុះកាន់មគ្គនិយាម ដែលត្រឹមត្រូវក្នុងកុសលធម៌ទាំងឡាយ ។ ក្នុងបទថា* **កថំ បរិភោតិ** *(បុគ្គលមើលងាយពាក្យពោល) ជាដើម កាលពោលថា រឿងនេះឈ្មោះថា រឿងអ្វី ឈ្មោះថា រមែងមើលងាយពាក្យពោល ។ បទថា* **កថិកំ បរិភោតិ** *(មើលងាយបុគ្គលអ្នកពោល) បានដល់ កាលពោលថា បុគ្គលនោះនិយាយរឿងអ្វី បុគ្គលនេះនឹងនិយាយរឿងអ្វី ដូច្នេះ ឈ្មោះថា មើលងាយបុគ្គលអ្នកពោល ។* **អត្តានំ បរិភោតិ** *(មើលងាយ*

ខ្លួនឯង) សេចក្តីថា កាលពោលថា យើងនឹងស្តាប់រឿងនេះរបស់យើងបាន ដូចម្តេច ដូច្នេះ ឈ្មោះថា មើលងាយខ្លួនឯង ។ គប្បីជ្រាបធម៌ចំណែកស ដោយន័យផ្ទុយគ្នានេះឯង ។

ចប់អដ្ឋកថា បឋមសទ្ធម្មនិយាមសូត្រទី ១

# អដ្ឋកថា ទុតិយសទ្ធម្មនិយាមសូត្រទី ២

*(ធម៌របស់អ្នកចូលដល់កុសល និងមិនចូលដល់កុសល)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសទ្ធម្មនិយាមសូត្រទី ២ ដូចតទៅនេះ ៖*

*[៥២] បទថា អនញ្ញាតេ អញ្ញាតមានី (អ័ប្បឥតប្រាជ្ញាល្ងង់ខ្លៅ លលា បានដឹងក្នុងហេតុដែលខ្លួនមិនដឹង) បានដល់ ជាអ្នកដឹងខ្លួនក្នុងវត្ថុ ដែលខ្លួនមិនទាន់ដឹងច្បាស់ យ៉ាងនេះថា វត្ថុនេះយើងដឹងច្បាស់ហើយ ។*

ចប់អដ្ឋកថា ទុតិយសទ្ធម្មនិយាមសូត្រទី ២

# អដ្ឋកថា តតិយសទ្ធម្មនិយាមសូត្រទី ៣

*(ធម៌របស់អ្នកចូលដល់កុសល និងមិនចូលដល់កុសល)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយសទ្ធម្មនិយាមសូត្រទី ៣ ដូចតទៅនេះ ៖*

*[៥៣] បទថា* **មក្ខី ធម្មំ សុណាតិ** *(គឺជាអ្នកលុបគុណគេ ហើយស្តាប់ធម៌) បានដល់ ជាអ្នកមើលងាយគេហើយ ស្តាប់ដោយចិត្តលុបគុណគេ ។ បទថា* **សឧបារម្ភចិត្តោ** *(ជាអ្នកមានចិត្តសង្កត់សង្កិន) បានដល់ គឺ មានចិត្តលើកឡើងដើម្បីសង្កត់សង្កិន ។ បទថា* **រន្ធគវេសី** *(ស្វែងរកទោស) បានដល់ គឺ ចាំចាប់កំហុសក្នុងអ្នកមានគុណ ។*

ចប់អដ្ឋកថា តតិយសទ្ធម្មនិយាមសូត្រទី ៣

# អដ្ឋកថា បឋមសទ្ធម្មសម្មោសសូត្រទី ៤

*(ហេតុវិនាស និងហេតុចម្រើននៃសាសនា)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសទ្ធម្មសម្មោសសូត្រទី ៤ ដូចតទៅនេះ ៖*

*[៥៤] បទថា ន សក្កច្ចំ ធម្មំ សុណន្តិ (មិនស្តាប់ធម៌ដោយគោរព) បានដល់ មិនផ្ទៀងត្រចៀកតាំងចិត្តស្តាប់ធម៌ ។ បទថា ន សក្កច្ចំ ធម្មំ បរិយាបុណន្តិ[១] (មិនរៀនធម៌ដោយគោរព) បានដល់ សូម្បីកាលនឹងបដិបត្តិធម៌តាមដែលស្តាប់មក ក៏មិនបដិបត្តិដោយគោរព ។*

ចប់អដ្ឋកថា បឋមសទ្ធម្មសម្មោសសូត្រទី ៤

(១) អដ្ឋកថា = ន បរិយាបុណន្តិ ។

# អដ្ឋកថា ទុតិយសទ្ធម្មសម្មោសសូត្រទី ៥

*(ហេតុវិនាស និងហេតុមិនវិនាសនៃសាសនា)*

[៥៥] *ក្នុងសូត្រទទី ៥ ងាយយល់ទាំងអស់នោះឯង ។*

ចប់អដ្ឋកថា ទុតិយសទ្ធម្មសម្មោសសូត្រទី ៥

# អដ្ឋកថា តតិយសទ្ធម្មសម្មោសសូត្រទី ៦

*(ហេតុវិនាស និងហេតុមិនវិនាសនៃសាសនា)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង តតិយសទ្ធម្មសម្មោសសូត្រទី ៦ ដូចតទៅនេះ ៖*

*[៥៦] បទថា **អប្បដិសរណោ** (មិនប្រតិស្ឋានទៅ) បានដល់ មិនមានទីពឹងអាស្រ័យ ។ ពិតណាស់ អាចារ្យទាំងឡាយ ឈ្មោះថា ជាទីពំនាក់នៃព្រះសូត្រ ព្រោះមិនមានអាចារ្យទាំងនោះ ព្រះសូត្រក៏មិនមានទីអាស្រ័យ ។ បទដ៏សេសក្នុងសូត្រនេះ មានសេចក្តីដូចដែលពោលមកហើយនុះឯង ។*

ចប់អដ្ឋកថា តតិយសទ្ធម្មសម្មោសសូត្រទី ៦

# អដ្ឋកថា ឧក្កាចាសូត្រទី ៧

*(ពោលល្អទៅជាអាក្រក់ និងពោលល្អកាន់តែល្អ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧក្កាចាសូត្រទី ៧ ដូចតទៅនេះ ៖*

*[៥៧] បទថា **បុគ្គលំ ឧបនិធាយ** (ដោយលើកយកបុគ្គលទៅប្រៀប) សេចក្តីថា អាងដល់បុគ្គលនោះ ៗ ហើយឲ្យធ្វើជាសាក្សី ។ បទថា **កច្ចមានាយ** (កាលបើពោល) បានដល់ កាលពោល ។ បទដ៏សេសក្នុងសូត្រនេះមានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា ឧក្កាចាសូត្រទី ៧

# អដ្ឋកថា សារជ្ជសូត្រទី ៨

## (ធម៌ធ្វើឲ្យញាញើតញាញើម និងក្លាហាន)

[៥៨] *សារជ្ជសូត្រទី ៨ ងាយយល់ហើយ ។*

ចប់អដ្ឋកថា សារជ្ជសូត្រទី ៨

# អដ្ឋកថា ឧទាយិសូត្រទី ៩

*(អដ្ឋរបស់ព្រះធម្មកបិក)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧទាយិសូត្រទី ៩ ដូចតទៅនេះ ៖*

*[៥៩] បទថា **អនុបុព្វិកថំ កថេស្សាមីតិ** (អាត្មាអញនឹងសម្ដែងនូវអនុបុព្វីកថា) សេចក្ដីថា គប្បីតាំងចិត្តថា អញនឹងសម្ដែងអនុបុព្វីកថាយ៉ាងនេះ គឺ សីលក្នុងលំដាប់ទាន សួគ៌ក្នុងលំដាប់សីល ឬគប្បីតាំងចិត្តថា យើងនឹងពោលកថាដែលសមគួរដល់បទព្រះសូត្រ ឬបទគាថា ដែលបានរៀនមកហើយ ដូច្នេះ ហើយទើបសម្ដែងធម៌ដល់អ្នកដទៃ ។ បទថា **បរិយាយទស្សាវី** (ដោយអាងហេតុផល) បានដល់ សម្ដែងដល់ហេតុនោះៗនៃខ្លឹមសារនោះៗ ។ ពិតណាស់ ក្នុងសូត្រនេះត្រាស់ ហេតុថា **បរិយាយ** ។ បទថា **អនុទយតំ បដិច្ច** (អាស្រ័យសេចក្ដីអាណិត) បានដល់ អាស្រ័យសេចក្ដីអាណិតថា យើងនឹងដោះទុក្ខសត្វទាំងឡាយដែលដល់សេចក្ដីលំបាកចេញពីសេចក្ដីលំបាក ។ បទថា **ន អាមិសន្តរោ កថំ កថេស្សាមីតិ** (អាត្មាអញនឹងមិនសម្ដែងធម៌ ព្រោះហេតុនៃអាមិស) បានដល់ មិនជាអ្នក*

មានអាមិសជាហេតុ អធិប្បាយថា មិនប្រាថ្នាលាភ គឺ បច្ច័យ ៤ ដើម្បីខ្លួន ។ បទថា អត្តានញ្ច បរញ្ច អនុបហញ្ច កថំ កថេស្សាមីតិ (អាត្មាអញនឹងសម្តែងដោយមិនបៀតបៀនខ្លួនឯង និងបុគ្គលដទៃ) បានដល់ មិនបៀតបៀនខ្លួនឯង និងអ្នកដទៃ ដោយការបៀតបៀនគុណ (គឺសេចក្តីល្អរបស់អ្នកដទៃ) ដោយលើកខ្លួនឯង សង្កត់សង្កិនអ្នកដទៃជាដើម ។

ចប់អដ្ឋកថា ឧទាយិសូត្រទី ៩

# អដ្ឋកថា ទុប្បដិវិនោទយសូត្រទី ១០[១]

## (ធម៌បន្ទោបង់បានលំបាក)

គប្បីជ្រាបវិនិច្ឆ័យក្នុង ទុប្បដិវិនោទយសូត្រទី ១០ ដូចតទៅនេះ ៖

[៦០] បទថា *ទុប្បដិវិនោទយា* (កើតឡើងហើយបន្ទោបង់បានដោយកម្រ) សេចក្តីថា ឋានៈណា រមែងមានដើម្បីញុំាងកិច្ច មានការរីករាយជាដើមឲ្យកើតឡើង កាលឋានៈទាំងនោះនៅមិនទាន់ដល់ទីបំផុត (សម្រេច) រមែងនាំចេញបានដោយលំបាក នាំចេញបានដោយក្រ ក្នុងរវាងនៃការប្រព្រឹត្តទៅ ។ ភាពជាអ្នកប្រាថ្នានឹងពោល ហៅថា **បដិភាណំ** (បដិភាណ) ។ ធម៌ ៥ យ៉ាងនេះ រម្ងាប់បានដោយលំបាក មិនមែនរម្ងាប់បានដោយងាយ តែអាចរម្ងាប់បាន ដោយបច្ចវេក្ខណៈ (ការពិចារណា) និងអនុសាសនៈ (ការប្រៀនប្រដៅ) ជាដើម សមគួរដោយឧបាយ ដោយហេតុ ។

ចប់អដ្ឋកថា ទុប្បដិវិនោទយសូត្រទី ១០

### ចប់សទ្ធម្មវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៨ សូត្រ

---

(១) អដ្ឋកថា = ទុព្វិនោទយសូត្រ ។

# អាឃាតវគ្គវណ្ណនាទី ២

## អដ្ឋកថា បឋមអាឃាតវិនយសូត្រទី ១

*(ធម៌រម្ងាប់សេចក្ដីអាឃាត ៥ យ៉ាង)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអាឃាតវិនយសូត្រទី ១ ដូចតទៅនេះ ៖*

*[៦១] បទថា **អាឃាតប្បដិវិនយា** (ធម៌សម្រាប់រម្ងាប់អាឃាត) បានដល់ ព្រោះអត្ថថា រម្ងាប់ គឺ ស្ងប់រម្ងាប់សេចក្ដីអាឃាត ។ បទថា **យត្ថ ភិក្ខុនោ ឧប្បន្នោ អាឃាតោ សព្វសោ បដិវិនេតព្វោ** (គំនុំកើតឡើង ភិក្ខុត្រូវកម្ចាត់បង់ដោយសព្វគ្រប់ ព្រោះអាឃាតប្បដិវិន័យណា) សេចក្ដីថា អាឃាតកើតឡើងដល់ភិក្ខុក្នុងអារម្មណ៍ណា គប្បីរម្ងាប់អាឃាតទាំងអស់នោះ ក្នុងអារម្មណ៍នោះ ដោយធម៌រម្ងាប់សេចក្ដីអាឃាតទាំង ៥ ប្រការនេះ ។ បទថា **មេត្តា តស្មឹ បុគ្គលេ ភាវេតព្វា** (ភិក្ខុត្រូវចម្រើនមេត្តាចិត្តចំពោះបុគ្គលនោះ) សេចក្ដីថា គប្បីចម្រើន មេត្តាចិត្តដោយតិកឈាន (តតិយជ្ឈាន) (បឋមជ្ឈាន-តតិយជ្ឈាន ដោយចតុក្កន័យ) និងចតុត្ថជ្ឈាន (បឋមឈាន-ចតុត្ថជ្ឈាន ដោយបញ្ចកន័យ) សូម្បីក្នុងករុណា*

ក៏ន័យនេះដូចគ្នា ។ តែឧបេក្ខា គួរចម្រើនដោយចតុត្ថជ្ឈាន (ចតុត្ថជ្ឈាន ពោលដោយចំណែកចតុក្កន័យ) និងបញ្ចមជ្ឈាន (បញ្ចមជ្ឈានពោលដោយ បញ្ចកន័យ) ក៏ព្រោះកាលឃើញបុគ្គលណា ចិត្តអាឃាតនៅមិនទាន់រម្ងាប់ មុទិតា រមែងមិនប្រាកដក្នុងបុគ្គលនោះ ដូច្នោះ ទើបមិនពោលដល់មុទិតា ។ បទថា *អសតិមនសិការោ* (ភិក្ខុត្រូវប្រតិបត្តិនូវការមិនធ្វើទុកក្នុងចិត្ត) បានដល់ មិនត្រូវនឹកដល់ហើយ ដាក់ចិត្តទៅក្នុងបុគ្គលនោះ ដោយអាការ ដែលបុគ្គលនោះមិនប្រាកដ ដូចជាយកជញ្ជាំងជាដើម បាំងទុក ដូច្នោះ ។

ចប់អដ្ឋកថា អាឃាតវិនយសូត្រទី ១

# អដ្ឋកថា ទុតិយអាឃាតវិនយសូត្រទី ២

## (ធម៌រម្ងាប់សេចក្តីអាឃាត ៥ យ៉ាង)

គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអាឃាតវិនយសូត្រទី ២ ដូចតទៅនេះ ៖

[៦២] បទថា *អាឃាតប្បដិវិនយា* (អាឃាតប្បដិវិន័យ) បានដល់ ព្រោះគួររម្ងាប់អាឃាតក្នុងបុគ្គលទាំង ៥ នោះខ្លះ ព្រោះគួររម្ងាប់អាឃាត ដោយធម៌ទាំង ៥ នោះខ្លះ ។ ពិតណាស់ បទថា **បដិវិនយា** នេះ ជាឈ្មោះរបស់វត្ថុដែលគួររម្ងាប់ខ្លះ ហេតុដែលគួររម្ងាប់ខ្លះ ។ សូម្បីទាំងពីរយ៉ាងនោះ ក៏គួរក្នុងទីនេះ ។ ក៏បុគ្គលទាំងឡាយ ៥ ជាវត្ថុដែលគួររម្ងាប់ វត្តបដិបត្តិ ៥ ដោយឧបមា ៥ ប្រការ ជាហេតុដែលគួររម្ងាប់ ។ បទថា **លភតិ ច កាលេន កាលំ ចេតសោ វិវរំ ចេតសោ បសាទំ** (ទាំងបានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលម្តងៗ) សេចក្តីថា រមែងឃើញផ្លូវ ពោលគឺ ឱកាសនៃចិត្តដែលជាសមថៈ និងវិបស្សនាកើតឡើងបាន និងសេចក្តីផូរផង់ ពោលគឺ សេចក្តីផូរផង់នៃចិត្តដោយសទ្ធាក្នុងជួរខណៈនៃចិត្ត ។

បទថា *រថិយាយ* (ច្រកផ្លូវ) បានដល់ ក្នុងចន្លោះផ្លូវ ។ បទថា *នន្តកំ* (ផែនសំពត់) បានដល់ ផ្ទាំងសំពត់ចាស់ ។ បទថា *និគ្គណ្ហិត្វា* (ហែកសំពត់យក) បានដល់ ជាន់ហើយ ។ បទថា *យោ តត្ថ សារោ* (ត្រង់កន្លែងដែលមានសាច់ជាប់) បានដល់ ចំណែកណាក្នុងផ្ទាំងសំពត់ដែលមានសាច់ជាប់ ។ បទថា *តំ បរិបាចេត្វា* (រូចកាន់យកដើរចៀសចេញទៅ) បានដល់ ហែកយកចំណែកនោះ ។ ក្នុងបទឧបមេយ្យថា *ឯវមេវ ខោ* នេះ គប្បីឃើញថា អ្នកនៅដោយមេត្តា ដូចភិក្ខុកាលកាន់យកសំពត់បង្សុកូលជាវត្ត , បុគ្គលអ្នកមានពៀរ ដូចសំពត់ចាស់ត្រង់ច្រកផ្លូវ , ការប្រព្រឹត្តតាមផ្លូវកាយដែលមិនបរិសុទ្ធ ដូចផ្ទាំងសំពត់ហែក , ការប្រព្រឹត្តតាមផ្លូវវាចាដែលបរិសុទ្ធ ដូចកំណាត់សំពត់ល្អ គប្បីឃើញថា វេលាដែលមិនធ្វើទុកក្នុងចិត្តដល់អ្នកមានការប្រព្រឹត្តតាមផ្លូវកាយមិនបរិសុទ្ធ ធ្វើទុកក្នុងចិត្តដល់អ្នកមានការប្រព្រឹត្តតាមផ្លូវវាចាបរិសុទ្ធ រំលត់ចិត្តប្បាទក្នុងបុគ្គលដែលជាសត្រូវនឹងគ្នា ហើយនៅជាសុខ ដូចវេលាដែលចោលកំណាត់សំពត់រហែក កាន់យកកំណាត់សំពត់ល្អ ដេរ ជ្រលក់ ហើយដណ្តប់ចារិកទៅ ។

បទថា **សេវាលបណកបរិយោនទ្ធា** (ពាសពេញដោយសារាយ និងចក) បានដល់ សារាយ និងចកដុះពាសពេញ ។ បទថា **ឃម្មបរេតោ**[១] (ត្រូវកំដៅថ្ងៃគ្របសង្កត់) បានដល់ ត្រូវសេចក្ដីក្ដៅគ្របសង្កត់ ។ បទថា **កិលន្តោ** (នឿយហត់) បានដល់ ដើរផ្លូវនឿយហត់ ។ បទថា **តសិតោ** (អន្ទះអន្ទែង) បានដល់ ត្រូវសេចក្ដីលំបាកគ្របសង្កត់ ។ បទថា **បិបាសិតោ** (ស្រេក) បានដល់ បំណងនឹងផឹកទឹក ។ បទថា **អបវិយូហិត្វា** (វែកសារាយ និងចក) បានដល់ វែកចេញ ។ បទថា **បិវិត្វា** (ក្បង់ទឹក) បានដល់ ក្បង់ទឹកថ្លាផឹក ។ ក្នុងបទថា **ឯវមេវ ខោ** (យ៉ាងណាមិញ) នេះ គប្បីជ្រាបថា ភិក្ខុអ្នកទូន្មានដោយមេត្តា ដូចបុរសអស់កម្លាំងព្រោះត្រូវសេចក្ដីក្ដៅក្រហាយដុតរោល ការប្រព្រឹត្តផ្លូវវាចាមិនបរិសុទ្ធ ដូចសារាយ និងចក ការប្រព្រឹត្តផ្លូវកាយដ៏បរិសុទ្ធ ដូចទឹកថ្លា វេលាដែល មិនធ្វើទុកក្នុងចិត្តដល់ការប្រព្រឹត្តផ្លូវវាចាដែលមិនបរិសុទ្ធ ហើយធ្វើទុកក្នុងចិត្តដល់ការប្រព្រឹត្តផ្លូវកាយដ៏បរិសុទ្ធ រំលត់ចិត្តប្បាទក្នុងបុគ្គលដែល មានពៀរនឹង

---

(១) អដ្ឋកថា = ឃម្មបរេតោ (ញើសហូរព្រោះក្ដៅ) ។

គ្នា ហើយនៅជាសុខ ដូចបុរសវែកសារាយ និងចក ហើយផឹកទឹកថ្លាដើរចេញទៅ ។

បទថា **ខោភិស្សាមិ (ឲ្យកម្រើក)** បានដល់ ធ្វើឲ្យរញ្ជួយ ។ បទថា **លោឡិស្សាមិ (ធ្វើឲ្យល្អក់)** គឺ ធ្វើឲ្យល្អក់ ។ បទថា **អបេយ្យម្បិ តំ ករិស្សាមិ (ទាំងធ្វើទឹកនោះឲ្យជាទឹកផឹកមិនបានផង)** និងធ្វើឲ្យមិនអាចនឹងផឹកបាន ។ បទថា **ចតុក្កុណ្ឌិកោ (លុតជង្គង់)** បានដល់ ជាអ្នកលុតជង្គង់ដោយយកជង្គង់ទាំងពីរ និងដៃទាំងពីរដាក់លើផែនដី ។ បទថា **គោបីតកំ (ឱនផឹកដូចជាគោ)** បានដល់ ជាអ្នកឱនចុះផឹកនូវទឹកជាដូចគោ ។ បទថា ក្នុងពាក្យឧបមេយ្យថា **ឯវមេវ ខោ (ដូច្នោះ)** នេះ គប្បីជ្រាបថា ភិក្ខុអ្នកនៅដោយមេត្តា ដូចបុរសអស់កម្លាំង ព្រោះត្រូវសេចក្តីក្តៅដុតរោល អ្នកមានពៀរនឹងគ្នា ដូចស្នាមជើងគោ គប្បីជ្រាបថា ការដែលភិក្ខុនោះមិនជ្រះថ្លាដល់ការប្រព្រឹត្តផ្លូវកាយ និងប្រព្រឹត្តតាមផ្លូវវាចាដែលមិនបរិសុទ្ធ ហើយធ្វើទុកក្នុងចិត្តដល់ការបានបីតិបាមោជ្ជៈ ដែលជាសេចក្តីផូរផង់នៃចិត្ត ព្រោះអាស្រ័យការស្តាប់ធម៌តាមកាលដ៏គួរ ហើយញុំាងចិត្តឲ្យជ្រះថ្លាឲ្យរលត់ទៅ គប្បី

ឃើញដូចបុរសលុតជង្គង់ចុះ ផឹកទឹកដូចជាគោ ហើយចៀសចេញទៅ ។

បទថា **អាពាធិកោ (មានអាពាធ)** បានដល់ ឈឺចុកចាប់ដោយរោគទាស់ដែលទម្លាយដល់ឥរិយាបថ ។ **បុរតោបិស្ស (សូម្បីខាងមុខ... ក៏មាន)** បានដល់ គប្បីមាននៅខាងមុខ ។ បទថា **អនយព្យសនំ (ដល់នូវសេចក្ដីវិនាស)** បានដល់ សេចក្ដីមិនចម្រើន គឺ សេចក្ដីវិនាស ។ ក្នុងបទឧបមេយ្យថា **ឯវមេវ ខោ (ដូច្នោះ)** នេះ គប្បីជ្រាបថា បុគ្គលដែលប្រកបដោយធម៌ចំណែកខ្មៅទាំងអស់ ដូចជាបុគ្គលឈឺអនាថា សង្សារដែលរកទីបំផុតខាងដើមមិនបាន ដូចផ្លូវឆ្ងាយ និព្វាននៅឆ្ងាយ ដូចស្រុកឆ្ងាយទាំងខាងមុខ និងខាងក្រោយ ការមិនបានភោជនៈ គឺ សាមញ្ញផល ដូចការមិនបានភោជនៈដែលជាទីសប្បាយ ភាពមិនមានសមថៈ និងវិបស្សនា ដូចការដែលមិនបានភេសជ្ជៈដែលជាទីសប្បាយ ការមិនមានអ្នកព្យាបាលកិលេសដោយឱវាទានុសាសនី ដូចការមិនបានឧបដ្ឋាកដ៏សមគួរ ការមិនបានព្រះតថាគត ឬសាវករបស់ព្រះតថាគត អ្នកធ្វើឲ្យសម្រេចដល់និព្វាន ដូចការមិនបានអ្នកនាំផ្លូវទៅឲ្យដល់ទីស្រុក ភិក្ខុអ្នកនៅដោយមេត្តា ធ្វើករុណាឲ្យ

កើតក្នុងបុគ្គលនោះ ហើយធ្វើចិត្តអាឃាតឲ្យរលត់ទៅ ដូចជាបុរសណាមួយ ឃើញអ្នកជំងឺអនាថា ហើយបម្រើដោយសេចក្តីករុណា ។

បទថា **អច្ឆោទកា** (ទីមានទឹកថ្លា) បានដល់ ទីដែលមានទឹកថ្លាឈ្វេង ។ បទថា **សាតោទកា** (ឆ្ងាញ់) គឺ មានរសឆ្ងាញ់ ។ បទថា **សីតោទកា** (ត្រជាក់) បានដល់ មានទឹកត្រជាក់តិចៗ ។ បទថា **សេ-តោទកា** (ស) បានដល់ មានពណ៌សក្នុងទីដែលមានទឹករលក ។ បទថា **សុប្បតិដ្ឋា** (មានកំពង់រាបល្អ) បានដល់ គឺមានកំពង់រាបស្មើ ។ ក្នុងបទឧបមេយ្យថា **ឯវមេវ ខោ** (ដូច្នោះ) នេះ គប្បីជ្រាបថា ភិក្ខុអ្នកនៅដោយមេត្តា ដូចបុរសអស់កម្លាំងព្រោះត្រូវសេចក្តីក្តៅរោល បុរសអ្នកមានទ្វារបរិសុទ្ធ ដូចស្រះបោក្ខរណីនោះ ការដែលភិក្ខុប្រាថ្នាទ្វារណាក៏ធ្វើទ្វារនោះឲ្យជាអារម្មណ៍ ហើយធ្វើចិត្តអាឃាតឲ្យរលត់ ដូចកាលបុរសងូត ផឹក និងឡើងអំពីទឹក ដេកក្រោមម្លប់ដើមឈើទៅតាមសេចក្តីត្រូវការ ។

ចប់អដ្ឋកថា អាឃាតវិនយសូត្រទី ២

# អដ្ឋកថា សារកច្ឆាសូត្រទី ៣

*(គុណសម្បត្តិរបស់អ្នកគួរសន្ទនា)*

[៦៣] *សូត្រទី ៣ មានន័យតាមដែលពោលហើយនោះឯង ។*

ចប់អដ្ឋកថា សារកច្ឆាសូត្រទី ៣

# អដ្ឋកថា សាជីវសូត្រទី ៤

*(គុណសម្បត្តិរបស់អ្នកគួរនៅរួមគ្នា)*

[៦៤] *សូត្រទី ៤ ក៏មានន័យតាមដែលពោលហើយនោះឯង ។*

ចប់អដ្ឋកថា សាជីវសូត្រទី ៤

# អដ្ឋកថា បញ្ហាបុច្ឆាសូត្រទី ៥

## (ហេតុនៃការសួរបញ្ហា)

គប្បីជ្រាបវិនិច្ឆ័យក្នុង បញ្ហាបុច្ឆាសូត្រទី ៥ ដូចតទៅនេះ ៖

[៦៥] បទថា *បរិករំ* (មើលងាយ) បានដល់ មើលងាយ អធិប្បាយថា សួរដើម្បីនឹងសង្កត់សង្កិន ដោយគិតថា យើងនឹងសង្កត់សង្កិនយ៉ាងនេះ ដូច្នេះ ។ បទថា *ញាតុកាមោ*[១] (បំណងនឹងដឹង) បានដល់ ជាអ្នកប្រាថ្នានឹងដឹង ។

ចប់អដ្ឋកថា បញ្ហាបុច្ឆាសូត្រទី ៥

(១) បិដក = អញ្ញាតុកាមោ បរំ បញ្ហំ បុច្ឆតិ (មិនចង់ដឹង ហើយសួរប្រស្នា) ។

# អដ្ឋកថា និរោធសូត្រទី ៦

*(អ្នកចូល និងចេញចាកសញ្ញាវេទយិតនិរោធ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និរោធសូត្រទី ៦ ដូចតទៅនេះ ៖*

*[៦៦] បទថា **អត្ថេតំ ឋានំ** (ហេតុនោះតែងតែមាន) បានដល់ហេតុនោះមាន ។ បទថា **នោ ច ទិដ្ឋេវ ធម្មេ អញ្ញំ អារាធេយ្យ** (បើមិនបានសម្រេចអរហត្តផលក្នុងបច្ចុប្បន្នទេ) សេចក្តីថា ប្រសិនបើលោកមិនបានសម្រេចអរហត្តក្នុងអត្តភាពនេះទេ ។ បទថា **កវឡិង្ការាហារភក្ខានំ ទេវានំ** (ពួកទេវតាមានកវឡិង្ការាហារជាអាហារ) បានដល់ ពួកទេវតាជាន់កាមាវចរៈ ។ បទថា **អញ្ញតរំ មនោមយំ កាយំ** (ពួកទេវតាដែលសម្រេចដោយចិត្តណាមួយ) បានដល់ ពួកព្រហ្មជាន់សុទ្ធាវាសណាមួយដែលកើតឡើងដោយឈានចិត្ត ។*

*បទថា **ឧទាយិ** បានដល់ ព្រះលោឡុទាយិ ។ ព្រះលោឡុទាយិនោះ បានស្តាប់ថា **មនោមយំ** (អ្នកកើតដោយចិត្ត) ទើបជំទាស់ដោយគិតថា ពួកទេវតាដែលកើតដោយចិត្តគប្បីជាអរូប ។ ព្រះថេរៈមិនឈប់ពាក្យ*

ពោលត្រឹមតែប៉ុណ្ណោះ ដើម្បីការពារការកើតឡើងនៃការយល់ឃើញរបស់ពួកបុគ្គលពាលយ៉ាងនេះថា ព្រះសារីបុត្រនឹងដឹងអ្វី នៅចំពោះមុខរបស់លោក ពួកភិក្ខុនៅជំទាស់នឹងពាក្យយ៉ាងនេះ ទើបចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។ បទថា **អត្ថិ នាម (ប្រព្រឹត្តទៅបានហ្ន៎)** ជានិបាតចុះក្នុងអត្ថថា បង្ហាញឲ្យមើល ។ ព្រោះហេតុនុ៎ះឯង បទថា **អជ្ឈុបេក្ខិស្សថ (ព្រងើយកន្តើយ)** ក្នុងទីនេះ ទើបទ្រង់ធ្វើឲ្យជាស័ព្ទអនាគតកាល ។ ក្នុងប្រការនេះ មានសេចក្តីដូចតទៅនេះថា ម្នាលអានន្ទ ពួកអ្នករមែងព្រងើយកន្តើយចំពោះភិក្ខុជាថេរៈដែលត្រូវគេបៀតបៀន តថាគតនឹងមិនទ្រាំចំពោះពួកអ្នក មិនអត់ធន់ មិនអត់ទ្រាំទៀតឡើយ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ចំពោះព្រះអានន្ទថេរៈប៉ុណ្ណោះ ។ ឆ្លើយថា ព្រោះលោកជាឃ្លាំងធម៌ ។ ពិតហើយ ព្រះឧទាយិកាលពោលយ៉ាងនេះ ទើបជាភារៈរបស់លោកដែលជាឃ្លាំងធម៌ សមគួរនឹងហាមឃាត់បាន ។ ម្យ៉ាងទៀត ព្រះអានន្ទត្ថេរៈក៏ជាបិយមិត្តរបស់ព្រះសារីបុត្តត្ថេរៈ ព្រោះហេតុនោះ ព្រះសារីបុត្តត្ថេរៈ ទើបជាភារៈរបស់ព្រះអានន្ទត្ថេរៈ ។ ក្នុង

ប្រការនោះ សូម្បីព្រះមានព្រះភាគ កាលទ្រង់តិះដៀលព្រះអានន្ទត្ថេរៈ ទើបត្រាស់យ៉ាងនេះក៏ពិត តែក៏គប្បីជ្រាបថា មិនមែនតិះដៀលត្រឹមតែព្រះអានន្ទប៉ុណ្ណោះទេ ក៏ជាការតិះដៀលដល់ពួកភិក្ខុទាំងអស់ដែលនូវចំពោះព្រះភ័ក្ត្រនុ៎ះឯង ។

បទថា ***វិហារំ (វិហារ)*** បានដល់ ព្រះគន្ធកុដិ ។ បទថា ***អនច្ឆរិយំ (មិនគួរប្លែកចិត្ត)*** បានដល់ មិនគួរអស្ចារ្យ ។ បទថា ***យថា (ដោយប្រការដែល)*** ជាពាក្យសម្តែងហេតុ ។ បទថា ***អាយស្មន្តញ្ញេវេត្ថ ឧបវានំ បដិកាសេយ្យ (គប្បីត្រាស់នឹងព្រះឧបវានៈដោយចំពោះក្នុងហេតុនោះ)*** នេះ ព្រះអានន្ទត្ថេរៈបំភ្លឺថា កាលព្រះមានភាគទ្រង់ប្រារព្ធហេតុនេះ ទ្រង់លើកយករឿងនេះមកអាងហើយ ពាក្យឆ្លើយចូរជាក់ច្បាស់ដល់ភិក្ខុឧបវានៈចុះ ។ បទថា ***សារជ្ជំ ឱក្កន្តំ (ការមិនសប្បាយចិត្តបានកើតឡើង)*** បានដល់ ចិត្តប្រកបដោយទោមនស្ស ។ ព្រះឧបវានៈពោលដល់សីលរបស់ព្រះខីណាស្រពជាដើម ដោយពាក្យមានជាអាទិ៍ថា ***សីលវា (អ្នកមានសីល)*** ។ បទថា ***ខណ្ឌិច្ចេន (ជាអ្នកមានធ្មេញបាក់)*** ជាដើម ព្រះឧបវានៈពោលដោយសួរ

ដល់ហេតុនៃសក្ការៈជាដើម ព្រោះហេតុនោះ ក្នុងប្រការនេះ ទើបមានការអធិប្បាយដូច្នេះថា សព្រហ្មចារីទាំងឡាយគប្បីសក្ការៈសព្រហ្មចារី ដោយហេតុមានធ្វើញបាក់ជាដើម ។

ចប់អដ្ឋកថា និរោធសូត្រទី ៦

# អដ្ឋកថា ចោទនាសូត្រទី ៧

## (ធម៌សម្រាប់ភិក្ខុអ្នកចោទក៍)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ចោទនាសូត្រទី ៧ ដូចតទៅនេះ ៖*

*[៦៧] បទថា **ចោទកេន (អ្នកចោទ)** បានដល់ ភិក្ខុជាអ្នកចោទ ចោទដោយចោទនវត្ថុ (រឿងសម្តែងដល់ការចោទ) ៤ គឺ បង្ហាញវត្ថុ បង្ហាញអាបត្តិ ហាមសំវាស ហាមសាមីចិកម្ម ។ ក្នុងបទថា **កាលេន វក្ខាមិ នោ អកាលេន (អាត្មាអញនឹងពោលក្នុងកាលគួរ មិនពោលក្នុងកាលមិនគួរ)** នេះ ព្រះសារីបុត្តពោលដល់កាលរបស់ភិក្ខុអ្នកត្រូវចោទ (ចម្លើយ) មិនបានពោលដល់កាលរបស់ចោទក៍ (អ្នកចោទ) ។ ពិតហើយ អ្នកដែលនឹងចោទអ្នកដទៃ មិនគួរចោទក្នុងចំណោមបរិស័ទ ឬក្នុងរោងឧបោសថ បវារណា ឬទីអង្គុយ និងរោងឆាន់ជាដើម គួរសូមឱកាសយ៉ាងនេះ ក្នុងវេលាអង្គុយ ក្នុងពេលសម្រាកពេលថ្ងៃថា លោកម្ចាស់ចូរឲ្យឱកាស ខ្ញុំបំណងនឹងនិយាយជាមួយលោកម្ចាស់ ហើយទើបចោទ ។ សម្លឹងដល់បុគ្គល បុគ្គលឡេះឡោះណា ពោលពាក្យមិនពិត ធ្វើឲ្យភិក្ខុទាំងឡាយវិនាស*

ចោទក៏មិនត្រូវសូមឱកាស គប្បីចោទបុគ្គលទ្បេះទ្បោះនោះបាន ។ បទថា *ភូតេន* (ដោយរឿងពិត) គឺ ដោយសភាវៈពិត ។ បទថា *សណ្ហេន* (ដោយពាក្យពិរោះ) គឺ ដោយពាក្យសុភាពទន់ភ្លន់ ។ បទថា *អត្ថសញ្ហិតេន* (ពាក្យដែលប្រកបដោយប្រយោជន៍) បានដល់ ដែលប្រកបដោយភាពជាអ្នកប្រាថ្នាប្រយោជន៍ដ៏ទូលំទូលាយ ។ បទថា *អវិប្បដិសារោ ឧបទហិតព្វោ* (គួរតាំងទុកនូវសេចក្ដីមិនក្ដៅក្រហាយ) បានដល់ ការមិនធ្វើកំហុសឲ្យកើតឡើង ។ បទថា *អលន្តេ អវិប្បដិសារាយ* (លោកទើបមិនគួរក្ដៅក្រហាយ) បានដល់ លោកគួរជាអ្នកមិនមានកំហុស ។ បទដ៏សេសក្នុងសូត្រនេះ មានសេចក្ដីងាយយល់ទាំងអស់នុ៎ះឯង ។

ចប់អដ្ឋកថា ចោទនាសូត្រទី ៧

# អដ្ឋកថា សីលសូត្រទី ៨

*(ទោសនៃបុគ្គលទ្រុស្តសីល និងគុណនៃបុគ្គលមានសីល)*

[៦៨] *សីលសូត្រទី ៨ ជាក់ច្បាស់ហើយ ព្រោះមានន័យដូចដែលពោលមកហើយនុ៎ះឯង ។*

ចប់អដ្ឋកថា សីលសូត្រទី ៨

# អដ្ឋកថា និសន្តិសូត្រទី ៩

## (ហេតុឲ្យគិតបានរហ័ស រៀនបានល្អ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង និសន្តិសូត្រទី ៩ ដូចតទៅនេះ ៖*

[៦៩] *បទថា **ខិប្បនិសន្តិ** (ជាអ្នកពិចារណាបានរហ័ស) ព្រោះពិចារណាចង់ចាំបានរហ័ស ។ បទថា **សុគ្គហិតគ្គាហី** (រៀនបានល្អ) ព្រោះបានរៀនដោយល្អហើយ ។ បទថា **អត្ថកុសលោ** (ជាអ្នកឈ្លាសក្នុងអត្ថ) បានដល់ ជាអ្នកឈ្លាសក្នុងអដ្ឋកថា ។ បទថា **ធម្មកុសលោ** (ឈ្លាសក្នុងធម៌) បានដល់ ឈ្លាសក្នុងព្រះបាលី ។ បទថា **និរុត្តិកុសលោ** (ឈ្លាសក្នុងភាសា) បានដល់ ឈ្លាសក្នុងភាសានិយាយ ។ បទថា **ព្យញ្ជនកុសលោ** (ឈ្លាសក្នុងព្យញ្ជនៈ) បានដល់ ឈ្លាសក្នុងប្រភេទនៃអក្សរ ។*

*បទថា **បុព្វាបរកុសលោ** (ឈ្លាសក្នុងខាងដើម និងខាងចុង) បានដល់ ជាអ្នកឈ្លាសក្នុងខាងដើម និងខាងចុង ៥ ប្រការនេះ គឺ ខាងដើមខាងចុងនៃអត្ថ ខាងដើមខាងចុងនៃធម៌ ខាងដើមខាងចុងនៃបទ ខាងដើមខាងចុងនៃអក្សរ ខាងដើមខាងចុងនៃអនុសន្ធិ ។ ក្នុងខាងដើមខាងចុង*

ទាំងនោះ ដឹងអត្ថខាងចុងដោយអត្ថខាងដើម ដឹងអត្ថខាងដើមដោយអត្ថខាងចុង ឈ្មោះថា ជាអ្នកឈ្លាសក្នុងខាងដើមខាងចុងនៃអត្ថ ដូចម្តេច ។ ក៏ភិក្ខុនោះ កាលលោកវៀរអត្ថខាងដើម ពោលតែអត្ថខាងចុង រមែងដឹងថា អត្ថខាងដើមមានដូច្នេះ , សូម្បីលោកវៀរអត្ថខាងចុង ពោលតែអត្ថខាងដើម ក៏ដឹងថា អត្ថខាងចុងមានដូច្នេះ , កាលលោកវៀរអត្ថទាំងពីរ ពោលតែអត្ថត្រង់កណ្តាល រមែងដឹងថា អត្ថទាំងពីរមានដូច្នេះ , កាលលោកវៀរអត្ថត្រង់កណ្តាល ពោលតែអត្ថទាំងពីរចំណែក រមែងដឹងថា អត្ថត្រង់កណ្តាលមានដូច្នេះ ។ សូម្បីក្នុងខាងដើមខាងចុងនៃធម៌ជាដើម ក៏ន័យនេះដូចគ្នា ។

ក៏ក្នុងខាងដើមខាងចុងនៃអនុសន្ធិ មានអធិប្បាយដូចតទៅនេះ កាលព្រះសូត្រផ្តើមពីសីលជាដើមទៅ ក្នុងទីបំផុតក៏មកដល់អភិញ្ញា ៦ ភិក្ខុរមែងដឹងថា ព្រះសូត្រប្រព្រឹត្តទៅតាមអនុសន្ធិ ទៅតាមកំណត់បទ , កាលព្រះសូត្រផ្តើមពីទិដ្ឋិទៅ ខាងចុងសច្ចៈទាំងឡាយក៏មកដល់ ភិក្ខុក៏រមែងដឹងថា ព្រះសូត្រប្រព្រឹត្តទៅតាមអនុសន្ធិ , កាលព្រះសូត្រផ្តើម ពីការវិវាទទាស់

*ផែនគ្នា ខាងចុងសាកណីយធម៌ក៏មកដល់ កាលព្រះសូត្រផ្តើមពីតិរច្ឆានកថា ៣២ ខាងចុងកថាវត្ថុ ១០ ក៏មកដល់ ភិក្ខុរមែងដឹងថា ព្រះសូត្រប្រព្រឹត្តទៅតាមអនុសន្ធិ ។*

ចប់អដ្ឋកថា និសន្តិសូត្រទី ៩

# អដ្ឋកថា ភទ្ទជិសូត្រទី ១០

## (ព្រះភទ្ទជិសម្ដែងវត្ថុដែលជាកំពូល)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភទ្ទជិសូត្រទី ១០ ដូចតទៅនេះ ៖*

*[៧០] បទថា **អភិភូ** (ជាអ្នកធំក្រៃលែង) បានដល់ គ្របសង្កត់ហើយតាំងនៅ គឺ ជាធំ ។ បទថា **អនភិភូតោ** (មិនមាននរណាគ្របសង្កត់បាន)* បានដល់ ដែលអ្នកដទៃគ្របសង្កត់មិនបាន ។ បទថា **អញ្ញទត្ថុ** (វត្ថុទាំងពួង) ជានិបាតប្រើក្នុងបទថា តែម្យ៉ាង ។ អធិប្បាយថា ឃើញ គឺ ឃើញសព្វគ្រប់ ដោយអំណាចការសម្លឹងមើល ។ បទថា **វសវត្តី** (ញុំាងអ្នកដទៃឲ្យប្រព្រឹត្តក្នុងអំណាច) បានដល់ ញុំាងជនទាំងអស់ឲ្យស្ថិតនៅក្នុងអំណាច ។ បទថា **យថា បស្សតោ** (អ្នកឃើញតាមពិត) បានដល់ អ្នកឃើញអារម្មណ៍ មិនថាជាឥដ្ឋារម្មណ៍ ឬអនិដ្ឋារម្មណ៍ ដោយអាការដែលពិត ។ បទថា **អនន្តរា អាសវានំ ខយោ ហោតិ** (ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានក្នុងលំដាប់) បានដល់ ព្រះអរហត្តរមែងកើតឡើងក្នុងលំដាប់នោះឯង ។ សូម្បីក្នុងបទថា **យថា សុណតោ** (បុគ្គលបានឮ

តាមពិត) នេះ ក៏ន័យនេះដូចគ្នា ។ មួយវិញទៀត ភិក្ខុឃើញរូបណាដោយចក្ខុហើយ ផ្ដើមចម្រើនវិបស្សនា សម្រេចព្រះអរហត្តក្នុងលំដាប់ជាប់ៗគ្នានុ៎ះឯង ព្រះអរហត្តរបស់ភិក្ខុនោះ រមែងឈ្មោះថា មានក្នុងលំដាប់នៃចក្ខុ-វិញ្ញាណ ព្រះអានន្ទត្ថេរៈសំដៅដល់ព្រះអរហត្តនោះ ទើបពោលថា ឥទំ ទស្សនានំ អគ្គំ (ការឃើញនេះ ប្រសើរជាងការឃើញទាំងឡាយ) សូម្បីក្នុងប្រការទី ២ ក៏ន័យនេះដូចគ្នា ។

បទថា យថា សុខិតស្ស (បុគ្គលបានទទួលសេចក្ដីសុខតាមពិត) បានដល់ អ្នកដល់នូវសេចក្ដីសុខ ដែលកើតអំពីមគ្គ ។ បទថា អនន្តរា អាសវានំ ខយោ ហោតិ (ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានក្នុងលំដាប់) បានដល់ ព្រះអរហត្តរមែងកើតឡើងក្នុងលំដាប់ (នៃមគ្គសុខ) នោះឯង ។ បទថា ឥទំ សុខានំ អគ្គំ (នេះជាកំពូលនៃសេចក្ដីសុខទាំងឡាយ) បានដល់ មគ្គសុខនេះ ជាកំពូលនៃសេចក្ដីសុខទាំងឡាយ ។ សូម្បីក្នុងបទថា យថាសញ្ញិស្ស (បុគ្គលអ្នកមានសេចក្ដីសម្គាល់តាមពិត) នេះ បំណងយកមគ្គសញ្ញានុ៎ះឯង ។ បទថា យថាភូតស្ស (អ្នកកើតហើយតាម

ពិត) បានដល់ កើតហើយក្នុងភពណា គឺ ក្នុងអត្តភាពណា ។ បទថា **អនន្តរា** (ក្នុងលំដាប់) បានដល់ ព្រះអរហត្តកើតឡើងហើយក្នុងលំដាប់នុ៎ះឯង ។ បទថា **ឥទំ ភវានំ អគ្គំ** (នេះជាកំពូលនៃភពទាំងឡាយ) បានដល់ អត្តភាពចុងក្រោយ ឈ្មោះថា ជាកំពូលនៃភពទាំងឡាយ ។ម្យ៉ាងទៀត អធិប្បាយថា បទថា **អ្នកកើតហើយតាមពិត** បានដល់ កើត គឺ មានហើយ ក្នុងខណៈនៃមគ្គចិត្ត ព្រោះខន្ធទាំងឡាយណា ។ បទថា **អនន្តរា អាសវានំ ខយោ ហោតិ** (ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានក្នុងលំដាប់) បានដល់ ផលរមែងកើតឡើងក្នុងលំដាប់នៃមគ្គនុ៎ះឯង ។ បទថា **នេះកំពូលនៃភពទាំងឡាយ** បានដល់ ខន្ធបញ្ចកៈក្នុងខណៈនៃមគ្គចិត្តនេះ ឈ្មោះថា ជាកំពូលនៃភពទាំងឡាយ ។

ចប់អដ្ឋកថា ភទ្ទជិសូត្រទី ១០

## ចប់អាឃាតវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៧ សូត្រ

# ឧបាសកវគ្គវណ្ណនាទី ៣

## អដ្ឋកថា សារជ្ជសូត្រទី ១

*(ធម៌ធ្វើឲ្យឧបាសកក្លៀវក្លា)*

គប្បីជ្រាបវិនិច្ឆ័យក្នុង សារជ្ជសូត្រទី ១ ដូចតទៅនេះ ៖

[៧១] ទ្រង់ត្រាស់ដល់អគារិយប្បដិបត្តិ វត្តបដិបត្តិរបស់អ្នកគ្រប់គ្រងផ្ទះ ។ សូម្បីជាព្រះសោតាបន្ន និងព្រះសកទាគាមី អគារិយប្បដិបត្តិក៏រមែងគួរទាំងអស់ ។

ចប់អដ្ឋកថា សារជ្ជសូត្រទី ១

# អដ្ឋកថា វិសារទសូត្រទី ២

*(ធម៌ធ្វើឲ្យឧបាសកក្លៀវក្លា)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វិសារទសូត្រទី ១ ដូចតទៅនេះ ៖*

*[៧២] ទ្រង់ត្រាស់ដល់អគារិយប្បដិបត្តិ វត្តបដិបត្តិរបស់អ្នកគ្រប់គ្រងផ្ទះ ។ សូម្បីជាព្រះសោតាបន្ន និងព្រះសកទាគាមី អគារិយប្បដិបត្តិក៏រមែងគួរទាំងអស់ ។*

ចប់អដ្ឋកថា វិសារទសូត្រទី ២

# អដ្ឋកថា និរយសូត្រទី ៣

*(ធម៌ធ្វើឲ្យឧបាសកធ្លាក់នរក)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង និរយសូត្រទី ១ ដូចតទៅនេះ ៖*

*[៧៣] ទ្រង់ត្រាស់ដល់អគារិយប្បដិបត្តិ វត្តបដិបត្តិរបស់អ្នកគ្រប់គ្រងផ្ទះ ។ សូម្បីជាព្រះសោតាបន្ន និងព្រះសកទាគាមី អគារិយប្បដិបត្តិក៏រមែងគួរទាំងអស់ ។*

ចប់អដ្ឋកថា និរយសូត្រទី ៣

# អដ្ឋកថា វេរសូត្រទី ៤

## *(ភ័យ ៥ ប្រការ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វេរសូត្រទី ៤ ដូចតទៅនេះ ៖*

*[៧៤] បទថា **ភយានិ** (ភ័យ) បានដល់ ភ័យដែលកើតអំពីសេចក្តីតក់ស្លុត ។ បទថា **វេរានិ** (ពៀរ) បានដល់ ពៀរកើតពីអកុសលខ្លះ ពៀរកើតពីបុគ្គលខ្លះ ។ បទថា **ចេតសិកំ** (ផ្លូវចិត្ត) បានដល់ អាស្រ័យចិត្ត ។ បទថា **ទុក្ខំ** (ទុក្ខ) បានដល់ ទុក្ខដែលមានកាយបសាទជាទីតាំង ។ បទថា **ទោមនស្សំ** (ទោមនស្ស) បានដល់ ទោមនស្សវេទនា ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ការលះដោយវិរតិ (ចេតនាវៀរចាក) ។*

ចប់អដ្ឋកថា វេរសូត្រទី ៤

# អដ្ឋកថា ចណ្ឌាលសូត្រទី ៥

## (ធម៌របស់ឧបាសកអាក្រក់)

គប្បីជ្រាបវិនិច្ឆ័យក្នុង ចណ្ឌាលសូត្រទី ៥ ដូចតទៅនេះ ៖

[៧៥] បទថា **ឧបាសកបច្ចិកិដ្ឋោ** (ឧបាសកគួរខ្ពើម) បានដល់ ជាឧបាសកទន់ទាប ។ បទថា **កោតុហលមង្គលិកោ** (ប្រកាន់មង្គលភ្ញាក់ផ្អើល) បានដល់ អ្នកដែលប្រកបដោយអារម្មណ៍ដែលបានឃើញ បានឮ បានជ្រាប ថាជាមង្គល គឺ ភ្ញាក់ផ្អើល ព្រោះជាមនុស្សល្ងង់ ឲ្យប្រព្រឹត្តទៅយ៉ាងនេះថា វត្ថុនេះនឹងមានដោយហេតុនេះ ។ បទថា **មង្គលំ បច្ចេតិ នោ កម្មំ** (ជឿមង្គល មិនជឿកម្ម) បានដល់ ជឿ ដាក់ចិត្តតែរឿងមង្គល មិនជឿកម្ម ។ បទថា **ឥតោ ច ពហិទ្ធា** (ខាងក្រៅសាសនានេះ) បានដល់ ខាងក្រៅពីព្រះពុទ្ធសាសនានេះ ។ បទថា **បុព្វការំ ករោតិ** (ធ្វើការទំនុកបម្រុង) បានដល់ ធ្វើកុសលកិច្ច មានទានជាដើម ។

ចប់អដ្ឋកថា ចណ្ឌាលសូត្រទី ៥

# អដ្ឋកថា បីតិសូត្រទី ៦

*(មិនជាឋានៈរបស់ព្រះអរិយសាវកអ្នកចូលដល់បីតិ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បីតិសូត្រទី ៥ ដូចតទៅនេះ ៖*

*[៧៦] បទថា **កិន្តិ មយំ** (ពួកយើង... ដោយឧបាយដូចម្ដេច) បានដល់ ពួកយើង (គប្បីចូលដល់បីតិដែលកើតអំពីវិវេក...) ដោយឧបាយដូចម្ដេច ។ បទថា **បវិវេកំ បីតឹ** (បីតិដែលកើតពីវិវេក) បានដល់ បីតិដែលអាស្រ័យបឋមឈាន និងទុតិយឈានកើតឡើង ។ បទថា **កាមុបសញ្ហិតំ** (ដែលប្រកបដោយកាម) បានដល់ ដែលអាស្រ័យកាម គឺ អាស្រ័យកាមពីរយ៉ាង ប្រារព្ធកាមពីរយ៉ាងកើតឡើង ។ កាលគិតថា យើងនឹងបាញ់ម្រឹគ និងជ្រូកជាដើម បាញ់ព្រួញទៅខុស ទុក្ខទោមនស្សដែលអាស្រ័យអកុសល កើតឡើងយ៉ាងនេះថា យើងបាញ់ខុសហើយ ឈ្មោះថា **អកុសលុបសញ្ហិតំ** (ដែលប្រកបដោយអកុសល) ។ កាលបាញ់មិនខុស ក្នុងឋានៈនោះ សុខសោមនស្សកើតឡើងថា យើងបាញ់ល្អហើយ យើងប្រហារល្អហើយ ឈ្មោះថា **អកុសលុបសញ្ហិតំ សុខំ សោមនស្សំ** (សុខសោម-*

នស្សប្រកបដោយអកុសល) ។ តែទុក្ខទោមនស្ស ដែលកើតឡើងព្រោះ ឧបករណ៍មានទានវត្ថុជាដើមនៅមិនដល់ព្រម គប្បីជ្រាបថា កុសលូបស-ញ្ហិតំ ទុក្ខំ ទោមនស្សំ (ទុក្ខទោមនស្សដែលប្រកបដោយកុសល) ។

ចប់អដ្ឋកថា បីតិសូត្រទី ៦

# អដ្ឋកថា វណិជ្ជសូត្រទី ៧

គប្បីជ្រាបវិនិច្ឆ័យក្នុង វណិជ្ជសូត្រទី ៧ ដូចតទៅនេះ ៖

[៧៧] បទថា *វណិជ្ជា* (ជំនួញ) បានដល់ ការធ្វើជំនួញ ។ បទថា *ឧបាសកេន* (ឧបាសក) បានដល់ អ្នកដល់សរណៈ ៣ ។ បទថា *សត្ថវណិជ្ជា* (ការជួញគ្រឿងសស្ត្រាវុធ) បានដល់ ឲ្យគេធ្វើអាវុធហើយក៏ជួញដូរអាវុធនោះ ។ បទថា *សត្តវណិជ្ជា* (ការជួញមនុស្ស) បានដល់ ជួញមនុស្ស ។ បទថា *មំសវណិជ្ជា* (ការជួញសត្វដែលគេសម្លាប់យកសាច់) បានដល់ ចិញ្ចឹមជ្រូកយកសាច់ជាដើម ហើយជួញសត្វទាំងនោះ ។ បទថា *មជ្ជវណិជ្ជា* (ការជួញគ្រឿងស្រវឹង) បានដល់ ឲ្យគេធ្វើគ្រឿងស្រវឹងណាមួយ ហើយក៏ជួញគ្រឿងស្រវឹងទាំងនោះ ។ បទថា *វិសវណិជ្ជា* (ជួញថ្នាំពិស) បានដល់ ឲ្យគេធ្វើថ្នាំពិសហើយ ក៏ជួញថ្នាំពិសនោះ ។ ការធ្វើដោយខ្លួនឯង ការបបួលអ្នកដទៃឲ្យធ្វើ ជំនួញទាំងអស់នោះមិនគួរ ។

ចប់អដ្ឋកថា វណិជ្ជសូត្រទី ៧

# អដ្ឋកថា រាជសូត្រទី ៨

## *(អ្នកមានសីលមិនត្រូវព្រះរាជាដាក់ទោស)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង រាជសូត្រទី ៩ ដូចតទៅនេះ ៖*

*[៧៨] បទថា* ***បព្វាជេន្តិ*** *(និរទេស) គឺ ឲ្យបណ្តេញចេញអំពីតំបន់ ។ បទថា* ***យថាបច្ចយំ វា ករោន្តិ*** *(ឬធ្វើឲ្យគួរតាមទោស) បានដល់ ធ្វើតាមបំណង ធ្វើតាមអធ្យាស្រ័យ ។ បទថា* ***តមេវ បាបកម្មំ បវេទេន្តិ*** *(បាបកម្មរបស់គេនោះឯងរមែងប្រាប់ឲ្យជ្រាប) បានដល់ គេធ្វើបាបកម្មដោយប្រការណា ប្រាប់កម្មនោះដល់អ្នកដទៃដោយប្រការនោះឯង ។*

ចប់អដ្ឋកថា រាជសូត្រទី ៨

(១) បិដក = តមេវ បាបកម្មំ បវេទេតិ ។

# អដ្ឋកថា គិហិសូត្រទី ៩

*គប្បីជ្រាបវិនិច្ឆ័យក្នុង គិហិសូត្រទី ៩ ដូចតទៅនេះ ៖*

*[៧៩] បទថា* ***សំវុតកម្មន្តំ (មានការងារសង្រួម)*** *គឺ មានការងារដែលបិទបាំងហើយ (អំពីអកុសល) ។ បទថា* ***អាភិចេតសិកានំ (ដែលមានចិត្តដ៏ក្រៃលែង)*** *គឺ ដែលអាស្រ័យចិត្តខ្ពង់ខ្ពស់ ។ បទថា* ***ទិដ្ឋធម្មសុខវិហារានំ (នូវធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន)*** *បានដល់ នូវធម៌ជាគ្រឿងនៅជាសុខក្នុងធម៌ដែលឃើញច្បាស់នោះឯង គឺ ក្នុងបច្ចុប្បន្ន ។ បទថា* ***អរិយកន្តេហិ (ដែលព្រះអរិយៈប្រាថ្នា)*** *បានដល់ សីលក្នុងមគ្គផលដែលព្រះអរិយៈទាំងឡាយប្រាថ្នាហើយ ។ ព្រះមានព្រះភាគត្រាស់សីល ៥ ថា អរិយធម៌ ក្នុងបទនេះថា* ***អរិយធម្មំ សមាទាយ (សមាទានអរិយធម៌ហើយ)*** *។ បទថា* ***មេរយំ វារុណឹ (សុរាមេរ័យ)*** *បានដល់ មេរ័យ ៤ យ៉ាង និងសុរា ៥ យ៉ាង ។ បទថា* ***ធម្មញ្ញានុវិតក្កយេ (និងគប្បីត្រិះរិះដល់ព្រះធម៌រឿយៗ)*** *បានដល់ គប្បីត្រិះរិះដោយរឭកដល់លោកុត្តរធម៌ ៩ យ៉ាង ។ បទថា* ***អព្យាបជ្ឈំ***

*ហិតំ ចិត្តំ (ចិត្តដែលប្រាសចាកព្យាបាទ ដែលជាប្រយោជន៍ដ៏ទូលាយ)* បានដល់ ចិត្តដែលប្រកបដោយព្រហ្មវិហារ មានមេត្តាជាដើម ដែលរកទុក្ខមិនបាន ។ បទថា *ទេវលោកាយ ភាវយេ (គប្បីអប់រំ... ដើម្បីទេវលោក)* បានដល់ គប្បីចម្រើនដើម្បីកើតក្នុងព្រហ្មលោក ។ បទថា *បុញ្ញត្ថស្ស ជិគីសតោ (អ្នកត្រូវការបុណ្យស្វែងរកបុណ្យ)* បានដល់ អ្នកប្រាថ្នាបុណ្យ អ្នកស្វែងរកបុណ្យ ។ បទថា *សន្តេសុ (ក្នុងសប្បុរស)* បានដល់ ក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះតថាគត ។ បទថា *វិបុលា ហោតិ ទក្ខិណា (ទក្ខិណាទាន... រមែងមានផលច្រើន)* បានដល់ ទានដែលឲ្យហើយយ៉ាងនេះ មានផលច្រើន ។ បទថា *អនុបុព្វេន (ដោយលំដាប់)* បានដល់ ដោយលំដាប់ មានការបំពេញសីលជាដើម ។ ពាក្យដ៏សេស មានន័យបានពោលហើយក្នុងតិកនិបាតនោះឯង ។

ចប់អដ្ឋកថា គិហិសូត្រទី ៩

# អដ្ឋកថា ភវេសិសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភវេសិសូត្រទី ១០ ដូចតទៅនេះ ៖*

*[៨០] បទថា* ***សិតំ បាត្វាកាសិ*** *(ទ្រង់ធ្វើការញញឹមឲ្យប្រាកដ) សេចក្តីថា ព្រះមានព្រះភាគកាលស្តេចយាងទៅតាមផ្លូវធំ ទ្រង់ទតមើលសាលព្រឹក្សនោះ ទ្រង់ព្រះតម្រិះថា ក្នុងទីនេះនឹងមានហេតុអ្វីធ្លាប់កើតឡើងហើយហ្ន៎ ទ្រង់ក៏បានឃើញហេតុដែលឧបាសក ឈ្មោះ ភវេសី បានធ្វើទុកហើយក្នុងសម័យព្រះពុទ្ធកស្សបៈ ព្រះអង្គមានព្រះតម្រិះតទៅទៀតថា ហេតុនេះ ប្រក្រតីមិនប្រាកដដល់ពួកភិក្ខុ ណ្ហើយចុះ តថាគតនឹងធ្វើហេតុនេះឲ្យប្រាកដដល់ពួកភិក្ខុ ទើបគេចចេញអំពីផ្លូវ ប្រថាប់ក្នុងទីដ៏សមគួរមួយ ទ្រង់ធ្វើនូវការញញឹមឲ្យប្រាកដ គឺ ទ្រង់ញញឹមតិចៗ សម្តែងចុងព្រះទន្ត ។ ព្រះពុទ្ធទាំងឡាយមិនបានញញឹមដូចពួកមនុស្សក្នុងលោក ដែលសើចខ្លាំងៗ (រីងពោះ) សើចចេញទឹកភ្នែក ។ ការញញឹមរបស់ព្រះពុទ្ធទាំងឡាយ ក៏ត្រឹមតែអាការសោមនស្សប៉ុណ្ណោះ ។ ឈ្មោះថា ការញញឹមនេះ រមែងមានដោយចិត្តសហគតដោយសោមនស្ស ១៣ ដួង ។ ពួកមនុស្សសើចដោយ*

ចិត្ត ៨ ដួង គឺ ចំណែកអកុសល ៤ ដួង ចំណែកកាមាវចរកុសល ៤ ដួង ។ វៀរចិត្តដែលសម្បយុត្តដោយទិដ្ឋិ ចំណែកអកុសល ២ ដួង ព្រះសេក្ខៈទាំងឡាយ រមែងសើចដោយចិត្ត ៦ ដួង ។ ព្រះខីណាស្រពសើចដោយចិត្ត ៥ ដួង គឺ ចំណែកកិរិយាចិត្តដែលជាសហេតុកៈ ៤ ដួង ដែលជាអហេតុកៈ ១ ដួង ។ សូម្បីក្នុងចិត្តទាំងនោះ កាល អារម្មណ៍មានកម្លាំងមកប្រាកដ ព្រះខីណាស្រពទាំងឡាយ រមែងសើចដោយចិត្តសម្បយុត្តដោយញាណ ២ ដួង ។ កាលអារម្មណ៍ដែលមានកម្លាំងខ្សោយមកប្រាកដ ព្រះខីណាស្រព រមែងសើចដោយចិត្ត ៣ ដួង គឺ ដោយទុហេតុកចិត្ត ២ ដួង និងដោយអហេតុកចិត្ត ១ ដួង ។ តែក្នុងទីនេះ កិរិយាចិត្តដែលសហគតដោយសោមនស្ស ដែលជាអហេតុកមនោវិញ្ញាធាតុ ធ្វើការញញឹមត្រឹមតែអាការរីករាយក្នុងចិត្តឲ្យកើតឡើងដល់ព្រះដ៏មានព្រះភាគ ។ ក៏ការញញឹមនោះ សូម្បីត្រឹមតែបន្តិចបន្តួចយ៉ាងនេះ ក៏មកប្រាកដដល់ព្រះថេរៈហើយដូចម្តេច ។ ពិតណាស់ ក្នុងកាលនោះ ពន្លឺរស្មីប្រមាណធំប៉ុនដើមត្នោតផ្សាយចេញពីព្រះទន្ត (ព្រះចង្កូមកែវ) ទាំង ៤ របស់ព្រះតថាគត ដូចផ្លេក

បន្ទោរ ចេញអំពីជុំពពកធំក្នុងទិសទាំង ៤ ធ្វើប្រទក្សិណជុំវិញព្រះសិរសៈ ៣ ជុំ ហើយក៏បាត់ទៅត្រង់ខាងចុងព្រះទាឋៈនុ៎ះឯង ។ ដោយសញ្ញានោះ ព្រះអានន្ទ សូម្បីតាមស្តេចទៅខាងក្រោយព្រះមានព្រះភាគ ក៏រមែងដឹងថា ព្រះមានព្រះភាគទ្រង់ធ្វើការញញឹមឲ្យប្រាកដ ។

បទថា **ឥទ្ធំ** (ជានគរស្តុកស្តម្ភ) បានដល់ មានទ្រព្យច្រើន ។ បទថា **ផីតំ** (ធំទូលាយ) បានដល់ ចម្រើនដ៏ក្រៃលែង ដូចផ្កាឈើរីកស្គុះស្គាយគ្រប់ជួរ ។ បទថា **អាកិណ្ណមនុស្សំ** (មានមនុស្សកុះករ) បានដល់ ពោរពេញទៅដោយមនុស្ស ។ បទថា **សីលេសុ អបរិបូរការី** (ជាអ្នកមិនបានធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ) បានដល់ មិនធ្វើឲ្យបរិបូណ៌ក្នុងសីល ៥ ។ បទថា **បដិទេសិតានិ** (ពន្យល់) បានដល់ សម្តែងភាពជាឧបាសក ។ បទថា **សមាទបិតានិ** (ឲ្យសមាទានហើយ) សេចក្តីថា ឲ្យតាំងនៅក្នុងសរណៈទាំងឡាយ ។ បទថា **ឥច្ចេតំ សមសមំ** (សុទ្ធតែស្មើៗ គ្នាដូច្នោះ) បានដល់ ដូច្នោះ ហេតុនោះស្មើគ្នាដោយការស្មើដោយអាការទាំងពួង មិនបានស្មើដោយឯកទេស (ចំណែកខ្លះ) ។ បទថា **នត្ថិ កិញ្ចិ អតិរេកំ**

(មិនមានក្រៃលែងជាងគ្នា) បានដល់ យើងមិនមានហេតុអ្វីៗ ដែលលើស លុបជាងមនុស្សទាំងនេះទេ ។ សព្ទថា **ហន្ទ** (បើដូច្នោះ) ជានិបាតចុះក្នុង អត្ថថា ដាស់តឿន ។ បទថា **អតិរេកាយ** (គួរបដិបត្តិឲ្យក្រៃលែងជាង) សេចក្តីថា យើងនឹងបដិបត្តិដើម្បីហេតុដ៏ល្អក្រៃលែងឡើងទៅ ។ បទថា **សីលេសុ បរិបូរការី ធារេថ** (ចូរចាំទុកនូវខ្ញុំថា ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុង សីលទាំងឡាយ) បានដល់ អ្នកទាំងឡាយចូរដឹងថា យើងជាអ្នកធ្វើឲ្យ បរិបូណ៌ក្នុងសីល ៥ ។ ដោយហេតុត្រឹមតែប៉ុណ្ណោះ ភវេសិឧបាសកនោះ ឈ្មោះថា សមាទានសីល ៥ ហើយ ។ បទថា **កិមង្គំ បន ន មយំ** (ក៏ហេតុអ្វី យើងទាំងឡាយធ្វើឲ្យបរិបូរក្នុងសីលមិនបានឬ) បានដល់ ដោយ ហេតុយ៉ាងណាហ្ន៎ យើងទើបមិនជាអ្នកធ្វើឲ្យបរិបូណ៌ ។ ពាក្យដ៏សេស ក្នុងសូត្រនេះងាយយល់ហើយ ។

ចប់អដ្ឋកថា ភវេសិសូត្រទី ១០

## ចប់អាឃាតវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# អរញ្ញវគ្គវណ្ណនាទី ៤

## អដ្ឋកថា អារញ្ញកសូត្រទី ១

*(អ្នកនៅព្រៃជាវត្ត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អារញ្ញកសូត្រទី ១ ដូចតទៅនេះ ៖*

*[៨១] បទថា* **មន្ទត្តា មោមូហត្តា** *(ព្រោះល្ងង់ខ្លៅ ព្រោះវង្វេង) បានដល់ មិនដឹងការសមាទាន មិនដឹងអានិសង្ស តែនៅព្រៃជាវត្តដោយមិនដឹង ព្រោះខ្លួនល្ងង់ខ្លៅ ។ បទថា* **បាបិច្ឆោ ឥច្ឆាបកតោ** *(មានការប្រាថ្នាលាមក ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់) សេចក្តីថា ភិក្ខុតាំងនៅក្នុងសេចក្តីប្រាថ្នាលាមកយ៉ាងនេះថា កាលអញនៅក្នុងព្រៃ ជនទាំងឡាយនឹងធ្វើសក្ការៈដោយបច្ច័យ ៤ ព្រោះគិតថា ភិក្ខុនេះកាន់យកព្រៃជាវត្ត ហើយនឹងសរសើរដោយគុណទាំងឡាយ មានជាអាទិ៍ថា ភិក្ខុនេះជាលជ្ជី ចូលចិត្តស្ងប់ស្ងាត់ ដូច្នេះ ហើយត្រូវសេចក្តីប្រាថ្នាលាមកនោះឯងគ្របសង្កត់ ទើបជាអ្នកយកព្រៃជាវត្ត ។ មួយទៀត ភិក្ខុចូលទៅនៅក្នុងព្រៃដោយការឆ្កួតឈ្មោះថា កាន់យកព្រៃជាវត្ត* **ឧម្មាទា ចិត្តក្ខេបា** *(ព្រោះជាភិក្ខុឆ្កួត ព្រោះ*

*ចិត្តរាយមាយ) ។ បទថា **វណ្ណិតំ** (សរសើរ) សេចក្តីថា ជាអ្នកកាន់យកព្រៃជាវត្ត ព្រោះដឹងថា ឈ្មោះថា អង្គនៃភិក្ខុអ្នកនៅព្រៃជាវត្តនេះ ព្រះពុទ្ធនិងសាវករបស់ព្រះពុទ្ធទាំងឡាយសរសើរហើយ គឺ រមែងសរសើរហើយ ។ បទថា **ឥទមត្ថិតំ** (ភាពជាអ្នកមានសេចក្តីត្រូវការដោយវត្តបដិបត្តិល្អដូច្នេះ) សេចក្តីថា ឈ្មោះថា **ឥទមត្ថិ** ព្រោះមានសេចក្តីត្រូវការដោយវត្តបដិបត្តិល្អយ៉ាងនេះ ភាពនៃអ្នកមានសេចក្តីត្រូវការដោយវត្តបដិបត្តិដែលល្អយ៉ាងនេះ ឈ្មោះថា **ឥទមត្ថិតា** ព្រោះអាស្រ័យភាពជាអ្នកមានសេចក្តីត្រូវការដោយវត្តបដិបត្តិនេះប៉ុណ្ណោះ មិនបានអាស្រ័យលោកាមិសៈណាៗ ដទៃ ។ ពាក្យដ៏សេសក្នុងសូត្រនេះ និងសូត្រក្រៅអំពីនេះ មានអត្ថងាយហើយ ។*

ចប់អដ្ឋកថា អារញ្ញសូត្រទី ១

# អដ្ឋកថា បង្សុកូលិកសូត្រទី ២

*(អ្នកទ្រទ្រង់សំពត់បង្សុកូលជាវត្ត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បង្សុកូលិកសូត្រទី ២ ដូចតទៅនេះ ៖*

[៨២] *ក្នុងសូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា បង្សុកូលិកសូត្រទី ២

# អដ្ឋកថា រុក្ខមូលិកសូត្រទី ៣

*(អ្នកនៅគល់ឈើជាវត្ត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង រុក្ខមូលិកសូត្រទី ៣ ដូចតទៅនេះ ៖*

*[៨៣] ក្នុងសូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា រុក្ខមូលិកសូត្រទី ៣

# អដ្ឋកថា សោសានិកសូត្រទី ៤

*(អ្នកនៅព្រៃខ្មោចជាវត្ត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សោសានិកសូត្រទី ៤ ដូចតទៅនេះ ៖*

[៨៤] *ក្នុងសូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា សោសានិកសូត្រទី ៤

# អដ្ឋកថា អព្ភោកាសិកសូត្រទី ៥

*(អ្នកនៅក្នុងទីវាលជាវត្ត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អព្ភោកាសិកសូត្រទី ៥ ដូចតទៅនេះ ៖*

*[៨៥] ក្នុងសូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អព្ភោកាសិកសូត្រទី ៣

# អដ្ឋកថា នេសជ្ជិកសូត្រទី ៦

*(អ្នកសមាទានការអង្គុយជាវត្ត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង នេសជ្ជិកសូត្រទី ៦ ដូចតទៅនេះ ៖*

*[៨៦] ក្នុងសូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា នេសជ្ជិកសូត្រទី ៦

# អដ្ឋកថា យថាសន្តតិកសូត្រទី ៧

*(អ្នកនៅក្នុងសេនាសនៈតាមដែលបាត់ឲ្យជាវត្ត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង យថាសន្តតិកសូត្រទី ៧ ដូចតទៅនេះ ៖*

*[៨៧] ក្នុងសូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា យថាសន្តតិកសូត្រទី ៧

# អដ្ឋកថា ឯកាសនិកសូត្រទី ៨

*(អ្នកសមាទានការចាន់ក្នុងអាសនៈមួយជាវត្ត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឯកាសនិកសូត្រទី ៨ ដូចតទៅនេះ ៖*

[៨៨] *ក្នុងសូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា ឯកាសនិកសូត្រទី ៨

# អដ្ឋកថា ខលុបច្ឆាភត្តិកសូត្រទី ៩

*(អ្នកកាន់ការហាមភត្តដែលនាំមកជាខាងក្រោយជាវត្ត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ខលុបច្ឆាភត្តិកសូត្រទី ៩ ដូចតទៅនេះ ៖*

[៨៩] *ក្នុងសូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា ខលុបច្ឆាភត្តិកសូត្រទី ៩

# អដ្ឋកថា បត្តបិណ្ឌិកសូត្រទី ១០

*(អ្នកសមាទានការឆាន់ក្នុងបាត្រជាវត្ត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បត្តបិណ្ឌិកសូត្រទី ១០ ដូចតទៅនេះ ៖*

*[៩០] ក្នុងសូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា បត្តបិណ្ឌិកសូត្រទី ១០

## ចប់អរញ្ញវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថរួមគ្នា

# ព្រាហ្មណវគ្គវណ្ណនាទី ៥

## អដ្ឋកថា សោណកសូត្រទី ១

*(សុនខនៅរក្សាធម្មទំនៀមបុរាណទុកបាន)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សោណសូត្រទី ១ ដូចតទៅនេះ ៖*

[៩១] *បទថា **ព្រាហ្មណធម្មា** (ធម៌របស់ព្រាហ្មណ៍) បានដល់សភាពរបស់ព្រាហ្មណ៍ ។ បទថា **សុនខេសុ** (ក្នុងពួកសុនខ) បានដល់ក្នុងសុនខទាំងឡាយ ។ បទថា **នេវ កីណន្តិ នោ វិក្កីណន្តិ** (មិនទិញមិនលក់) បានដល់ ទទួលយកមកមិនបានទិញ ឲ្យទៅមិនបានលក់ ។ បទថា **សម្បិយេនេវ សំវាសំ សម្ពន្ធាយ សម្បវត្តេន្តិ** (គ្រាន់តែប្រព្រឹត្តទៅដើម្បីផ្សំផ្គុំនូវសំវាស តាមសេចក្តីស្រលាញ់ និងមិនស្រឡាញ់ប៉ុណ្ណោះ) សេចក្តីថា អ្នកជាទីស្រលាញ់ចូលទៅរកអ្នកជាទីស្រលាញ់ ហើយនូវរួមគ្នាដើម្បីបន្តប្រពៃណីប៉ុណ្ណោះ ។ បទថា **ឧទរាវទេហកំ** (បំពេញពោះ) បានដល់ បរិភោគរហូតពេញពោះ ។ បទថា **អវសេសំ អាទាយ បក្កមន្តិ** (កាន់យកចំណែកដែលសេសសល់ទៅ) បានដល់ កាន់យកអាហារដែល*

បរិភោគមិនអស់ចៀសចេញទៅ ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ត្រាស់ចំណែកវិនាសតែម្យ៉ាង ។

ចប់អដ្ឋកថា សោណសូត្រទី ១

# អដ្ឋកថា ទោណសូត្រទី ២

## (ព្រាហ្មណ៍ ៥ ពួក ទ្រង់ត្រាស់ដល់ទោណព្រាហ្មណ៍)

គប្បីជ្រាបវិនិច្ឆ័យក្នុង ទោណសូត្រទី ២ ដូចតទៅនេះ ៖

[៩២] បទថា **តុំបិ នោ** (សូម្បីលោក...មិនមែនឬ) កែជា **តុម្ហេ នុ** (សូម្បីលោក) ។ បទថា **បវត្តារោ** (ប្រាប់) គឺ អ្នកបង្រៀន ។ បទថា **យេសំ** (ដែលលោក) គឺ ដែលជាសម្បត្តិរបស់ឥសីពួកណា ។ បទថា **មន្តបទំ** (នូវបទមន្ត) បានដល់ មន្ត គឺ គម្ពីរវេទត្រៃឯង ។ បទថា **គីតំ** (ដែលលោកច្រៀងហើយ) បានដល់ ដែលពួកបុរាណព្រាហ្មណ៍ចំនួន ១០ នាក់ មានអដ្ឋកព្រាហ្មណ៍ជាដើម ស្វាធ្យាយហើយ ដោយការដល់ព្រមនៃសំឡេង ។ បទថា **បវុត្តំ** (ប្រាប់ហើយ) បានដល់ ប្រាប់ ពោលគឺ បង្រៀនដល់ពួកព្រាហ្មណ៍ដទៃ ។ បទថា **សមិហិត** (រួបរួមទុកហើយ) បានដល់ រួបរួម គឺ ធ្វើឲ្យជាកង អធិប្បាយថា តាំងទុកជាក្រុម ជាដុំ ។ បទថា **តទនុគាយន្តិ** (ច្រៀងតាម) បានដល់ ឥឡូវនេះ ព្រាហ្មណ៍ទាំងឡាយ ក៏ច្រៀងមន្តនោះ តាមបុរាណព្រាហ្មណ៍ទាំងនោះប្រាប់មកអំពីមុន ។ បទថា

**តទនុភាសន្តិ** (ពោលតាម) បានដល់ ពោលតាមមន្តនោះ ។ បទនេះ វេវចនៈរបស់បទមុននោះឯង ។ បទថា **ភាសិតមនុភាសន្តិ** (ពោលបានត្រឹមត្រូវតាមដែលលោកពោលទុក) បានដល់ ពោលតាមដែលពួកបុរាណ-ព្រាហ្មណ៍ទាំងនោះពោលទុកហើយ ។ បទថា **សជ្ឈាយិតមនុសជ្ឈាយន្តិ**[១] (ស្វាធ្យាយតាមដែលលោកស្វាធ្យាយទុក) បានដល់ ស្វាធ្យាយតាមដែលពួកបុរាណព្រាហ្មណ៍ទាំងនោះស្វាធ្យាយហើយ ។ បទថា **វាចិតមនុវាចេន្តិ** (ប្រាប់បានត្រឹមត្រូវតាមដែលលោកប្រាប់ទុក) បានដល់ ប្រាប់តាមដែលពួកបុរាណព្រាហ្មណ៍ទាំងនោះប្រាប់ដល់ពួកជនដទៃ ។

បទថា **សេយ្យថីទំ** (គឺ) បានដល់ បុរាណព្រាហ្មណ៍ទាំងនោះ មាននរណាខ្លះ ។ បទថា **អដ្ឋកោ** (ឥសីឈ្មោះអដ្ឋកៈ) ជាដើម ជាឈ្មោះរបស់បុរាណព្រាហ្មណ៍ទាំងនោះ ។ បានឮថា បុរាណព្រាហ្មណ៍ទាំងនោះ សម្លឹងមើលដោយទិព្វចក្ខុហើយ រៀបរៀងមន្តទាំងឡាយ មិនធ្វើការបៀនបៀនអ្នកដទៃ ប្រៀបដូចនឹងពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគអរហន្ត-

(១) បទនេះ មិនឃើញមានក្នុងបិដកទេ ។

សម្មាសម្ពុទ្ធព្រះនាមកស្សបៈ ។ តែព្រាហ្មណ៍ពួកដទៃ បន្ថែមកម្មមានបា-ណាតិបាតជាដើមចូលទៅ ទម្លាយព្រះវេទ ៣ ធ្វើឲ្យជំទាស់នឹងព្រះពុទ្ធ-វចនៈ ។

បទថា **អស្សុ** ក្នុងបទថា **ត្យាស្សុមេ** (ឥសីទាំងនោះ... នេះ) នេះ ត្រឹមតែជានិបាត ។ អធិប្បាយថា ព្រាហ្មណ៍ទាំងនោះរមែងបញ្ញត្តិព្រាហ្ម-ណធម៌ ៥ ទាំងនេះ ។ បទថា **មន្តេ អធិយមានោ** (រៀនយកនូវមន្ត) បានដល់ ទន្ទេញ រៀនព្រះវេទទាំងឡាយ ។ បទថា **អាចរិយធនំ** (ទ្រព្យសម្រាប់បូជាអាចារ្យ) បានដល់ ទ្រព្យបូជាអាចារ្យ គឺ ទ្រព្យដែលជាចំណែកសម្រាប់អាចារ្យ ។ បទថា **ន ឥស្សត្ថេន** (មិនបានស្វែងរកដោយអំពើនៃឋានៈជាទាហាន) បានដល់ មិនមែនឲ្យកើតឡើងដោយភាពជាទាហាន ។ បទថា **ន រាជបោរិសេន** (មិនបានស្វែងរកដោយភាពជារាជបុរស) បានដល់ មិនមែនឲ្យកើតឡើងដោយភាពជាអ្នករាជការ ។

បទថា **កេវលំ ភិក្ខាចរិយាយ** (ដើម្បីភិក្ខាប៉ុណ្ណោះ) បានដល់ សម្រាប់ភិក្ខាចារដ៏បរិសុទ្ធ (សុទ្ធៗ) ប៉ុណ្ណោះ ។ បទថា **កបាលំ អនតិ-**

មញ្ញមានោ (ពេញចិត្តនឹងអំបែង) បានដល់ មិនមើលងាយភាជនៈសម្រាប់សូម ។ ក៏ព្រាហ្មណ៍នោះ កាន់យកភាជនៈសម្រាប់សូម ដាក់ទឹកពេញហើយលាបសីសៈ ឈរនូវត្រង់ទ្វាររបស់ត្រកូលទាំងឡាយស្រែកសូមថា ខ្ញុំប្រព្រឹត្តកោមារព្រាហ្មណ៍ (ជាកំលោះ) មកអស់ ៤៨ ឆ្នាំ ទាំងមន្តក៏ខ្ញុំរៀនហើយ ខ្ញុំនឹងឲ្យទ្រព្យបូជាអាចារ្យដល់អាចារ្យ សូមលោកទាំងឡាយចូលឲ្យទ្រព្យដល់ខ្ញុំចុះ ។ ពួកមនុស្សបានស្តាប់ដូច្នោះ ខ្លះឲ្យទ្រព្យ ៨ កហាបណៈ ខ្លះ ១៦ កហាបណៈ ខ្លះ ១០០ កហាបណៈ តាមការអាចនឹងឲ្យបាន តាមកម្លាំង ។ ព្រាហ្មណ៍នោះត្រាច់ទៅសូមទូទាំងស្រុកយ៉ាងនេះ ទើបប្រគល់ទ្រព្យដែលបានឲ្យដល់អាចារ្យ ។ ពាក្យនេះត្រាស់សំដៅដល់ភាជនៈនោះ ។

បទថា **ឯវំ ខោ ទោណ ព្រាហ្មណោ ព្រហ្មសមោ ហោតិ** (ទោណៈ ព្រាហ្មណ៍ដែលស្មើដោយព្រហ្មយ៉ាងនេះឯង) សេចក្តីថា ព្រាហ្មណ៍ឈ្មោះថា ជាអ្នកស្មើដោយព្រហ្ម ព្រោះប្រកបដោយព្រហ្មវិហារយ៉ាងនេះ ។ បទថា **នេវ កយេន ន វិក្កយេន** (មិនស្វែងរកដោយការទិញ ដោយការលក់) បានដល់ មិនមែនខ្លួនឯងទិញមក មិនមែនដទៃលក់ឲ្យ ។ បទថា **ឧទកូ-**

បសន្ធំ (ដែលគេឲ្យដោយប្រោះទឹក) បានដល់ ដែលគេប្រោះទឹកហើយឲ្យ ។ ក៏ព្រាហ្មណ៍ទាំងនោះទៅឈរត្រង់ទ្វាររបស់ត្រកូល ដែលមានស្រីក្រមុំវ័យជំទង់ កាលគេសួរថា លោកឈរទីនេះធ្វើអ្វី ។ ក៏ឆ្លើយថា ខ្ញុំប្រព្រឹត្តកោមារព្រហ្មចារ្យមកអស់ ៤៨ ឆ្នាំ ខ្ញុំនឹងឲ្យវត្តគ្រប់យ៉ាងដល់លោក សូមលោកឲ្យស្រីក្រមុំដល់ខ្ញុំចុះ ។ ពួកគេនាំស្រីក្រមុំមក ហើយស្រោចទឹកដាក់លើដៃរបស់ព្រាហ្មណ៍នោះ ហើយនាំយកទៅ ។ ព្រាហ្មណ៍នោះ ទទួលយកស្រីក្រមុំដែលគេស្រោចទឹកឲ្យជាភរិយា ហើយក៏ត្រឡប់ទៅ ។

បទថា **អតិមិឡ្ហជោ** (កើតក្នុងគំនរលាមក) បានដល់ កើតក្នុងទីកខ្វក់ គឺ ក្នុងគំនរលាមកធំ ។ បទថា **តស្សស្ស** កាត់បទជា **តស្ស** ឯតស្ស ។ បទថា **ន ទវត្ថា** (មិនមែនប្រយោជន៍ដល់ការលេង) បានដល់ មិនមែនត្រូវការលេង។ បទថា **ន រតត្ថា** (មិនមែនត្រូវការសេចក្តីត្រេកអរ) បានដល់ មិនមែនត្រូវការសេចក្តីរីករាយក្នុងកាម។ បទថា **មេថុនំ ឧប្បាទេត្វា** (មានបុត្រ ឬធីតាហើយ) បានដល់ ព្រាហ្មណ៍ញ៉ាំងធីតាឲ្យកើត ឬបង្កើតបុត្រហើយគិតថា ឥឡូវនេះ ប្រពៃណីនឹងជាប់តទៅ ទើបចេញបួស ។

បទថា *សុគតឹ សគ្គំ លោកំ* (ក៏ទៅកើតក្នុងសុគតិ សួគ៌ទេវលោក) នេះ ត្រាស់សំដៅដល់ព្រហ្មលោកប៉ុណ្ណោះ ។ បទថា *ទេវសមោ ហោតិ* (ជាអ្នកស្មើដោយទេវតា) បានដល់ ឈ្មោះថា ជាអ្នកស្មើដោយទេវតា ព្រោះប្រកបដោយទិព្វវិហារធម៌ ។ បទថា *តមេវ បុត្តស្សាទំ និកាមយមានោ* (ប្រាថ្នាសេចក្ដីត្រេកអរក្នុងបុត្រ ឬធីតានោះឯង) សេចក្ដីថា ព្រាហ្មណ៍ប្រាថ្នា គឺ ត្រូវការសេចក្ដីស្រលាញ់ក្នុងបុត្រ សេចក្ដីពេញចិត្តក្នុងបុត្រដែលកើតឡើង ព្រោះឃើញធីតា ឬបុត្រដែលកើតហើយ ។ បទថា *កុដុម្ពំ អជ្ឈាវសតិ* (គ្រប់គ្រងទ្រព្យសម្បត្តិ) បានដល់ នៅក្នុងកណ្ដាលទ្រព្យសម្បត្តិ ។ បទដ៏សេសក្នុងសូត្រនេះ ងាយយល់ហើយ ។

ចប់អដ្ឋកថា ទោណសូត្រទី ២

# អដ្ឋកថា សង្គារវសូត្រទី ៣

## (សង្គារវព្រាហ្មណ៍សួរហេតុនៃមន្តដែលប្រាកដ)

គប្បីជ្រាបវិនិច្ឆ័យក្នុង សង្គារវសូត្រទី ៣ ដូចតទៅនេះ ៖

[៩៣] បទថា **បគេវ** (មិនត្រូវពោលដល់) បានដល់ មុនអំពីនោះ តែម្យ៉ាង ។ បទថា **កាមរាគបរិយុដ្ឋិតេន** (ត្រូវកាមរាគរួបរឹត) បានដល់ ត្រូវកាមរាគចងទុក ។ បទថា **កាមរាគបរេតេន** (កាមរាគៈគ្របសង្កត់ហើយ) បានដល់ ត្រូវកាមរាគៈជាប់តាម ។

បទថា **និស្សរណំ** (ធម៌ជាគ្រឿងរលាស់ចេញ) សេចក្តីថា ការរលាស់ចេញនូវកាមរាគៈមាន ៣ យ៉ាង គឺ ការរលាស់ចេញដោយការគ្របសង្កត់ ១ ការរលាស់ចេញទៅដោយអង្គនោះៗ ១ ការរលាស់ចេញដាច់ជាសមុច្ឆេទ ១ ។ ក្នុង ៣ យ៉ាងនោះ បឋមឈានក្នុងអសុភកម្មដ្ឋាន ឈ្មោះថា ការរលាស់ចេញដោយការគ្របសង្កត់ ។ វិបស្សនា ឈ្មោះថា ការរលាស់ចេញដោយអង្គនោះៗ អរហត្តមគ្គ ឈ្មោះថា ការរលាស់ចេញដោយដាច់ជាសមុច្ឆេទ ។ អធិប្បាយថា រមែងមិនដឹងការរលាស់ចេញសូម្បី

ទាំង ៣ យ៉ាងនោះ ។

ក្នុងបទថា **អត្តត្ថម្បិ** (នូវប្រយោជន៍របស់ខ្លួន) ជាដើម ប្រយោជន៍របស់ខ្លួនឯង បានដល់ ព្រះអរហត្ត ឈ្មោះថា **ប្រយោជន៍ខ្លួន** ប្រយោជន៍របស់អ្នកឲ្យបច្ច័យ ឈ្មោះថា **ប្រយោជន៍អ្នកដទៃ** ប្រយោជន៍សូម្បីទាំងពីរនោះឯង ឈ្មោះថា **ប្រយោជន៍ទាំងពីរ** គប្បីជ្រាបសេចក្តីក្នុងគ្រប់វារៈដោយន័យនេះឯង ។

តែគប្បីជ្រាបសេចក្តីផ្សេងគ្នាដូចតទៅ ។ ពិតណាស់ ក្នុងបទមានជាអាទិ៍ថា (ព្យាបាទស្ស និស្សរណំ (នូវធម៌ជាគ្រឿងរលាស់ចេញព្យាបាទ) ការរលាស់ចេញមាន ២ យ៉ាង គឺ ការរលាស់ចេញដោយការគ្របសង្កត់ និងការរលាស់ចេញដោយដាច់ជាសមុច្ឆេទ ។ ក្នុងពីរយ៉ាងនោះ ចំពោះព្យាបាទ មេត្តាបឋមឈាន ឈ្មោះថា ការរលាស់ចេញដោយការគ្របសង្កត់ទុក ។ អនាគាមិមគ្គ ឈ្មោះថា ការរលាស់ចេញដោយដាច់ជាសមុច្ឆេទ ឯថីនមិទ្ធៈ អាលោកសញ្ញា ឈ្មោះថា ការរលាស់ចេញដោយការគ្របសង្កត់ អរហត្តមគ្គ ឈ្មោះថា ការរលាស់ចេញទៅដោយដាច់ជាសមុច្ឆេទ ។ ឧទ្ធច្-

កុក្កុច្ចៈ សមថៈណាមួយ ឈ្មោះថា ការរលាស់ចេញដោយការគ្របសង្កត់ តែក្នុងឧទ្ធច្ចកុក្កុច្ចៈនេះ ឧទ្ធច្ចៈ អរហត្តមគ្គ ឈ្មោះថា ការរលាស់ចេញដោយដាច់ជាសមុច្ឆេទ , ចំណែកកុក្កុច្ចៈ អនាគាមិមគ្គ ឈ្មោះថា ការរលាស់ចេញដោយដាច់ជាសមុច្ឆេទ ។ វិចិកិច្ឆា ការកំណត់ធម៌ (វិបស្សនា) ឈ្មោះថា ការរលាស់ចេញដោយការគ្របសង្កត់ បឋមមគ្គ ឈ្មោះថា ការរលាស់ចេញដោយដាច់ជាសមុច្ឆេទ ។

ក៏ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ការឧបមាពួកណា មានជាអាទិ៍ថា សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ សំសដ្ឋោ លាខាយ វា (ប្រៀបដូចភាជនៈពេញដោយទឹកដែលលាយច្រឡំដោយល័ខ) ក្នុងឧបមាប៉ុណ្ណោះ ។ បទថា ឧទបត្តោ (ភាជនៈដែលពេញដោយទឹក) បានដល់ ភាជនៈពេញដោយទឹក ។ បទថា សំសដ្ឋោ (លាយច្រឡំ) បានដល់ លាយដោយពណ៌ប្រភេទផ្សេងៗ ។ បទថា ឧក្កដ្ឋិតោ (ក៏ពុះឡើងចំហាយ) បានដល់ ពុះហើយ ។ បទថា ឧស្សទកជាតោ (មានចំហាយ) បានដល់ មានចំហាយទឹកក្ដៅ ។ បទថា សេវាលបណកបរិយោនទ្ធោ (ដែលសារាយ និងចក

**រួបរីត)** បានដល់ បិទបាំងដោយសារាយ មានប្រភេទជាពូជល្វជាដើម ឬចកមានពណ៌ខៀវ និងពណ៌ដូចខ្នងកង្កែប ដែលកើតឡើងបិទបាំងសម្បុរទឹក ។ បទថា **វាតេរិតោ** (ត្រូវខ្យល់បក់) បានដល់ ត្រូវខ្យល់បក់បោក ។ បទថា **អាវិលោ** (ល្អក់) បានដល់ គឺ មិនថ្លា ។ បទថា **លុឡិតោ** (វក់វី) បានដល់ មិនស្ងៀម ។ បទថា **កលលីភូតោ** (ជាដើម) គឺ មានសំបកដើម ។ បទថា **អន្ធការេ និក្ខិត្តោ** (ដែលគេទុកក្នុងទីងងឹត) បានដល់ ត្រូវដំកល់ទុកក្នុងទីមិនមានពន្លឺ (ងងឹត) ដូចខាងក្នុងជង្រុកស្រូវជាដើម ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគទ្រង់សំដែងបញ្ញាសអំពីភព ៣ ហើយទ្រង់បញ្ចប់ដោយកំពូលធម៌ គឺ ព្រះអរហត្ត ។ ចំណែកព្រាហ្មណ៍តាំងនៅក្នុងគុណត្រឹមតែដល់សរណៈ ។

ចប់អដ្ឋកថា សង្គារវសូត្រទី ៣

# អដ្ឋកថាការណបាលីសូត្រទី ៤

## (ហេតុដែលការណបាលីព្រាហ្មណ៍ជ្រះថ្លា)

គប្បីជ្រាបវិនិច្ឆ័យក្នុង ការណបាលីសូត្រទី ៤ ដូចតទៅនេះ ៖

[៩៤] បទថា **ការណបាលី** ជាឈ្មោះរបស់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍ឈ្មោះ ការណបាលិ ព្រោះបង្គាប់ឲ្យធ្វើការងារក្នុងរាជដំណាក់ ។ បទថា **កម្មន្តំ ការេតិ** (ប្រើមនុស្សឲ្យធ្វើការងារ) សេចក្តីថា ការណបាលីព្រាហ្មណ៍ក្រោកអំពីព្រឹកព្រលឹម ឲ្យគេធ្វើទ្វារបន្ទាយ និងកំពែង ដែលនៅមិនទាន់បានធ្វើ ឲ្យគេជួសជុលចំណែកដែលទ្រុឌទ្រោម ។

បទថា **បិង្គិយានី ព្រាហ្មណំ** (បង្គិយានិព្រាហ្មណ៍) បានដល់ ព្រាហ្មណ៍ដែលជាអរិយសាវក ដែលតាំងនៅក្នុងអនាគាមិផល មានឈ្មោះយ៉ាងនេះ ។ បានឮថា ព្រាហ្មណ៍នោះក្រោកអំពីព្រឹកព្រលឹម ឲ្យកាន់យកគ្រឿងក្រអូប និងផ្កាឈើជាដើម ទៅគាល់ព្រះសាស្ដា ថ្វាយបង្គំហើយ បូជាដោយផ្កាឈើជាដើម ហើយទើបចូលទៅកាន់ក្រុង នេះជាកិច្ចវត្តប្រចាំថ្ងៃរបស់ព្រាហ្មណ៍នោះ ។ ការណបាលីព្រាហ្មណ៍នោះ បានឃើញបិង្គិយានិព្រាហ្មណ៍ ធ្វើ

កិច្ចវត្តយ៉ាងនោះហើយ កំពុងដើរមក ។

បទថា ឯតទវោច (បានសួរ) សេចក្តីថា ការណបាលីព្រាហ្មណ៍គិតថា ព្រាហ្មណ៍នេះមានបញ្ញា មានញាណខ្ពង់ខ្ពស់ ទៅណា មកទាំងព្រឹកហ្ន៎ ដឹងត្រឹមតែថា ព្រាហ្មណ៍ដើរចូលមកជិតដោយលំដាប់ហើយ ទើបបានពោលពាក្យមានជាអាទិ៍ថា ហន្ទ កុតោ (មកពីណាហ្ន៎) ។ ក្នុងបទទាំងនោះបទថា ទិវា ទិវស្ស (ក្នុងវេលាថ្ងៃត្រង់) បានដល់ កណ្តាលថ្ងៃត្រង់ អធិប្បាយថា ថ្ងៃត្រង់ ។

បទថា បណ្ឌិតោ មញ្ញេតិ[១] (ព្រះអង្គនឹងឃើញថាជាបណ្ឌិតឬ) បានដល់ មានសេចក្តីដូច្នេះថា បិង្គិយានី រមែងសម្គាល់ព្រះសមណគោតមថា ជាបណ្ឌិតឬមិនមែនហ្ន៎ ។ បទថា កោ ចាហម្ភោ (ខ្ញុំជានរណា) បានដល់ លោកដ៏ចម្រើន ខ្ញុំឈ្មោះថាជានរណាហ្ន៎ នឹងអាចដឹងនូវសេចក្តីឈ្លាសវៃនៃព្រះបញ្ញារបស់ព្រះសមណគោតមបាន ។ បទថា កោ ច សមណស្ស គោតមស្ស បញ្ញាវេយ្យត្តិយំ ជានិស្សាមិ (ខ្ញុំនឹងដឹងក្នុងការឈ្លាសវៃចំពោះ

(១) អដ្ឋកថា = បណ្ឌិតោ មញ្ញតិ ។

ប្រាជ្ញារបស់ព្រះសមណគោតមដូចម្ដេចបាន) សេចក្ដីថា បិង្គិយានិព្រាហ្មណ៍សំដែងការមិនដឹងរបស់ខ្លួន សូម្បីដោយប្រការទាំងពួងយ៉ាងនេះថា ខ្ញុំនឹងដឹងការឈ្លាសវៃនៃព្រះបញ្ញារបស់ព្រះសមណគោតមបានអំពីណា គឺ ខ្ញុំនឹងដឹងបានដោយហេតុណាហ្ន៎ ។

បទថា នូនស្ស តាទិសោវ (សូម្បីបុគ្គលនោះស្រដៀងគ្នានឹងព្រះសមណគោតមដោយពិត) បិង្គិយានិព្រាហ្មណ៍ពោលថា បុគ្គលណាគប្បីដឹងដល់ការឈ្លាសវៃនៃព្រះបញ្ញារបស់ព្រះសមណគោតម បុគ្គលនោះក៏ត្រូវបំពេញបារមី ១០ សម្រេចព្រះសព្វញ្ញុតញ្ញាណ ទើបគប្បីដូចព្រះសមណ-គោតម គឺ ជាព្រះពុទ្ធអង្គទ្រង់ឯង ។ បុគ្គលបំណងនឹងវាស់ភ្នំសិនេរុក្ដី ផែនដីក្ដី អាកាសក្ដី គប្បីបានឈើវាស់ ឬខ្សែស្មើនឹងភ្នំសិនេរុ ផែនដី និងអាកាសនោះ សូម្បីគេដឹងបញ្ញារបស់ព្រះសមណគោតម ក៏គប្បីនឹងបានព្រះសព្វញ្ញុតញ្ញាណដូចព្រះញាណរបស់ព្រះអង្គដូចគ្នា ។ ក៏ក្នុងសូត្រនេះ បិង្គិយានិព្រាហ្មណ៍ ពោលដដែលៗ ដោយសេចក្ដីអើពើ ។

បទថា ឧឡារាយ (ដ៏លើសលុប) បានដល់ ខ្ពស់បំផុត គឺ ប្រសើរ

បំផុត ។ បទថា កោ ចាហម្ភោ (ខ្ញុំជានរណា) បានដល់ លោកដ៏ចម្រើន ខ្ញុំឈ្មោះថាជានរណាហ្ន៎ ក្នុងការដែលសរសើរព្រះសមណគោតម ។ បទថា កោ ច សមណំ គោតមំ បសំសិស្សាមិ (និងហេតុអ្វី ទើបសរសើរព្រះសមណគោតម) បានដល់ ខ្ញុំនឹងសរសើរដោយហេតុអ្វី ។

បទថា បសត្ថប្បសត្ថោ (គុណរបស់ព្រះអង្គប្រសើរក្រៃពេក) សេចក្តីថា គុណទាំងឡាយរបស់ព្រះអង្គ ដែលមនុស្សលោកទាំងពួងសរសើរហើយ ដែលប្រសើរលើលោកទាំងឡាយ សរសើរហើយ មិនចាំបាច់ត្រូវសរសើរព្រះអង្គដោយគុណដទៃៗ ។ ដូចផ្កាចម្ប៉ាក្តី ឧប្បលក្តី បទុមក្រហមក្តី ចន្ទក្រហមក្តី ជារបស់ស្រស់ស្អាត និងមានក្លិនក្រអូប ដោយសិរី គឺពណ៌ និងក្លិនប្រចាំខាងក្នុងវានោះឯង មិនចាំបាច់សរសើរផ្កាឈើនោះដោយពណ៌ និងក្លិនដែលផ្សាយចេញមកខាងក្រៅ យ៉ាងណា ដូចជាកែវមណីក្តី ព្រះចន្ទក្តី រមែងបង្ហាញរូបកាយដោយពន្លឺរបស់ខ្លួនឯង កែវមណី និងព្រះច័ន្ទនោះ ក៏មិនចាំបាច់បង្ហាញកាយដោយពន្លឺដទៃ យ៉ាងណា ព្រះសមណគោតម ក៏ដូច្នោះ ដែលគុណរបស់ព្រះអង្គ ដែលមនុស្សទាំងឡាយសរសើរ

ហើយនុ៎ះឯង សរសើរឲ្យដល់ភាពជាបុគ្គលប្រសើរបំផុតលើលោកទាំងពួង មិនចាំបាច់សរសើរព្រះអង្គដោយគុណដទៃ ៗ ន័យម្យ៉ាងទៀត ឈ្មោះថា សរសើរក្រៃពេកហើយ សូម្បីព្រោះបានទទួលការសរសើរ បានសរសើរហើយ ។ ក៏នរណាឈ្មោះថា អ្នកបានទទួលការសរសើរ ។ ព្រះបាទបសេនទិកោសលអ្នកដែនកាសី និងអ្នកដែនកោសលសរសើរហើយ ព្រះបាទពិម្ពិសារអ្នកដែនអង្គៈ និងមគធៈសរសើរហើយ ក្សត្រិយ៍លិច្ឆវីក្រុងវេសាលី អ្នកដែនវជ្ជីសរសើរហើយ មល្លក្សត្រិយ៍ក្នុងក្រុងបាវា មល្លក្សត្រិយ៍ក្នុងក្រុងកុសិនារា ក្សត្រិយ៍នោះៗ សូម្បីពួកដទៃអ្នកស្រុកជនបទនោះៗ សរសើរហើយ , ព្រាហ្មណ៍ មានចង្កីព្រាហ្មណ៍ជាដើម ដែលពួកព្រាហ្មណ៍សរសើរហើយ , ឧបាសក មានអានាថបណ្ឌិកសេដ្ឋីជាដើម ដែលពួកឧបាសកសរសើរហើយ , ឧបាសិកា មាននាងវិសាខាជាដើម ដែលឧបាសិកាច្រើនរយសរសើរហើយ , បរិព្វាជក មានសកុឡុទាយីជាដើម ដែលបរិព្វាជកច្រើនរយសរសើរហើយ , មហាសាវិកា មានឧប្បលវណ្ណាថេរីជាដើម ដែលភិក្ខុនីច្រើនរយសរសើរហើយ , ព្រះមហាថេរៈ មានព្រះ

សារីបុត្តជាដើម ដែលភិក្ខុច្រើនរយសរសើរហើយ , ទេវតា មានសក្កទេវរាជជាដើម ដែលពពួកទេវតាច្រើនពាន់សរសើរហើយ , ព្រហ្ម មានស្តេចមហាព្រហ្មជាដើម ដែលព្រហ្មច្រើនពាន់សរសើរហើយ មនុស្ស និងទេវតាសូម្បីទាំងអស់នោះ ក៏សរសើរនូវគុណរបស់ព្រះទសពលដ៏យ៉ាងក្រៃលែង ។ ព្រះមានព្រះភាគ លោកហៅថា *គុណរបស់ព្រះអង្គប្រសើរពន់ពេកហើយ* ដោយប្រការដូច្នេះ ។

បទថា *អត្ថវសំ (អំណាចប្រយោជន៍)* គឺ អំណាចនៃប្រយោជន៍ទាំងឡាយ ។ គ្រានោះ បិង្គិយានិព្រាហ្មណ៍កាលពោលដល់ហេតុដែលខ្លួនជ្រះថ្លាដល់ការណបាលិព្រាហ្មណ៍នោះ ទើបពោលពាក្យថា *សេយ្យថាបិ ភោ បុរិសោ (ម្នាលអ្នកដ៏ចម្រើន ប្រៀបដូចបុរស)* ជាដើម ។ ក្នុងបទថា *អគ្គរសបរិតិត្តោ (អ្នករីករាយក្នុងរសដ៏ប្រសើរហើយ)* សេចក្តីថា ឈ្មោះថា រសប្រសើរមានជាអាទិ៍យ៉ាងនេះ គឺ បណ្តារសភោជន រសបាយាសប្រសើរជាង , បណ្តាដែលជាប្រភេទទឹក មានទឹកដោះថ្លាប្រសើរជាង ។ បណ្តាលរសចត់ ទឹកឃ្មុំរបស់សត្វតូចៗ⁽¹⁾ ដែលមិនមានវត្ថុលាយឡំ

បណ្ដាលរសផ្អែម ទឹកត្នោតប្រសើរជាង ។ អ្នកពេញចិត្តក្នុងរសទាំងនោះណាមួយ គឺ បរិភោគមានបរិមាណដល់កទើបឈប់ ។ បទថា **អញ្ញេសំ ហីនានំ (រសដទៃដែលថោកទាប)** បានដល់ រសដ៏ថោកទាបដទៃ ឬរសដែលប្រសើរលើស ។ បទថា **សុត្តសោ (ដោយសុត្តៈ)** បានដល់ ដោយសូត្រ អធិប្បាយថា ដោយបានស្ដាប់មក ។ បទថា សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ បទថា **តតោ តតោ (ដោយលក្ខណៈនោះៗ)** បានដល់ ដោយសត្ថុសាសន៍ មានសុត្តៈជាដើមនោះៗ ។ បទថា **ន អញ្ញេសំ បុថុស្សមណប្បវាទានំ (វាទៈរបស់ពួកសមណៈច្រើនពួកដទៃ)** បានដល់ មិនពេញចិត្ត មិនប្រាថ្នា ពាក្យទូន្មានដែលជាលទ្ធិរបស់សមណៈព្រាហ្មណ៍ដទៃជាច្រើន មិនប្រាថ្នានឹងស្ដាប់វាទៈទាំងនោះ ដែលសមណព្រាហ្មណ៍និយាយ ។ បទថា **ជិឃច្ឆាទុព្វល្យបរេតោ (ត្រូវសេចក្ដីស្រេកឃ្លាន និងការទន់កម្លាំងគ្របសង្កត់)** បានដល់ ត្រូវសេចក្ដីស្រេកឃ្លាន និងសេចក្ដីថយកម្លាំងគ្របសង្កត់ ។

បទថា **មធុបណ្ឌិកំ (សំបុកឃ្មុំ)** បានដល់ នំសត្ថុដុំដែលគេលីង

ស្រូវសាលីឲ្យជាលាច ហើយលាយដោយរសផ្អែម ៤ យ៉ាង ឬទំផ្អែមនោះឯង ។ បទថា **អធិគច្ឆេយ្យ (គប្បីបាន)** បានដល់ គប្បីបានទទួល ។ បទថា **អសេចនកំ (មិនលាយឡំ)** បានដល់ មានរសប្រណីតឆ្ងាញ់ មិនលាយដោយរសដទៃដើម្បីធ្វើឲ្យផ្អែម ។ បទថា **ហរិចន្ទនស្ស (នៃចន្ទន៍លឿង)** បានដល់ នៃឈើចន្ទន៍ពណ៌លឿងដូចមាស ។ បទថា **លោហិតចន្ទនស្ស (នៃចន្ទន៍ក្រហម)** បានដល់ ឈើចន្ទន៍ពណ៌ក្រហម ។ បទថា **សុរភិគន្ធំ (ក្លិនក្រអូបល្អ)** បានដល់ មានក្លិនក្រអូប ។ ក៏ **សេចក្តីក្រវល់ក្រវាយ** ជាដើម បានដល់ សេចក្តីក្រវល់ក្រវាយព្រោះវដ្តៈ សេចក្តីលំបាកព្រោះវដ្តៈ នឹងសេចក្តីក្តៅក្រហាយព្រោះវដ្តៈនោះឯង ។

បទថា **ឧទានំ ឧទានេសិ (បន្លឺនូវឧទាន)** បានដល់ បន្លឺនូវឧទាន ។ ដូចប្រេងឯណាដែលមិនអាចនឹងជួសបាន ក៏រមែងហូរទៅ ប្រេងនោះហៅថា *អវសេកៈ (ហៀរចេញ)* ទឹកណាមិនអាចនឹងឃាំងទុកក្នុងស្រះបាន ក៏ហូរចេញទៅ ទឹកនោះលោកហៅថា **ឱឃៈ** *(អន្លង់ទឹក)* យ៉ាងណា ពាក្យណាដែលប្រកបដោយបីតិ មិនអាចនឹងរក្សាទុកក្នុងចិត្តបាន មានច្រើនពេក តាំង

នៅមិនបានក្នុងខាងក្នុង ក៏ចេញទៅខាងក្រៅ ពាក្យដែលប្រកបដោយបីតិនោះ ហៅថា ឧទាន ក៏ដូច្នោះ ។ អធិប្បាយថា ការណបាលីព្រាហ្មណ៍បន្លឺពាក្យដែលសម្រេចដោយបីតិបែបនេះ ។

ចប់អដ្ឋកថា ការណបាលិសូត្រទី ៤

# អដ្ឋកថា បង្គិយានីសូត្រទី ៥

## (បង្គិយានីព្រាហ្មណ៍ជាហេតុឲ្យត្រាស់រតនៈ)

គប្បីជ្រាបវិនិច្ឆ័យក្នុង បង្គិយានីសូត្រទី ៥ ដូចតទៅនេះ ៖

[៩៥] បទថា **នីលា** (ខៀវ) នេះ រួមពណ៌ខៀវទុកទាំងអស់ ។ បទថា **នីលវណ្ណា** (មានសម្បុរខៀវ) ជាដើម សំដែងការចែកពណ៌ខៀវនោះឯង ។ បទថា **មានសម្បុរខៀវ** នោះ សម្បុរតាមប្រក្រតីរបស់ក្សត្រិយ៍លិច្ឆវីទាំងនោះមិនខៀវ តែលោកពោលពាក្យនោះ ព្រោះក្សត្រិយ៍ទាំងនោះលាបដោយគ្រឿងលាបពណ៌ខៀវ ។ បទថា **នីលវត្ថា** (មានសំពត់ខៀវ) បានដល់ សូម្បីសំពត់សាច់ល្អ សំពត់ថ្មីជាដើម របស់ក្សត្រិយ៍ទាំងនោះក៏មានពណ៌ខៀវទាំងអស់ ។ បទថា **នីលាលង្ការ** (មានគ្រឿងប្រដាប់ខៀវ) បានដល់ ប្រដាប់ដោយកែវមណីខៀវ និងផ្កាឈើខៀវ សូម្បីគ្រឿងប្រដាប់ដំរី គ្រឿងប្រដាប់សេះ គ្រឿងប្រដាប់រថ រាំងនន ពិដាន និងសំលៀកបំពាក់របស់ក្សត្រិយ៍ទាំងនោះក៏ខៀវទាំងអស់ ។ គប្បីជ្រាបសេចក្តីក្នុងបទទាំងពួងដោយន័យនេះ ។

បទថា **បទុមំ យថា** (ដូចផ្កាឈូក) បានដល់ ដូចផ្កាបទុមពណ៌ក្រហម មាន ១០០ ត្របក ។ បទថា **កោកនុទំ** (ឈ្មោះកោកនុទ) ជាវេវចនៈរបស់ពាក្យថា **ផ្កាឈូក** នោះឯង ។ បទថា **បាតោ** (រីកអំពីព្រឹក) បានដល់ ព្រឹកព្រលឹម គឺ ក្នុងវេលាព្រះអាទិត្យរះឡើង ។ បទថា **សិយា** (អាស្រ័យ) បានដល់ គប្បីអាស្រ័យ ។ បទថា **អវីតគន្ធំ** (មិនប្រាសចាកក្លិន) បានដល់ មិនប្រាសចាកអំពីក្លិន ។ បទថា **អង្គីរសំ** (រស្មីផ្សាយចេញពីព្រះអង្គ) សេចក្តីថា ព្រះរស្មីផ្សាយចេញអំពីព្រះវរកាយតូចធំរបស់ព្រះមានព្រះភាគ ព្រោះដូច្នោះ ទើបហៅព្រះអង្គីរស ។ បទថា **តបន្តមាទិច្ច-មិវន្តលិក្ខេ** (ដូចព្រះអាទិត្យបញ្ចេញរស្មីក្នុងកណ្តាលពពក) សេចក្តីថា ទ្រង់រុងរឿងដូចព្រះអាទិត្យបញ្ចេញពន្លឺក្នុងអាកាស អាចបំភ្លឺក្នុងទ្វីបធំទាំង ៤ ដែលមានទ្វីបតូច ២.០០០ ជាបរិវារ ។ បង្គិយានីព្រាហ្មណ៍ពោលយ៉ាងនេះថា **សូមលោកមើលព្រះអង្គីរស** សំដៅដល់ខ្លួនឯងប៉ុណ្ណោះ ឬមហាជនក៏បាន ។

ចប់អដ្ឋកថា បង្គិយានីសូត្រទី ៥

# អដ្ឋកថា សុបិនសូត្រទី ៦

## (មហាសុបិន ៥ ប្រការ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុបិនសូត្រទី ៦ ដូចតទៅនេះ ៖*

[៩៦] *បទថា* ***មហាសុបិនា (មហាសុបិន)*** *សេចក្តីថា ឈ្មោះថា មហាសុបិន ព្រោះបុរសដែលធំគប្បីយល់សប្តិ នឹងព្រោះភាពជានិមិត្តនៃប្រយោជន៍ដ៏ធំ ។ បទថា* ***បាតុរហេសុំ (ប្រាកដ)*** *បានដល់ បានប្រាកដហើយ។*

*ក្នុងការយល់សប្តិនោះ អ្នកយល់សប្តិរមែងយល់សប្តិព្រោះហេតុ ៤ ប្រការ គឺ ព្រោះធាតុកម្រើក ១ ព្រោះធ្លាប់ឃើញមកអំពីមុន ១ ព្រោះទេវតាបណ្តាលចិត្ត ១ ព្រោះជាបុព្វនិមិត្ត ១ ។ ក្នុងហេតុទាំងនោះ មនុស្សធាតុកម្រើក ព្រោះប្រមាត់ជាដើម ជាហេតុធ្វើឲ្យកម្រើក រមែងយល់សប្តិព្រោះធាតុកម្រើក និងការយល់សប្តិ រមែងយល់សប្តិច្រើនយ៉ាង ដូចជាយល់សប្តិថា ធ្លាក់អំពីភ្នំ ទៅតាមអាកាស ត្រូវសត្វកាចមានដំរី និងចោរជាដើមដេញតាម ។ កាលយល់សប្តិ ព្រោះធ្លាប់ដឹង ធ្លាប់ឃើញ*

មកអំពីមុន រមែងយល់សប្តិដល់អារម្មណ៍ដែលធ្លាប់សោយមកហើយ ក្នុងកាលមុន ។ ឯបុគ្គលយល់សប្តិ ព្រោះទេវតាបណ្ដាលចិត្ត ពួកទេវតារមែងបណ្ដាលអារម្មណ៍ច្រើនយ៉ាង ព្រោះបំណងល្អក៏មាន ព្រោះបំណងអាក្រក់ក៏មាន បុគ្គលនោះរមែងយល់សប្តិឃើញអារម្មណ៍ទាំងនោះ ដោយអានុភាពរបស់ពួកទេវតាទាំងនោះ ។ កាលយល់សប្តិ ព្រោះជាបុព្វនិមិត្ត រមែងយល់សប្តិជាបុព្វនិមិត្តឲ្យកើតប្រយោជន៍ ឬមិនមានប្រយោជន៍ ដែលនឹងកើតឡើងដោយអំណាចបុណ្យ ឬបាប ដូចព្រះជននីរបស់ព្រះពោធិសត្វទ្រង់យល់សប្តិឃើញនិមិត្តក្នុងការបានព្រះឱរស ដូចព្រះបាទបសេនទិកោសល ទ្រង់យល់សប្តិឃើញហេតុសុបិន ១៦ និងដូចព្រះមានព្រះភាគព្រះអង្គនេះឯង កាលនៅជាព្រះពោធិសត្វ ទ្រង់យល់សប្តិឃើញមហាសុបិន ៥ ប្រការ ។

ក្នុងការយល់សប្តិទាំងនោះ យល់សប្តិព្រោះធាតុកម្រើក ព្រោះធ្លាប់ជួបប្រទះមកអំពីមុន រមែងជាការយល់សប្តិមិនពិត ។ យល់សប្តិ ព្រោះទេវតាបណ្ដាលចិត្ត ពិតខ្លះ មិនពិតខ្លះ ព្រោះថា ទេវតាទាំងឡាយក្រោធខឹង

ឡើង បំណាំងនឹងឲ្យដល់សេចក្តីវិនាស ដោយឧបាយ ទើបក្លែងធ្វើជាឲ្យខុសប្រក្រតី ។ តែយល់សប្តិព្រោះបុព្វនិមិត្ត ពិតដោយចំណែកមួយ ។ សូម្បីព្រោះការទាក់ទងជាមួយនឹងមូលហេតុទាំង ៤ យ៉ាងនេះផ្សេងគ្នា ទើបការយល់សប្តិផ្សេងគ្នា ។ ព្រះសេក្ខៈ និងបុថុជ្ជនប៉ុណ្ណោះ រមែងយល់សប្តិ ឃើញហេតុទាំង ៤ យ៉ាងនោះបាន ព្រោះលះវិបល្លាសមិនទាន់បាន ព្រះអសេក្ខៈមិនយល់សប្តិ ព្រោះលះវិបល្លាសបានហើយ ។

ក៏បុគ្គលកាលយល់សប្តិ ដេកយល់សប្តិ ឬភ្ញាក់យល់សប្តិ ឬថាមិនដេកមិនភ្ញាក់យល់សប្តិ ក៏ក្នុងសេចក្តីនេះ យ៉ាងណា ។ ប្រការដំបូង ប្រសិនបើថា ដេកយល់សប្តិ ក៏ខុសក្នុងអភិធម្ម ព្រោះថា សត្វរមែងដេកលក់ដោយភវង្គចិត្ត ភវង្គចិត្តនោះ មិនមានរូបនិមិត្តជាដើម ជាអារម្មណ៍ ឬមិនសម្បយុត្តដោយរាគៈជាដើម ប្រសិនបើភ្ញាក់ ក៏ខុសក្នុងព្រះវិន័យ ព្រោះថា អ្នកដែលភ្ញាក់យល់សប្តិ រមែងយល់សប្តិដោយចិត្ត ដែលជាសព្វោហារិក (ចិត្តប្រក្រតី) អាបត្តិកាលកន្លងល្មើសដោយចិត្តជាសព្វោហារិក នឹងប្រព្រឹត្តទៅជាអាបត្តិ សូម្បីកាលអ្នកយល់សប្តិ ធ្វើការប្រព្រឹត្តកន្លងនូវ

សិក្ខាបទ ក៏មិនជាអាបត្តិឡើយ បើមិនដេកលក់មិនភ្ញាក់ឡើង ឈ្មោះថា យល់សប្តិក៏មិនមែន ដូច្នេះ ការយល់សប្តិមិនមានឬ ។ មិនមែនមិនមានទេ ។ ព្រោះហេតុអ្វី ។ ព្រោះអ្នកដេកលក់ដូចស្វា រមែងយល់សប្តិ សមដូចដែលព្រះនាគសេនពោលទុកថា មហាបពិត្រ អ្នកដេកលក់ដូចស្វា រមែងយល់សប្តិ ។ បទថា **កបិមិទ្ធបរេតោ (អ្នកលក់ដូចស្វា)** បានដល់ ប្រកបដោយការដេកដូចស្វា ។ ដូចការដេកលក់របស់ស្វាមានការប្រែប្រួលលឿនយ៉ាងណា ការលក់ណា ឈ្មោះថា ប្រែប្រួលរហ័ស ព្រោះជ្រៀតជ្រែកដោយចិត្តមានកុសលចិត្តជាដើមរឿយៗ ក្នុងការប្រព្រឹត្តទៅនៃការលក់ណា ចិត្តរមែងផ្តាច់ពីភវង្គរឿយៗ បុគ្គលប្រកបដោយការដេកលក់នោះ រមែងយល់សប្តិ ដូច្នោះ ។

ព្រោះហេតុនោះ យល់សប្តិនេះ ទើបជាកុសលខ្លះ អកុសលខ្លះ អព្យាកតខ្លះ ។ ក្នុងការយល់សប្តិនោះ គប្បីជ្រាបថា ជាកុសល ដល់អ្នកយល់សប្តិថា ធ្វើការថ្វាយបង្គំព្រះចេតីយ៍ ស្តាប់ធម៌ និងសំដែងធម៌ជាដើម , ជាអកុសល ដល់អ្នកយល់សប្តិថា ធ្វើបាណាតិបាតជាដើម ក្រៅ

អំពីទាំងពីរយ៉ាងនោះ ជាអព្យាកត ក្នុងខណៈអាវជ្ជនៈចិត្ត និងខណៈត-ទាលម្ពណចិត្ត ។ យល់សប្តិទាំងអស់នោះ មិនអាចនាំបដិសន្ធិមកបាន ព្រោះចេតនាមានកម្លាំងខ្សោយ តែក្នុងបវត្តិកាល យល់សប្តិដែលជាកុសល និងអកុសលដទៃឧបត្ថម្ភហើយ រមែងឲ្យវិបាក ឲ្យវិបាកសូម្បីក៏ពិត តែចេតនាក្នុងការយល់សប្តិ ក៏ជាអព្វោហារិក (ពោលអាងមិនបាន) ព្រោះកើតក្នុងទីដែលមិនមែនជាវិស័យ ។

ក៏យល់សប្តិនោះ សូម្បីពោលដោយវេលា យល់សប្តិក្នុងវេលាថ្ងៃ រមែងមិនពិត ក្នុងបឋមយាម មជ្ឈិមយាម បច្ឆិមយាម ក៏ដូចគ្នា ។ តែពេលជិតភ្លឺ កាលអាហារដែលបរិភោគ ផឹក និងទំពារ រលួយល្អហើយ លុះឱជៈសម្រេចក្នុងរាងកាយហើយ ពេលអរុណរះឡើង ការយល់សប្តិ រមែងពិត ។ កាលយល់សប្តិមានឥដ្ឋារម្មណ៍ជានិមិត្ត រមែងបានឥដ្ឋារម្មណ៍ កាលយល់សប្តិមានអនិដ្ឋារម្មណ៍ជានិមិត្ត រមែងបានអនិដ្ឋារម្មណ៍ ។ ក៏មហាសុបិន ៥ ប៉ុណ្ណោះ លោកិយមហាជនមិនយល់សប្តិ មហារាជទាំងឡាយមិនយល់សប្តិ ស្តេចចក្រពត្តិទាំងឡាយមិនយល់សប្តិ អគ្គសាវកទាំង

ឡាយមិនយល់សប្តិ ព្រះបច្ចេកពុទ្ធទាំងឡាយមិនយល់សប្តិ ព្រះសម្មា-សម្ពុទ្ធទាំងឡាយក៏មិនយល់សប្តិ ព្រះសព្វញ្ញូពោធិសត្វតែមួយអង្គប៉ុណ្ណោះរមែងយល់សប្តិ ។

សួរថា ក៏ព្រះពោធិសត្វរបស់ពួកយើង ទ្រង់យល់សប្តិឃើញសុបិនទាំងនេះកាលណា ។ ឆ្លើយថា ទ្រង់យល់សប្តិវេលារាត្រីថ្ងៃ ១៤ កើត ដែលជាហេតុឲ្យទ្រង់ជ្រាបថា ព្រឹកនេះយើងនឹងត្រាស់ជាព្រះពុទ្ធ ។ អាចារ្យពួកខ្លះពោលថា ក្នុងវេលាថ្ងៃ ១៣ កើតក៏មាន ។ ព្រះអង្គទ្រង់យល់សប្តិឃើញសុបិន្តទាំងនេះឯង ទ្រង់ក្រោកឡើងប្រថាប់អង្គុយពត់ភ្នែន ទ្រង់ព្រះតម្រិះថា បើយើងឃើញសុបិនទាំងនេះក្នុងក្រុងកបិលវត្ថុ និងក្រាបទូលព្រះជនក ប្រសិនបើព្រះជននីរបស់យើងទ្រង់ព្រះជន្មនៅឡើយ យើងនឹងទូលព្រះជននី តែក្នុងទីនេះមិនមានអ្នកទាយសុបិន្តទាំងនេះបាន យើងនឹងទាយដោយខ្លួនឯង ។ ពេលនោះ ព្រះពោធិសត្វនោះ ទ្រង់ទាយសុបិនដោយព្រះអង្គឯងថា សុបិននេះ នឹងជាបុព្វនិមិត្តរបស់វត្ថុនេះ សុបិននេះនឹងជាបុព្វនិមិត្តរបស់វត្ថុនេះ ហើយសោយបាយបាយាស ដែលនាងសុជាតា

ថ្វាយក្នុងឧរុវេលគ្រាម ស្តេចឡើងកាន់មណ្ឌលព្រះពោធិព្រឹក្ស ទ្រង់សម្រេចសម្ពោធិញ្ញាណ ទ្រង់ប្រថាប់នៅក្នុងព្រះជេតពនតាមលំដាប់ ដើម្បីញ៉ាំងមហាសុបិន ៥ ដែលព្រះអង្គឃើញហើយ ក្នុងវេលាជាមកុឡពុទ្ធៈ (វេលាជាព្រះពុទ្ធដូចផ្កាក្រពុំផ្តើមនឹងរីកឡើង) ឲ្យពិស្តារ ទើបហៅភិក្ខុទាំងឡាយហើយទ្រង់ផ្តើមទេសនានេះ ។

ក្នុងបទទាំងនោះ បទថា **មហាបឋវី** (ផែនដីធំ) បានដល់ ផែនដីធំ តាំងនៅពេញផ្ទៃចក្រវាល ។ បទថា **មហាសយនំ អហោសិ** (ជាសយនៈដ៏ប្រសើរ) បានដល់ ជាទីសិរីសេយ្យាសន៍ ។ បទថា **ឱហិតោ** (សណ្តូកចុះ) បានដល់ ដំកល់ទុកហើយ ។ ក៏ព្រះហត្ថនោះ គប្បីជ្រាបថា មិនបានជ្រលក់ចុះក្នុងទឹក ដែលដាក់ទៅខាងលើៗ របស់មហាសមុទ្រទិសខាងលិចហើយដាក់ចុះក្នុងទីបំផុតនៃចក្រវាលទិសខាងលិច ។ សូម្បីក្នុងបទទាំងនេះថា **បច្ឆិមេ សមុទ្ទេ ទក្ខិណោ** (ក្នុងសមុទ្រខាងលិច ក្នុងសមុទ្រទិសខាងត្បូង) ក៏ន័យនេះដូចគ្នា ។

ព្រះអង្គត្រាស់ហៅថា ទព្វតិណៈ (គឹស្បូវ) ថា (**តិរិយា នាម**

តិណជាតិ (ស្បូវ) ។ បទថា នាភិយា ឧគ្គន្ត្វា នភំ អាហច្ច ឋិតា អហោសិ (បានឡើងពីនាភី... ទៅទល់នឹងអាកាសតាំងនៅ) សេចក្តីថា (ស្មៅ) មានស្មៅចិញ្ចៀនពណ៌ក្រហមប្រមាណប៉ុនដងនង្គ័ល ផុសឡើងអំពីព្រះនាភី (ផ្ចិត) កាលព្រះអង្គទតព្រះនេត្រហើយ ស្មៅចិញ្ចៀនក៏ដុះឡើងទៅៗ យ៉ាងនេះ គឺ ១ ចំអាម ១ ហត្ថ ១ យដ្ឋិ ១ គាវុត កន្លះយោជន៍ ១ យោជន៍ ហើយដុះឡើងរហូតដល់អាកាស ច្រើនពាន់យោជន៍ ។

បទថា បាទេហិ ឧស្សក្កិត្វា (បានវារឡើងមកតាមព្រះបាទ) បានដល់ វារឡើងមកតាមព្រះបាទតាំងពីចុងព្រះនខា ។ បទថា នានាវណ្ណា (មានពណ៌ផ្សេងៗ គ្នា) បានដល់ មានពណ៌ផ្សេងៗ គ្នាយ៉ាងនេះ គឺ មួយពណ៌ខៀវ មួយពណ៌លឿង មួយទៀតពណ៌ក្រហម មួយទៀតពណ៌ដូចស្លឹកឈើទុំ ។ បទថា សេតា (មានពណ៌ស) បានដល់ ពណ៌ស គឺ សទាំងអស់ ។

បទថា មហតោ មិឡ្ហបព្វតស្ស (ភ្នំលាមកធំ) បានដល់ ភ្នំពេញទៅដោយលាមកខ្ពស់ប្រមាណ ៣ យោជន៍ ។ បទថា ឧបរុបរិ ចង្កមតិ

(ដើរទៅមកលើ) បានដល់ ស្តេចចង្ក្រមលើកំពូលៗ ។ តែព្រះពុទ្ធទាំងឡាយដែលទ្រង់មានព្រះជន្មវែង នឹងប្រាកដដូចស្តេចចូលទៅប្រថាប់លើភ្នំដែលពេញទៅដោយលាមក ខ្ពស់ប្រមាណ ៣ យោជន៍ ។

ព្រះមានព្រះភាគ កាលទ្រង់សំដែងបុព្វនិមិត្ត ដោយឋានៈទាំងនេះយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សំដែងដល់វត្ថុដែលនឹងបានព្រម និងបុព្វនិមិត្តនោះ ទើបត្រាស់បទមានជាអាទិ៍ថា **យម្បិ ភិក្ខវេ** (ប្រការដែល) ។ ក្នុងបទនោះ ព្រះអរហត្តមគ្គរបស់ព្រះពុទ្ធទាំងឡាយ ឈ្មោះថា **អនុត្តរា សម្មាសម្ពោធិ** (ជាសម្មាសម្ពោធិញ្ញាណដែលមិនមានធម៌ដទៃក្រៃលែងជាង) ព្រោះឲ្យនូវគុណគ្រប់យ៉ាង ។ ព្រោះដូច្នោះ ព្រោះពោធិសត្វនោះ ទ្រង់បានឃើញផែនដីធំនៃចក្រវាឡនោះ ជាពូកដេកដ៏មានសិរី ផែនដីធំនៃចក្រ-វាឡនោះ ជាបុព្វនិមិត្តនៃភាពជាព្រះពុទ្ធ ។ ទ្រង់បានឃើញខ្នងភ្នំហិមពាន្តណាជាខ្នើយ ខ្នងភ្នំហិមពាន្តនោះ ជាបុព្វនិមិត្តនៃខ្នើយ គឺ ព្រះសព្វញ្ញុត-ញ្ញាណ ។ ទ្រង់បានឃើញព្រះហត្ថ និងព្រះបាទ ទាំង ៤ ដែលប្រតិស្ឋានលើកំពូលចក្រវាឡណា នោះជាបុព្វនិមិត្តនៃធម្មចក្រ (ការប្រកាសសំដែង

ធម្មចក្រ) ដែលនរណាៗ ជំទាស់មិនបាន ។ ទ្រង់បានឃើញព្រះអង្គផ្ទំផ្ងារ យ៉ាងណា នោះជាបុព្វនិមិត្តដែលសត្វទាំងឡាយ ផ្កាប់មុខនៅក្នុងភព ៣ នឹងផ្ងារមុខឡើង ។ ទ្រង់ដូចជាបើកព្រះនេត្រឃើញ យ៉ាងណា នោះជាបុព្វ-និមិត្តនៃការបានទិព្វចក្ខុ ។ លោកដែលប្រព្រឹត្តទៅ រហូតដល់ភវគ្គព្រហ្ម យ៉ាងណា នោះជាបុព្វនិមិត្តនៃអានាវរណញ្ញាណ (ញាណដែលមិនមានគ្រឿងរាំង) ។ បទដ៏សេសគប្បីជ្រាបដោយន័យនៃព្រះបាលីនោះឯង ។

ចប់អដ្ឋកថា សុបិនសូត្រទី ៦

# អដ្ឋកថា វស្សសុត្តទី ៧

## (អន្តរាយរបស់ភ្លៀង)

គប្បីជ្រាបវិនិច្ឆ័យក្នុង វស្សសុត្តទី ៧ ដូចតទៅនេះ ៖

[៩៧] បទថា **នេមិត្តា (អ្នកទាយនូវនិមិត្ត)** បានដល់ ជនអ្នកទាយនូវនិមិត្ត ។ បទថា **តេជោធាតុ បកុប្បតិ (តេជោធាតុ... កម្រើក)** បានដល់ ដុំភ្លើងធំកើតឡើង ។ បទថា **បាណិនា ឧទកំ បដិច្ឆិត្វា (យកបាតដៃត្រងទឹក)** បានដល់ លាតដៃទំហំប្រមាណ ៣០០ យោជន៍ ទទួលទឹកដែលមានឧតុជាសមុដ្ឋាន ដែលតាំងឡើងហើយ ។ បទថា **បមត្តា ហោន្តិ (ធ្វេសប្រហែស)** បានដល់ ជាអ្នកប្រមាទ គឺ ប្រាសចាកសតិ ព្រោះការលេងរបស់ខ្លួន ។ ពិតណាស់ កាលពួកវស្សវលាហកទេវបុត្តទាំងនោះកើតចិត្តគិតតាមសេចក្តីពេញចិត្តរបស់ខ្លួនថា ពួកយើងពេញចិត្ត (និងឲ្យភ្លៀងធ្លាក់) ភ្លៀងរមែងធ្លាក់ចុះ សូម្បីក្នុងវេលាមិនមែនជារដូវកាល[១] រមែងធ្លាក់ដោយមិនមានហេតុនោះ[២] ។ ទ្រង់សំដៅដល់ប្រការនោះ ទើបត្រាស់

---

១ ព្រោះមិនមានចិត្តគិត ដូច្នោះ ទើបភ្លៀងមិនធ្លាក់ , ២ ភ្លៀងមិនធ្លាក់តាមរដូវកាល ។

ដូច្នោះថា សូម្បីដល់វេលាកាល ភ្លៀងក៏មិនធ្លាក់ ។

ចប់អដ្ឋកថា វស្សសូត្រទី ៧

# អដ្ឋកថា វាចាសូត្រទី ៨

*(អង្គនៃវាចាសុភាសិត)*

[៩៨] *សូត្រនេះ មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា វាចាសូត្រទី ៨

# អដ្ឋកថា កុលសូត្រទី ៩

*(ត្រកូលប្រសព្វបុណ្យដោយឋានៈ ៥)*

[៩៩] *សូត្រនេះ មានសេចក្ដីងាយយល់ហើយ ។*

ចប់អដ្ឋកថា កុលសូត្រទី ៩

# អដ្ឋកថា និស្សារណីយសូត្រទី ១០

## (ធាតុដែលគប្បីរលាស់ចេញ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង និស្សារណីយសូត្រទី ១០ ដូចតទៅនេះ ៖*

*[១០០] បទថា* ***និស្សារណិយា*** *(ដែលគួររលាស់ចេញ) បានដល់ រលាស់ចេញ គឺ ប្រាសចេញបាន ។ បទថា* ***ធាតុយោ*** *(ធាតុ) បានដល់ សភាពដែលទទេចាកខ្លួន ។ បទថា* ***កាមំ មនសិករោតោ*** *(ធ្វើទុកក្នុងចិត្ត នូវកាមទាំងឡាយ) បានដល់ ដាក់ចិត្តដល់កាម អធិប្បាយថា ចេញចាក អសុភឈានហើយ បញ្ជូនចិត្តឆ្ពោះទៅរកកាមដើម្បីនឹងសាកល្បង ដូចចាប់ យកថ្នាំព្យាបាលពិសមកសាកល្បងពិស ។ បទថា* ***ន បក្ខន្ទតិ*** *(រមែងមិន ស្ទុះទៅ) គឺ មិនចូលទៅ ។ បទថា* ***ន បសីទតិ*** *(មិនជ្រះថ្លា) គឺ មិន ដល់ភាពជ្រះថ្លា ។ បទថា* ***ន សន្តិដ្ឋតិ*** *(មិនតាំងនៅ) គឺ មិនតាំងនៅ ។ បទថា* ***ន វិមុច្ចតិ*** *(មិនជ្រប់នៅ) គឺ មិនបង្អោនទៅ ។ ដូចជារោមមាន់ក្តី ស្បែកកន្ត្រៃបក្តី ដែលគេដាក់ចូលទៅក្នុងភ្លើង រមែងរួញ ង រមូរ មិន ត្រង់ យ៉ាងណា ចិត្តក៏រួញរាមិនពង្រីកចេញ ដូច្នោះ ។ បឋមឈានក្នុង*

អសុភ ឈ្មោះថា នេក្ខម្មៈ ក្នុងបទថា **នេក្ខម្មំ ខោ បន** (តែ ...នេក្ខម្មៈ) ។ កាលភិក្ខុនោះធ្វើទុកក្នុងចិត្តដល់នេក្ខម្មៈនោះ ចិត្តរមែងស្ទុះទៅ (ក្នុងនេក្ខម្មៈនោះ) ។ បទថា **តស្ស តំ ចិត្តំ** (ចិត្តរបស់ភិក្ខុនោះ) បានដល់ ចិត្តក្នុងអសុភឈាននោះ របស់ភិក្ខុនោះ ។ បទថា **សុគតំ** (ដំណើរទៅល្អហើយ) បានដល់ ទៅហើយដោយល្អ ព្រោះទៅក្នុងគោចរ (អារម្មណ៍) ។ បទថា **សុភាវិតំ** (អប់រំល្អហើយ) បានដល់ អប់រំហើយដោយល្អ ព្រោះមិនប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្តីវិនាស ។ បទថា **សុវុដ្ឋិតំ** (តាំងនៅល្អហើយ) បានដល់ ចេញចាកកាមហើយ ។ បទថា **សុវិមុត្តំ** (រួចផុតល្អហើយ) បានដល់ រួចផុតហើយដោយល្អពីកាមទាំងឡាយ ។ អាសវៈទាំងឡាយ ៤ យ៉ាង ដែលមានកាមហេតុ ឈ្មោះថា អាសវៈមានកាមជាបច្ច័យ ។ សេចក្តីទុក្ខ ឈ្មោះថា **វិឃាតៈ** (ទុក្ខ) ។ សេចក្តីក្តៅក្រហាយ ព្រោះកាមរាគៈ ឈ្មោះថា **បរិឡាហា** (សេចក្តីក្តៅក្រហាយ) ។ បទថា **ន សោ តំ វេទនំ វេទិយតិ** (រមែងមិនសោយវេទនា ដែលកើតព្រោះហេតុនោះ) សេចក្តីថា ភិក្ខុនោះមិនបានសោយវេទនាកើតអំពីកាមនោះ និងវេទនាកើតអំពីសេចក្តី

ទុក្ខ និងសេចក្តីក្តៅក្រហាយឡើយ ។

បទថា *ឥទមក្ខាតំ កាមានំ និស្សរណំ (នេះតថាគតពោលថា ជាការប្រាសចេញនៃកាមទាំងឡាយ)* សេចក្តីថា អសុភឈាននេះ ព្រះមានព្រះភាគត្រាស់ថា ជាគ្រឿងប្រាសចេញទៅនៃកាមទាំងឡាយ ព្រោះរលាស់ចេញចាកកាម ។ ក៏ភិក្ខុណាធ្វើឈាននោះឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយ សម្រេចតតិយមគ្គ ឃើញនិព្វានដោយអនាគាមិផលហើយ ក៏ដឹងថា ឈ្មោះថាកាមទាំងឡាយរមែងមិនមានទៀត ចិត្តរបស់ភិក្ខុនោះ ឈ្មោះថារលាស់ចេញហើយដោយសព្វគ្រប់ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ តែសេចក្តីផ្សេងគ្នាមានដូច្នេះ ក្នុងវារៈទី ២ មេត្តាឈាន ឈ្មោះថា ជាគ្រឿងរលាស់ចេញព្យាបាទ ក្នុងវារៈទី ៣ករុណាឈាន ឈ្មោះថា ជាគ្រឿងរលាស់ចេញវិហេសា ក្នុងវារៈទី ៤ អរូបឈាន ឈ្មោះថា ជាគ្រឿងរលាស់ចេញរូបឈានទាំងឡាយ ។ម្យ៉ាងទៀត គប្បីប្រកបអរហត្តផលចូលទៅក្នុងបទនេះថា រលាស់ចេញហើយដោយសព្វគ្រប់ ។ ក្នុងវារៈទី ៥ បទថា *សក្កាយំ មនសិករោតោ (កាលភិក្ខុធ្វើទុកក្នុងចិត្ត*

នូវសក្កាយ) សេចក្តីថា កាលភិក្ខុកំណត់សង្ខារសុទ្ធៗ ជាអារម្មណ៍ហើយ សម្រេចព្រះអរហត្ត ជាសុក្ខវិបស្សកៈ ចេញចាកផលសមាបត្តិហើយ បញ្ជូនចិត្តឆ្ពោះទៅកាន់ឧបាទានក្ខន្ធ ៥ ដើម្បីសាកល្បង ។ បទថា **ឥទមក្ខាតំ សក្កាយស្ស និស្សរណំ** (តថាគតពោលថា ជាការប្រាសចេញនៃសក្កាយ) សេចក្តីថា ចិត្តដែលសម្បយុត្តដោយអរហត្តផលសមាបត្តិ កើតឡើងថា សក្កាយៈមិនមានតទៅទៀត របស់ភិក្ខុអ្នកឃើញព្រះនិព្វានដោយអរហត្ត-មគ្គ និងផល តាំងនៅ ព្រះមានព្រះភាគត្រាស់ថា ជាការប្រាសចេញនូវសក្កាយៈ ។

ឥឡូវនេះ ព្រះមានព្រះភាគកាលទ្រង់សរសើរគុណរបស់ព្រះខីណា-ស្រព ដែលដល់នូវការរលត់ គឺ ការប្រាសចេញនៃសក្កាយៈយ៉ាងនេះហើយតាំងនៅ ទើបត្រាស់បទមានជាអាទិ៍ថា **តស្ស កាមនន្ទិបិ នានុសេតិ** (សេចក្តីត្រេកត្រអាលក្នុងកាមក្តី រមែងមិនកើតឡើងដល់អ្នក) ។ ក្នុងបទទាំងនោះ បទថា **នានុសេតិ** (មិនបានកើត) គឺ មិនបង្កើតឡើង ។ បទថា **អននុសយា** (ព្រោះមិនកើត) គឺ ព្រោះការមិនបង្កើត ។ បទដ៏សេសក្នុង

*សូត្រនេះ មានសេចក្ដីងាយយល់ទាំងអស់ហើយ ។*

ចប់អដ្ឋកថា និស្សារណីយសូត្រទី ១០

## ចប់ព្រាហ្មណវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៨ សូត្រ

# ចប់ចតុត្ថបណ្ណាសក

# បញ្ចមបណ្ណាសកៈ

## កិមិលវគ្គវណ្ណនាទី ១

## អដ្ឋកថា កិមិលសូត្រទី ១

*(ត្រាស់ហេតុធ្វើឲ្យសាសនាវិនាសដល់ព្រះកិម្ពិលៈ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង កិមិលសូត្រទី ១ ដូចតទៅនេះ ៖*

[១០១] *បទថា* ***កិមិលាយំ*** *(ជិតក្រុងកិមិលា) បានដល់ ជិតក្រុងដែលមានឈ្មោះយ៉ាងនេះ ។ បទថា* ***វេឡុវនេ*** *(ត្រង់ព្រះវិហារវេឡុវ័ន) បានដល់ ក្នុងព្រៃមុចលិន្ទ ។ បទថា* ***ឯតទវោច*** *(ទូលសួរ) សេចក្តីថា បានឮថា ព្រះថេរៈនេះ ជាបុត្រសេដ្ឋីក្នុងក្រុងនោះ បួសក្នុងសម្នាក់ព្រះសាស្តា បានបុព្វេនិវាសញ្ញាណ ។ ព្រះថេរៈនោះ កាលរលឹកដល់ខន្ធសន្តាន (ការជាប់តនៃខន្ធ) ដែលខ្លួនធ្លាប់រស់នៅហើយ បានឃើញខ្លួនធ្លាប់បួសក្នុងពេលដែលសាសនារបស់ព្រះកស្សបទសពលសាបសូន្យ កាលបរិស័ទ ៤ មិនធ្វើសេចក្តីគោរពក្នុងសាសនា ទើបដាក់ជណ្តើរឡើងទៅលើភ្នំ ធ្វើសមណធម៌*

លើក្តីនោះ ហើយនៅទីនោះ ។ លោកចូលទៅគាល់ព្រះសាស្តា ហើយគិតថា យើងនឹងទូលសួរដល់ហេតុនោះ ទើបបានក្រាបទូលដោយពាក្យជាដើមថា **កោ នុ ខោ ភន្តេ** (បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុ) យ៉ាងនេះ ។ បទថា **សត្ថរិ អគារវា វិហរន្តិ អប្បតិស្សា** (ជាអ្នកមិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែងក្នុងព្រះសាស្តា) បានដល់ រមែងមិនតាំងសេចក្តីគោរព និងភាពជាធំក្នុងព្រះសាស្តា ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

ក្នុងបទទាំងនោះ ត្រង់លានព្រះចេតិយ៍ ភិក្ខុកាលដើរបាំងឆត្រ ពាក់ទ្រនាប់ជើងជាដើមក្តី និយាយរឿងដែលមិនជាប្រយោជន៍ មានប្រការផ្សេងៗក្តី ឈ្មោះថា មិនគោរពក្នុងព្រះសាស្ត្រា ។ មួយទៀត ក្នុងរោងស្តាប់ធម៌ អង្គុយដេកក្តី និយាយរឿងដែលមិនជាប្រយោជន៍មានប្រការផ្សេងៗ ក្តី ក៏ឈ្មោះថា មិនគោរពក្នុងធម៌ ។ ក្នុងកណ្តាលសង្ឃ កាលនិយាយដល់រឿងផ្សេងៗ លើកដៃគ្រវីទៅមកក្តី មិនធ្វើការកោតក្រែងក្នុងភិក្ខុជាថេរៈ នវភិក្ខុ (ភិក្ខុបួសថ្មី) និងមជ្ឈិមភិក្ខុ (ភិក្ខុកណ្តាល) ក្តី ឈ្មោះថា មិនគោរពក្នុង

ក្នុងសង្ឃ ។ កាលមិនធ្វើសិក្ខាបទឲ្យបរិបូណ៌ ឈ្មោះថា មិនគោរពក្នុងសិក្ខា ។ កាលធ្វើការឈ្លោះប្រកែកគ្នានិងគ្នាជាដើម ឈ្មោះថា មិនគោរពគ្នាទៅវិញទៅមក ។

ចប់អដ្ឋកថា កិមិលសូត្រទី ១

# អដ្ឋកថា ធម្មស្សវនសូត្រទី ២

*(អានិសង្សនៃការស្តាប់ធម៌)*

[១០២] *ក្នុងសូត្រនេះ មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា ធម្មស្សវនសូត្រទី ២

# អដ្ឋកថា អាជានិយសូត្រទី ៣

## (អង្គរបស់សេះអាជានេយ្យ)

គប្បីជ្រាបវិនិច្ឆ័យក្នុង អាជានិយសូត្រទី ៣ ដូចតទៅនេះ ៖

[១០៣] បទថា **អាជ្ជវេន (ស្មោះត្រង់)** បានដល់ ដោយភាពត្រង់ គឺ ដោយការមិនវៀច ។ បទថា **ជវេន (មានសន្ទុះលឿន)** គឺ ដោយសន្ទុះជើងរហ័ស ។ បទថា **មទ្ទវេន (មានភាពទន់ភ្លន់)** គឺ ដោយមានសរីរៈទន់ភ្លន់ ។ បទថា **ខន្តិយា (មានការអត់ធន់)** គឺ អត់ទ្រាំដោយសេចក្តីអត់ធ្មត់ ។ បទថា **សោរច្ចេន (មានការស្ងប់ស្ងៀម)** គឺ ដោយមានប្រក្រតីស្អាត ។ ក្នុងវារៈពោលដោយភិក្ខុ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ស្មោះត្រង់** បានដល់ ការប្រព្រឹត្តទៅត្រង់នៃញាណ ។ បទថា **មានសន្ទុះលឿន** បានដល់ ការប្រព្រឹត្តទៅនៃញាណដ៏ក្លៀវក្លា ។ បទថា **ទន់ភ្លន់** បានដល់ ភាពទន់ភ្លន់ព្រោះសីល ។ បទថា **សេចក្តីអត់ធន់** បានដល់ សេចក្តីអត់ធន់ដោយការគ្របសង្កត់ចិត្តនោះឯង ។ បទថា **ស្ងប់ស្ងៀម** បានដល់ ភាពជាអ្នកមានសីលស្អាតនោះឯង ។

ចប់អដ្ឋកថា អាជានិយសូត្រទី ៣

# អដ្ឋកថា ពលសូត្រទី ៤

*(កម្លាំង ៥ ប្រការ)*

[១០៤] *ក្នុងសូត្រនេះ ទ្រង់ត្រាស់ពលៈ ៥ លាយគ្នា (ទាំងលោកិយៈ និងលោកុត្តរៈ)*

ចប់អដ្ឋកថា ពលសូត្រទី ៤

# អដ្ឋកថា ចេតោខីលសូត្រទី ៥

## (ចំរឹងនៃចិត្ត ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង ចេតោខីលសូត្រទី ៥ ដូចតទៅនេះ ៖

[១០៥] បទថា **ចេតោខីលា (ចំរឹងនៃចិត្ត)** បានដល់ ភាពរឹងរូស ជាសម្រាម ជាដង្គត់នៃចិត្ត ។ បទថា **សត្ថរិ កង្ខតិ (រមែងសង្ស័យ... ក្នុងព្រះសាស្ដា)** សេចក្ដីថា ភិក្ខុរមែងសង្ស័យក្នុងព្រះវរកាយ ឬក្នុងព្រះគុណរបស់ព្រះសាស្ដា ។ កាលសង្ស័យក្នុងព្រះវរកាយ រមែងសង្ស័យថា ព្រះវរកាយ ឈ្មោះថា ប្រដាប់ដោយបុរិសលក្ខណៈ ៣២ មែនឬហ្ន៎ ។ កាលសង្ស័យក្នុងគុណ រមែងសង្ស័យថា ព្រះសព្វញ្ញុតញ្ញាណដែលអាចដឹងអតីត អនាគត បច្ចុប្បន្ន មែនឬទេហ្ន៎ ។ បទថា **វិចិកិច្ឆតិ (សង្ស័យ)** បានដល់ កាលជ្រើសរើស តែងតែលំបាក រមែងដល់នូវភាពពិបាក គឺ មិនអាចនឹងសម្រេចចិត្តបាន ។ បទថា **នាធិមុច្ចតិ (មិនបង្អោនចិត្តជឿ)** បានដល់ រមែងមិនបានបង្អោនចិត្តជឿថា វត្ថុនោះជាយ៉ាងនេះ ។ បទថា **ន សម្បសីទតិ (មិនជ្រះថ្លា)** បានដល់ ឈានចុះក្នុងគុណហើយ ព្រោះមិនទាន់អស់

សេចក្ដីសង្ស័យ ទើបមិនអាចនឹងជ្រះថ្លា គឺ មិនអាចមានចិត្តចុះស៊ប់ក្នុងព្រះសាស្ដា ។ បទថា **អាតប្បាយ (ដើម្បីសេចក្ដីព្យាយាម)** បានដល់ ដើម្បីធ្វើសេចក្ដីព្យាយាមដុតកំដៅកិលេស ។ បទថា **អនុយោគាយ (ដើម្បីប្រកបរឿយៗ)** បានដល់ ដើម្បីសេចក្ដីប្រកបរឿយៗ ។ បទថា **សាតច្ចាយ (ដើម្បីធ្វើមិនដាច់)** បានដល់ ដើម្បីធ្វើឲ្យជាប់តគ្នា ។ បទថា **បធានាយ (ដើម្បីបំពេញព្យាយាម)** បានដល់ ដើម្បីតាំងសេចក្ដីព្យាយាម ។ បទថា **អយំ បឋមោ ចេតោខិលោ (នេះចំរឹងនៃចិត្តទី ១)** បានដល់ ភាពរឹងរូសនៃចិត្តប្រការទីមួយ គឺ សេចក្ដីសង្ស័យក្នុងព្រះសាស្ដា ជាភាវៈដែលភិក្ខុនោះ លះមិនបានយ៉ាងនេះ ។

ក្នុងបទថា **ធម្មេ (ក្នុងធម៌)** គឺ ក្នុងព្រះបរិយត្តិធម៌ និងបដិវេធធម៌ ។ កាលសង្ស័យក្នុងព្រះបរិយត្តិធម៌ រមែងសង្ស័យថា អាចារ្យទាំងឡាយពោលថា ពុទ្ធវចនៈ គឺ ព្រះត្រៃបិដក មាន ៨៤.០០០ ធម្មក្ខន្ធ ព្រះពុទ្ធវចនៈនោះ មានមែនឬ ។ កាលសង្ស័យក្នុងបដិវេធធម៌ រមែងសង្ស័យថា អាចារ្យទាំងឡាយពោលថា ផលនៃវិបស្សនា ឈ្មោះថាមគ្គ ផលនៃមគ្គ

ឈ្មោះថាផល ការលះសង្ខារទាំងឡាយដាច់ជាសមុច្ឆេទ ឈ្មោះថានិព្វាន និព្វាននោះមានមែនឬ ។

បទថា **សង្ឃេ សង្ខតិ** (សង្ស័យក្នុងព្រះសង្ឃ) សេចក្តីថា រមែងសង្ស័យថា ព្រះសង្ឃដែលបដិបត្តិតាមបដិបទាបែបនេះ តាមបទជាដើមថា **ឧជុប្បដិបន្នោ** (អ្នកបដិបត្តិត្រង់) ជាជំនុំនៃបុគ្គល ៨ គឺ បុគ្គលតាំងនៅក្នុងមគ្គ ៤ តាំងនៅក្នុងផល ៤ មានមែនឬ ។

កាលសង្ស័យក្នុង **សិក្ខា** រមែងសង្ស័យថា អាចារ្យទាំងឡាយពោលថា អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា សិក្ខានោះមានមែនឬ ។

បទថា **អយំ បញ្ចមោ** (នេះ... ប្រការទី ៥) បានដល់ សភាវៈនេះ ជាកាពរឹងរូស ជាសម្រាម ជាដង្គត់ នៃចិត្តប្រការទី ៥ គឺ ភាពរឹងត្អឹងក្នុងមិត្តសព្រហ្មចារី ។

ចប់អដ្ឋកថា ចេតោខិលសូត្រទី ៥

# អដ្ឋកថា វិនិពន្ធសូត្រទី ៦

## (គ្រឿងចងរឹតចិត្ត ៥ ប្រការ)

គប្បីជ្រាបវិនិច្ឆ័យក្នុង វិនិពន្ធសូត្រទី ៦ ដូចតទៅនេះ ៖

[១០៦] បទថា **ចេតសោ វិនិពន្ធា** (ចំណងនៃចិត្ត) មានវិគ្រោះថា ឈ្មោះថា គ្រឿងចងចិត្ត ព្រោះចងចិត្តទុក ដូចធ្វើទុកក្នុងកណ្តាប់ដៃ ។ បទថា **កាមេសុ** (ក្នុងកាម) បានដល់ ទាំងវត្ថុកាម និងកិលេសកាម ។ បទថា **កាយេ** (ក្នុងកាយ) បានដល់ ក្នុងកាយរបស់ខ្លួន ។ បទថា **រូបេ** (ក្នុងរូប) បានដល់ ក្នុងរូបខាងក្រៅ ។ បទថា **យាវទត្ថំ** (តាមត្រូវការ) បានដល់ ពេលដែលខ្លួនប្រាថ្នា ។ បទថា **ឧទរាវទេហកំ** (រហូតឆ្អែត) បានដល់ ទាល់តែពេញពោះ ។ អាហារដែលពេញពោះនោះ គេហៅថា **ឧទរាវទេហកំ** ព្រោះបរិភោគពេញពោះ ។ បទថា **សេយ្យសុខំ** (សុខក្នុងការដេក) បានដល់ សេចក្តីសុខដោយការដេកលើគ្រែ ឬតាំង ឬសេចក្តីសុខតាមឧតុ (ដេកហាលថ្ងៃ ឬហាលខ្យល់ជាដើម) ។ បទថា **បស្សសុខំ** (សុខក្នុងការផ្អែក) បានដល់ សេចក្តីសុខដែលកើតឡើង ដូចសេចក្តីសុខ

របស់បុគ្គលអ្នកដេកប្រែទៅប្រែមក ម្តងខាងស្តាំ ម្តងខាងឆ្វេង ដូច្នោះ ។ បទថា **មិទ្ធសុខំ (សុខក្នុងការលក់)** គឺ សេចក្តីសុខក្នុងការដេកលក់ ។ បទថា **អនុយុត្តោ (ប្រកប)** បានដល់ ប្រកបដោយការខ្វល់ខ្វាយហើយ ។ បទថា **បណិធាយ (ប្រាថ្នា)** បានដល់ ប្រាថ្នាហើយ ។ ចតុប្បារិសុទ្ធិសីល ឈ្មោះថា **សីល** ក្នុងបទជាដើមថា **សីលេន (ដោយសីល)** ។ ការសមាទានវត្ត ឈ្មោះថា **វត្ត** ។ ការប្រព្រឹត្តតបៈ ឈ្មោះថា **តបៈ** ។ ការវៀរចាកមេថុន ឈ្មោះថា **ព្រហ្មចារ្យ** ។ បទថា **ទេវោ វា ភវិស្សាមិ (អាត្មាអញនឹងបានជាទេវតា)** បានដល់ អញនឹងជាទេវតាដែលមានសក្តិធំឬ ។ បទថា **ទេវញ្ញតរោ វា (ឬទេវតាអង្គណាមួយ)** បានដល់ ឬនឹងទេវតាអ្នកមានសក្តិតូចអង្គណាមួយ ។

ចប់អដ្ឋកថា វិនិពន្ធសូត្រទី ៨

# អដ្ឋកថា យាគុសូត្រទី ៧

*(អានិសង្សបបរ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង យាគុសូត្រទី ៦ ដូចតទៅនេះ ៖*

*[១០៧] បទថា **វាតំ អនុលោមេតិ** (ញុំាងខ្យល់ឲ្យប្រព្រឹត្តទៅសព្វ) បានដល់ ធ្វើខ្យល់ឲ្យដើរស្រួល ។ **វត្ថឹ សោធេតិ** (សំអាតតម្រងបស្សាវៈ) បានដល់ ជំរះសរសៃឈាមឲ្យស្អាត ។ បទថា **អាមាវសេសំ បាចេតិ** (ដុតអាហារចាស់ដែលមិនទាន់រលួយ) បានដល់ បើអាហារចាស់មាននៅសល់ ក៏ជួយរំលាយអាហារនោះ ។*

ចប់អដ្ឋកថា យាគុសូត្រទី ៧

# អដ្ឋកថា ទន្តកដ្ឋសូត្រទី ៨

*(ទោសការមិនប្រើឈើជម្រះធ្មេញ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទន្តកដ្ឋសូត្រទី ៨ ដូចតទៅនេះ ៖*

[១០៨] *បទថា* ***អចក្ខុស្សំ*** *(មានចក្ខុមិនស្អាត) បានដល់ មិនធ្វើការចម្រើនដល់ចក្ខុ គឺ មិនធ្វើចក្ខុឲ្យថ្លា ។*

ចប់អដ្ឋកថា ទន្តកដ្ឋសូត្រទី ៨

# អដ្ឋកថា គីតសូត្រទី ៩

*(ទោសនៃការពោលធម៌ដោយសំឡេងច្រៀងវែង)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង គីតសូត្រទី ៩ ដូចតទៅនេះ ៖*

[១០៩] *បទថា* ***អាយតកេន (វែង)*** *បានដល់ វែង គឺ ធ្វើឲ្យជារបៀបគាថា (ពាក្យកាព្យ) ដែលមានបទ និងព្យញ្ជនៈបរិបូណ៌ឲ្យវិនាសទៅ ។ បទថា* ***សរកុត្តិម្បិ និកាមយមានស្ស (កាលកិក្ខុពេញចិត្តក្នុងការធ្វើសំឡេង)*** *បានដល់ កាលប្រាថ្នាការធ្វើសំឡេង ដោយគិតថា សំឡេងច្រៀងរបស់យើងគួរធ្វើយ៉ាងនេះ ដូច្នេះ ។ បទថា* ***សមាធិស្ស កង្គោ ហោតិ (ការវិនាសនៃសមាធិរមែងមាន)*** *បានដល់ ចិត្តដែលប្រកបដោយសមថៈ និងវិបស្សនាក៏វិនាសទៅ ។*

ចប់អដ្ឋកថា គីតសូត្រទី ៨

# អដ្ឋកថា មុដ្ឋស្សតិស្សសូត្រទី ១០

*(ទោសរបស់បុគ្គលដេកមិនមានសតិ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មុដ្ឋស្សតិស្សសូត្រទី ១០ ដូចតទៅនេះ ៖*

[២១០] *បទថា **ទុក្ខំ សុបតិ** (រមែងដេកជាទុក្ខ) បានដល់ កាលដេកយល់សប្តិផ្សេងៗ ក៏លក់មិនស្រួល ។ បទថា **ទុក្ខំ បដិពុជ្ឈតិ** (រមែងភ្ញាក់ឡើងជាទុក្ខ) បានដល់ សូម្បីកាលភ្ញាក់ឡើង ក៏ភ្ញាក់ឡើងទាំងភ័យខ្លាច ។ ក្នុងសូត្រនេះ ត្រាស់សតិសម្បជញ្ញៈលាយគ្នា (ទាំងលោកិយៈ និងលោកុត្តរៈ) ។*

ចប់អដ្ឋកថា មុដ្ឋស្សតិស្សសូត្រទី ១០

## ចប់កិមិលវគ្គវណ្ណនាទី ១

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៩ សូត្រ

# អក្កោសកវគ្គវណ្ណនាទី ២

## អដ្ឋកថា អក្កោសកសូត្រទី ១

*(ទោសនៃការជេរ ៥ ប្រការ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អក្កោសកសូត្រទី ១ ដូចតទៅនេះ ៖*

[១១១] *បទថា* ***អក្កោសកបរិភាសកោ*** *(ជេរប្រទេចតិះដៀល) បានដល់ ជេរដោយអក្កោសវត្ថុ ១០ តិះដៀលដោយការសម្ដែងឲ្យខ្លាច ។ បទថា* ***ឆិន្នបរិបន្ថោ*** *(កាត់ផ្លូវសម្រេចលោកុត្តរធម៌) បានដល់ ឈ្មោះថា កាត់ផ្លូវនាំឲ្យសម្រេចលោកុត្តរធម៌ ព្រោះជាគ្រឿងរាំង គឺ លោកុត្តរៈ ត្រូវកាត់ផ្ដាច់ហើយ ។ បទថា* ***រោគាតង្កំ*** *(មានរោគយ៉ាងធ្ងន់) បានដល់ រោគនោះឯង ឈ្មោះថា រោគកំរ៉ៃ ព្រោះនាំការរស់នៅលំបាកមកឲ្យ ។*

ចប់អដ្ឋកថា អក្កោសកសូត្រទី ២

# អដ្ឋកថា ភណ្ឌនសូត្រទី ២

*(ទោសនៃការប្រកួតប្រកាន់)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ភណ្ឌនសូត្រទី ២ ដូចតទៅនេះ ៖*

[១១២] *បទថា* ***អធិករណការកោ*** *(បង្កអធិករណ៍) បានដល់ បង្កអធិករណ៍ ៤ ឲ្យកើតឡើងណាមួយ ។ បទថា* ***អនធិគតំ*** *(គុណដែលមិនទាន់បានសម្រេច) បានដល់ គុណវិសេសដែលនៅមិនទាន់បានសម្រេចមកអំពីមុន ។*

ចប់អដ្ឋកថា ភណ្ឌនសូត្រទី ២

# អដ្ឋកថា សីលសូត្រទី ៣

*(ទោសរបស់បុគ្គលទ្រុស្តសីល និងគុណបុគ្គលមានសីល)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សីលសូត្រទី ៣ ដូចតទៅនេះ ៖*

*[១១៣] បទថា **ទុស្សីលោ** (បុគ្គលទ្រុស្តសីល) បានដល់ មិនមាន សីល គឺ គ្មានសីល ។ បទថា **សីលវិបន្នោ** (មានសីលវិបត្តិ) បានដល់ មានសីលវិបត្តិ គឺ គ្មានការសង្រួម ។ បទថា **បមាទាធិករណំ** (មានការប្រមាទជាហេតុ) បានដល់ ព្រោះមានសេចក្តីប្រមាទជាហេតុ ។*

*ក៏សូត្រនេះ ប្រើសម្រាប់គ្រហស្ថ សូម្បីបព្វជិតក៏ប្រើបានដូចគ្នា ។ ពិតណាស់ គ្រហស្ថរមែងចិញ្ចឹមជីវិតបានដោយសិល្បៈណាៗ មិនថា ធ្វើស្រែ ឬលក់ដូរ បើប្រមាទដោយធ្វើបាណាតិបាតជាដើម ក៏រមែងមិនអាចឲ្យសិល្បៈនោះៗ សម្រេចផលតាមកាល ដូច្នោះ គេក៏អស់ដើម ព្រោះកាលធ្វើបាណាតិបាត និងអទិន្នាទិនាជាដើម ក្នុងវេលាដែលគេមិនត្រូវគ្នា រមែងដល់នូវការវិនាសភោគទ្រព្យដ៏ច្រើន ដោយត្រូវដាក់ទោសទៀតផង ។ បព្វជិតអ្នកទ្រុស្តសីល រមែងដល់នូវការវិនាសចាកសីល ព្រះពុទ្ធវចនៈ ឈាន*

និងវិនាសអរិយទ្រព្យ ៧ ប្រការ ព្រោះមានសេចក្តីប្រមាទជាហេតុ ។ ឯគ្រហស្ថ រមែងមានកេរ្តិ៍ឈ្មោះអាក្រក់ផ្សាយទៅកណ្តាលបរិស័ទទាំង ៤ ថា គ្រហស្ថឯណោះ កើតក្នុងត្រកូលឯណោះ ជាអ្នកទ្រុស្តសីល មានបាបធម៌ ជាអ្នកមានសេចក្តីវិនាសក្នុងលោកនេះ និងលោកខាងមុខ មិនឲ្យទានសូម្បីតែអាហារ ។ ចំពោះបព្វជិត កេរ្តិ៍ឈ្មោះដែលខូចក៏ផ្សាយទៅយ៉ាងនេះថា បព្វជិតរូបនោះ រក្សាសីលក៏មិនបាន រៀនព្រះពុទ្ធវចនៈក៏មិនបាន ចិញ្ចឹមជីវិតដោយវេជ្ជកម្មជាដើម ជាអ្នកប្រកបដោយសេចក្តីមិនគោរព ៦ យ៉ាង ។ បទថា **អវិសារទោ (មិនអង់អាច)** សេចក្តីថា ពោលដល់គ្រហស្ថ គេគិតថា ក្នុងទីប្រជុំនៃមនុស្សច្រើនៗ មនុស្សខ្លះនឹងដឹងកម្មរបស់យើងដោយពិត បើដូច្នោះ មនុស្សទាំងឡាយនឹងចាប់យើង ឬនឹងសម្តែងយើងដល់រាជត្រកូល ទើបចូលទៅរកដោយការភ័យខ្លាច អៀនប្រៀន មិនអង់អាច ដាក់ក សំយុងមុខចុះ អង្គុយយកម្រាមដៃគ្នុះដី មិនអាចនិយាយយ៉ាងក្លាហាន , ចំណែកបព្វជិតគិតថា ភិក្ខុប្រជុំគ្នាច្រើនៗ ភិក្ខុរូបខ្លះនឹងដឹងកម្មរបស់អញជាក់ជាមិនខាន បើដូច្នោះ ពួកភិក្ខុនឹងហាមទាំងឧបោសថ ទាំងបវារណាដល់អញ

ឲ្យអញវិនាសចាកភាពជាសមណៈ ហើយនឹងបណ្ដេញចេញ ទើបគេចូលទៅរកយ៉ាងភ័យខ្លាច មិនអាចនិយាយដោយក្បៀវក្លាបាន ។ ចំណែកភិក្ខុរូបខ្លះ សូម្បីទ្រុស្តសីល ត្រូវវិនាសហើយក៏នៅត្រាច់ទៅ (រមែងត្រាច់ទៅដោយរីករាយ) បព្វជិតរូបនោះ ឈ្មោះថា ជាអ្នកមិនអង់អាចដោយអធ្យាស្រ័យនោះឯង ។

បទថា **សម្មូឡ្ហោ កាលំ ករោតិ** (រមែងជាអ្នកវង្វេងក្នុងពេលស្លាប់) សេចក្ដីថា ក៏រឿងដែលសមាទានប្រព្រឹត្តកម្ម គឺ ទ្រុស្តសីលរមែងប្រាកដដល់គេ ដែលដេកលើគ្រែក្នុងពេលជិតស្លាប់ គេបើកភ្នែកឡើងឃើញលោកនេះ បិទភ្នែកក៏ឃើញលោកខាងមុខ គឺ អបាយភូមិ ៤ រមែងប្រាកដដល់គេ គេហាក់ដូចជាត្រូវលំពែង ១០០ ដើម ចាក់លើសីសៈ គេស្រែកយំថា លោកទាំងឡាយចូលហាមផង លោកទាំងឡាយចូលហាមផង ក៏ស្លាប់ទៅ ព្រោះហេតុនោះ ទើបត្រាស់ថា **ជាអ្នកវង្វេងក្នុងពេលស្លាប់** ចំណែកប្រការទី ៥ ងាយយល់ហើយ ។ កថាពោលដោយអានិសង្ស គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងពាក្យដែលពោលហើយនេះចុះ ។

ចប់អដ្ឋកថា សីលសូត្រទី ៣

# អដ្ឋកថា ពហុភាណីសូត្រទី ៤

*(គុណ និងទោសនៃការនិយាយច្រើន)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ពហុភាណីសូត្រទី ៤ ដូចតទៅនេះ ៖*

[១១៤] *បទថា* ***ពហុភាណិស្មឹ*** *(បុគ្គលនិយាយច្រើន)* បានដល់ បុគ្គលមិនកំណត់ទុកដោយបញ្ញា ហើយក៏និយាយច្រើន ។ បញ្ញា ហៅថា ***មន្តា*** ក្នុងបទថា ***មន្តភាណិស្មឹ*** *(បុគ្គលនិយាយដោយមន្តា)* បានដល់ បុគ្គលកំណត់ដោយបញ្ញាហើយ ទើបនិយាយ ។

ចប់អដ្ឋកថា ពហុភាណីសូត្រទី ៤

# អដ្ឋកថា បឋមអក្ខន្តិសូត្រទី ៥[១]

## (ទោសនៃការមិនអត់ធន់)

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអក្ខន្តិសូត្រទី ៥ ដូចតទៅនេះ ៖

[១១៥] បទថា *វេរពហុលោ (បុគ្គលច្រើនដោយពៀរ)* បានដល់ បុគ្គលមានពៀរច្រើន ដោយជាបុគ្គលពៀរខ្លះ ដោយអកុសលខ្លះ ។ បទថា *វជ្ជពហុលោ (បុគ្គលច្រើនដោយទោស)* បានដល់ បុគ្គលច្រើនដោយទោស ។

ចប់អដ្ឋកថា បឋមអក្ខន្តិសូត្រទី ៥

(១) អដ្ឋកថា = អខន្តិសូត្រ ។

# អដ្ឋកថា ទុតិយអក្ខន្តិសូត្រទី ៦

*(ទោសនៃការមិនអត់ធន់)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអក្ខន្តិសូត្រទី ៦ ដូចតទៅនេះ ៖*

[១១៦] *បទថា **លុទ្ទោ**[១] (ជាមនុស្សអាក្រក់) បានដល់ ជាមនុស្សកាច ជាមនុស្សអាក្រក់ ។ បទថា **វិប្បដិសារី** (ជាមនុស្សក្តៅក្រហាយ) គឺ ប្រកបដោយសេចក្តីក្តៅក្រហាយ ។*

ចប់អដ្ឋកថា ទុតិយអក្ខន្តិសូត្រទី ៦

(១) អដ្ឋកថា = លុទ្ធោ ។

# អដ្ឋកថា បឋមអបាសាទិកសូត្រទី ៧

*(ទោសរបស់បុគ្គលមិនគួរជ្រះថ្លា)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអបាសាទិកសូត្រទី ៧ ដូចតទៅនេះ ៖*

[១១៧] *បទថា* ***អបាសាទិកេ*** *(មិនគួរជ្រះថ្លា) បានដល់ បុគ្គលប្រកបដោយកាយកម្មជាដើម ដែលមិនគួរជ្រះថ្លា ។ បទថា* ***បាសាទិកេ*** *(បុគ្គលគួរជ្រះថ្លា) បានដល់ បុគ្គលដែលមានការប្រព្រឹត្តបរិសុទ្ធ ដែលនាំមកនូវសេចក្តីជ្រះថ្លា ។*

ចប់អដ្ឋកថា អបាសាទិកសូត្រទី ៧

# អដ្ឋកថា ទុតិយអចាសានិកសូត្រទី ៨

*(ទោសរបស់បុគ្គលមិនគួរជ្រះថ្លា)*

*[១១៨] ក្នុងសូត្រនេះ មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថា ទុតិយអចាសានិកសូត្រទី ៨

# អដ្ឋកថា អគ្គិសូត្រទី ៩

*(ទោសរបស់ភ្លើង)*

[១១៨] ក្នុងសូត្រនេះ មានសេចក្តីងាយយល់ហើយ ។

ចប់អដ្ឋកថា ទុតិយអចាសាធិកសូត្រទី ៨

# អដ្ឋកថា មធុរាសូត្រទី ១០

## *(ទោសនៃមធុរានគរ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មធុរាសូត្រទី ១០ ដូចតទៅនេះ ៖*

[១២០] *បទថា* ***បញ្ចិមេ ភិក្ខវេ អាទីនវា មធុរាយំ*** *(ម្នាលភិក្ខុទាំងឡាយ ទោសក្នុងដែនមធុរានេះ មាន ៥ យ៉ាង) សេចក្ដីថា សម័យមួយ ព្រះមានព្រះភាគទ្រង់មានភិក្ខុហែហមហើយ កាលស្ដេចចារិកទៅដល់មធុរានិគមហើយ ទ្រង់ផ្ដើមនឹងស្ដេចចូលទៅនៅខាងក្នុងព្រះនគរ ។ គ្រានោះ នាងយក្ខិនីមួយរូបជាមិច្ឆាទិដ្ឋិ និម្មិតកាយ លាដៃទាំងពីរចេញលៀនអណ្ដាត ឈរទទឹងមុខព្រះភក្ត្រព្រះទសពល ។ ព្រះសាស្ដាស្ដេចមិនចូលទៅខាងក្នុងព្រះនគរ ស្ដេចក៏ចេញអំពីនោះឯង ស្ដេចចេញអំពីទីនោះហើយ ស្ដេចចូលទៅកាន់វិហារ ។ មហាជនកាន់យករបស់ទំពារ និងរបស់បរិភោគ និងគ្រឿងសក្ការៈបូជាទៅកាន់វិហារ បានថ្វាយទានដល់ភិក្ខុសង្ឃដែលមានព្រះពុទ្ធជាប្រធាន ។ ព្រះសាស្ដា ទ្រង់ប្រារព្ធព្រះសូត្រនេះ ដើម្បីទ្រង់បង្ហាញទោសនគរនោះ ។ បណ្ដាលបទទាំងនោះ បទថា*

*វិសមា (មានផែនដីមិនស្មើ) បានដល់ មានផែនដីមិនរាបស្មើ ។ បទថា ពហុរជា (មានធូលីច្រើន) បានដល់ ក្នុងវេលាខ្យល់បក់ ក៏ត្រូវគំនរធូលីហុយឡើង ។ បទដ៏សេសក្នុងទីទាំងពួងងាយយល់ហើយ ។*

ចប់អដ្ឋកថា មធុរាសូត្រទី ១០

## ចប់អក្កោសកវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៨ សូត្រ

# និយចារិកវគ្គវណ្ណនាទី ៣

## អដ្ឋកថា បឋមនិយចារិកសូត្រទី ១

*(ទោសរបស់អ្នកចារិកទៅយូរ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមទីឃចារិកសូត្រទី ១ ដូចតទៅនេះ ៖*

[១២១] *បទថា **អនវត្ថចារិកំ** (ការត្រាច់ទៅមិនមានកំណត់) បានដល់ ការត្រាច់ទៅមិនបានកំណត់យកអ្វីៗ ទុក ។ បទថា **សុតំ ន បរិយោ-ទបេតិ** (រមែងមិនចូលចិត្តស្តាប់វត្ថុដែលបានស្តាប់ហើយ) បានដល់ ប្រការណា ដែលគេធ្លាប់ស្តាប់ហើយ ក៏មិនចូលចិត្តស្តាប់ប្រការនោះទៀត ។ បទថា **សុតេនេកច្ចេន អវិសារទោ ហោតិ** (រមែងមិនក្លៀវក្លាដោយវត្ថុខ្លះក្នុងប្រការដែលបានស្តាប់ហើយ) បានដល់ រមែងមិនសោមនស្សដោយការដឹង សូម្បីមានដោយការស្តាប់បន្តិចបន្តួច ។ បទថា **សមវត្ថចារេ** (ក្នុងការត្រាច់ទៅមានកំណត់ល្មមសមគួរ) បានដល់ ក្នុងការត្រាច់ទៅបានកំណត់ទុកហើយ ។*

ចប់អដ្ឋកថា បឋមទីឃចារិកសូត្រទី ១

# អដ្ឋកថា ទុតិយនិយចារិកសូត្រទី ២

*(ទោសរបស់អ្នកចារិកទៅយូរ)*

[១២២] *សូត្រនេះ សេចក្ដីងាយយល់ទាំងអស់ហើយ ។*

ចប់អដ្ឋកថា ទុតិយនិយចារិកសូត្រទី ២

# អដ្ឋកថា អភិនិវាសសូត្រទី ៣

## (ទោសក្នុងការនៅប្រចាំ)

គប្បីជ្រាបវិនិច្ឆ័យក្នុង អភិនិវេសសូត្រទី ៣ ដូចតទៅនេះ ៖

[១២៣] បទថា ពហុភណ្ឌោ (មានទ្រព្យសម្បត្តិច្រើន) បានដល់មានបរិក្ខារច្រើន ។ បទថា ពហុភេសជ្ជោ (មានភេសជ្ជៈច្រើន) បានដល់ជាអ្នកមានភេសជ្ជៈច្រើន ព្រោះទឹកដោះថ្លា និងទឹកដោះជូរមានច្រើន ។ បទថា អព្យត្តោ (មិនឈ្លាស) គឺ ជាមនុស្សមិនជាប់ជំពាក់ (ក្នុងកិច្ចដែលគប្បីជួយ) ។ បទថា សំសដ្ឋោ (ស្និទ្ធស្នាល) គឺ ជាអ្នកស្និទ្ធស្នាលដោយការស្និទ្ធស្នាល ៥ យ៉ាង ។ បទថា អននុលោមិកេន (ដែលមិនសមគួរ) បានដល់ មិនសមគួរដល់សាសនា ។

ចប់អដ្ឋកថា អភិនិវេសសូត្រទី ៣

# អដ្ឋកថា មច្ឆរសូត្រទី ៤

*(ការនៅប្រចាំធ្វើឲ្យកើតសេចក្តីកំណាញ់)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មច្ឆរសូត្រទី ៤ ដូចតទៅនេះ ៖*

[១២៤] *បទថា **វណ្ណមច្ឆរី** (កំណាញ់វណ្ណៈ) គឺ កំណាញ់គុណ ។ បទថា **ធម្មមច្ឆរី** (កំណាញ់ធម៌) គឺ កំណាញ់ព្រះបរិយត្តិ ។*

ចប់អដ្ឋកថា មច្ឆរសូត្រទី ៣

# អដ្ឋកថា បឋមកុលុបកសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង កុលុបកសូត្រទី ៥ ដូចតទៅនេះ ៖*

*[១២៥] បទថា **អនាមន្តចារេ អាបជ្ជតិ** (រមែងត្រូវអាបត្តិព្រោះត្រាច់ទៅមិនប្រាប់លា) សេចក្ដីថា រមែងត្រូវអាបត្តិ ដែលត្រាស់ទុកក្នុងសិក្ខាបទថា ភិក្ខុទទួលនិមន្តហើយ មានភត្តហើយ មិនប្រាប់លាភិក្ខុដែលមាននៅ ជាអ្នកត្រាច់ទៅក្នុងត្រកូលទាំងឡាយមុនអាហារ ឬខាងក្រោយអាហារ ។ សូម្បីបទជាដើមថា **រហោនិសជ្ជាយ** (ព្រោះអង្គុយក្នុងទីកំបាំងត្រចៀកជាមួយមាតុគ្រាម) គប្បីជ្រាបតាមសិក្ខាបទទាំងនោះ ។*

ចប់អដ្ឋកថា បឋមកុលុបកសូត្រទី ៥

# អដ្ឋកថា ទុតិយកុលុបកសូត្រទី ៥

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយកុលុបកសូត្រទី ៦ ដូចតទៅនេះ ៖*

[១២៦] *ពាក្យថា* ***អតិវេលំ*** *(ហួសវេលា) បានដល់ ហួសវេលា ដែលកំណត់ ៗ*

ចប់អដ្ឋកថា ទុតិយកុលុបកសូត្រទី ៦

# អដ្ឋកថា ភោគសូត្រទី ៧

*(គុណ និងទោសរបស់ភោគៈ)*

[១២៧] *ក្នុងសូត្រនេះ មានសេចក្ដីងាយយល់ទាំងអស់ ។*

ចប់អដ្ឋកថា ភោគសូត្រទី ៧

# អដ្ឋកថា ភត្តសូត្រទី ៨

## (ទោសនៃការបរិភោគអាហារក្នុងវេលាថ្ងៃពេក)

គប្បីជ្រាបវិនិច្ឆ័យក្នុង ភត្តសូត្រទី ៨ ដូចតទៅនេះ ៖

[១២៨] បទថា **ឧស្សូរភត្តេ** (បរិភោគអាហារក្នុងវេលាថ្ងៃ) បានដល់ បរិភោគអាហារក្នុងវេលាថ្ងៃពេក ។ បទថា **ន កាលេន បដិបូជេន្តិ** (រមែងមិនបានទទួលតាមវេលា) សេចក្តីថា ពួកជនទាំងនោះ មិនបរិភោគយាគូក្នុងវេលាដែលត្រូវបរិភោគយាគូ របស់ទំពារក្នុងវេលាដែលបរិភោគរបស់ទំពារ អាហារក្នុងវេលាដែលត្រូវបរិភោគអាហារ រមែងមិនបានទទួលតាមកាលវេលា ព្រោះកន្លងហួសវេលាដែលប្រកបការខ្វល់ខ្វាយហើយ ឈ្មោះថា ឲ្យដោយចិត្តរបស់ខ្លួនប៉ុណ្ណោះ ។ តមក កាលពួកជនទាំងនោះមកកាន់ផ្ទះរបស់ខ្លួន ម្ចាស់ផ្ទះ ក៏រមែងធ្វើយ៉ាងនោះដូចគ្នា ។ សូម្បីទេវតាដែលធ្លាប់ទទួលពលីមកហើយតាមប្រពៃណីនៃត្រកូល បានលាភតាមកាលដ៏សមគួរ ទើបរក្សាគ្រប់គ្រង តែកាលមិនបានទទួលតាមកាលវេលា រមែងមិនធ្វើការរក្សា ដោយគិតថា ពួកជនទាំងនោះមិនអើពើក្នុងពួកយើង ។ សូម្បីសមណព្រាហ្មណ៍

រមែងមិនធ្វើកិច្ចដែលគួរធ្វើក្នុងការងារមង្គល និងអពមង្គល ដោយគិតថា ក្នុងផ្ទះរបស់ជនទាំងនោះ មិនមានអាហារក្នុងវេលាអាហារ គេឲ្យក្នុងវេលាថ្ងៃពេក ។ បទថា **វិមុខា កម្មំ ករោន្តិ** (មានមុខក្រៀមធ្វើការងារ) សេចក្តីថា ពួកអ្នកបម្រើជាដើម លះបង់ការងារ អង្គុយដោយគិតថា ក្នុងវេលាព្រឹក ពួកយើងនៅមិនទាន់បានអ្វីឡើយ ពួកយើងឃ្លានខ្លាំងណាស់ មិនអាចធ្វើការងារបាន ។ បទថា **អនោជវន្តំ ហោតិ** (មិនមានឱជា) បានដល់អាហារដែលបរិភោគមិនត្រូវតាមកាល រមែងមិនអាចនឹងផ្សាយឱជារសទៅបាន ។ ធម៌ខាងចំណែកល្អ គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងពាក្យពោលមកហើយនោះឯង ។

ចប់អដ្ឋកថា ភត្តសូត្រទី ៨

# អដ្ឋកថា បឋមសប្បសូត្រទី ៩

## (ទោសរបស់ពស់ស្មើនឹងមាតុគ្រាម)

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសប្បសូត្រទី ៩ ដូចតទៅនេះ ៖

[១២៩] បទថា *សភីរុ (គួរតក់ស្លុត)* បានដល់ ជាសត្វចូលចិត្ត ដេក គឺ ដេកច្រើន ។ បទថា *សប្បដិភយោ (ជាភ័យចំពោះមុខ)* បានដល់ ភ័យរមែងកើតឡើងព្រោះអាស្រ័យពស់នោះ ព្រោះដូច្នោះ ពស់នោះ ទើបឈ្មោះថា មានភ័យចំពោះមុខ ។ បទថា *មិត្តទុព្ភី (អ្នកទ្រុស្តមិត្រ)* បានដល់ ប្រទូស្តរាយ បៀនបៀនមិត្រ សូម្បីអ្នកឲ្យបាយ និងទឹកបរិភោគ ។ សូម្បីក្នុងមាតុគ្រាម ក៏ន័យនេះដូចគ្នា ។

ចប់អដ្ឋកថា បឋមសប្បសូត្រទី ៩

# អដ្ឋកថា ទុតិយសប្បសូត្រទី ១០

*(ទោសរបស់ពស់ស្មើនឹងមាតុគ្រាម)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសប្បសូត្រទី ៩ ដូចតទៅនេះ ៖*

[១៣០] *បទថា **ឃោរវិសោ** (មានពិសពន្លឹក) គឺ មានពិសកាចសាហាវ ។ បទថា **ទុជ្ជិវ្ហោ** (មានអណ្តាតផែកជាពីរ) គឺ មានអណ្តាតបែកចេញជា ២ ចំណែក ។ បទថា **ឃោរវិសតា** (ជាបុគ្គលមានពិសពន្លឹក) គឺ ព្រោះជាសត្វមានពិសកាច ។ សូម្បីក្នុង ២ បទដ៏សេស ក៏មានន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា ទុតិយសប្បសូត្រទី ១០

## ចប់ទីឃចារិកវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៨ សូត្រ

# អាវាសិកវគ្គវណ្ណនាទី ៤

## អដ្ឋកថា អាវាសិកសូត្រទី ១

*(ធម៌របស់ចៅអាវាស)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាវាសិកសូត្រទី ១ ដូចតទៅនេះ ៖*

[១៣១] *បទថា* ន *អាកប្បសម្បន្នោ (ជាអ្នកមិនដល់ព្រមដោយមារយាទ)* បានដល់ ជាអ្នកមិនដល់ព្រមដោយកិរិយាមារយាទរបស់សមណៈ ។ *បទថា* អភាវនិយោ ហោតិ *(រមែងជាបុគ្គលមិនគួរសរសើរ)* បានដល់ រមែងមិនជាអ្នកគួរសរសើរឡើយ ។

ចប់អដ្ឋកថា អាវាសិកសូត្រទី ១

# អដ្ឋកថា បិយសូត្រទី ២

*(ហេតុធ្វើឲ្យចៅអាវាសជាទីស្រឡាញ់)*

[១៣២] *ក្នុងសូត្រនេះ ងាយយល់ទាំងអស់ហើយ ។*

ចប់អដ្ឋកថា បិយសូត្រទី ២

# អដ្ឋកថា សោភណសូត្រទី ៣

*(ធម៌ធ្វើទៅអាវាសឲ្យស្អាត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សោភណសូត្រទី ៣ ដូចតទៅនេះ ៖*

[១៣៣] *បទថា* **បដិពលោ** *(ជាអ្នកអាច) បានដល់ ឈ្មោះថា ជាអ្នកអាច ព្រោះជាអ្នកប្រកបដោយកម្លាំងកាយ និងកម្លាំងប្រាជ្ញា ។*

ចប់អដ្ឋកថា សោភណសូត្រទី ៣

# អដ្ឋកថា ពហុបការសូត្រទី ៤

*(ធម៌ធ្វើឲ្យចៅអាវាសមានឧបការៈច្រើន)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ពហុបការសូត្រទី ៤ ដូចតទៅនេះ ៖*

[១៣៤] *បទថា* ***ខណ្ឌផុល្លំ*** *(ដែលបែកបាក់) បានដល់ ទីទ្រុឌទ្រោម និងទីបែកបាក់ ។ បទថា* ***អាគេចេតិ*** *(ប្រាប់) នេះ ត្រាស់ដោយអំណាចនៃត្រកូលដែលបវារណាទុកហើយ ។*

ចប់អដ្ឋកថា ពហុបការសូត្រទី ៤

# អដ្ឋកថា អនុកម្បកសូត្រទី ៥

*(ហេតុឲ្យចៅអាវាសអនុគ្រោះដល់គ្រហស្ថ)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនុកម្បកសូត្រទី ៥ ដូចតទៅនេះ ៖*

[១៣៥] *បទថា* ***អធិសីលេសុ*** *(ក្នុងអធិសីល) បានដល់ ក្នុងសីល ៥ ។ បទថា* ***ធម្មទស្សនេ និវេសេតិ*** *(ឲ្យតាំងនៅក្នុងធម្មទស្សនៈ) បានដល់ ឲ្យតាំងនៅក្នុងធម្មទស្សនៈ គឺ សច្ចៈ ៤ ។ បទថា* ***អរហត្តំ*** *(ឲ្យត្រង់ចំពោះព្រះរតនត្រៃ) បានដល់ ឲ្យប្រព្រឹត្តទៅក្នុងព្រះរតនត្រៃ ដែលសមគួរដល់សក្ការៈទាំងពួង អធិប្បាយថា ជនទាំងឡាយចូរចូលទៅតាំងសេចក្តីគោរពកោតក្រែងក្នុងព្រះរតនត្រៃចុះ ។*

ចប់អដ្ឋកថា អនុកម្បកសូត្រទី ៥

# អដ្ឋកថា យថាភតអវណ្ណសូត្រទី ៦

*(ធ្លាក់នរកព្រោះសរសើរបុគ្គលគួរតិះដៀល)*

[១៣៦] *ក្នុងសូត្រទី ៦ ងាយយល់ទាំងអស់ហើយ ។*

ចប់អដ្ឋកថា យថាភតអវណ្ណសូត្រទី ៦

# អដ្ឋកថា យថាភតគេជសូត្រទី ៧

*(ធ្លាក់នរកព្រោះហួងហែងអាវាស)*

*គប្បីជ្រាបវិនិច្ឆ័យក្នុង យថាភតគេជសូត្រទី ៧ ដូចតទៅនេះ ៖*

*[១៣៧] បទថា **អាវាសបលិគេធី** (ហួងហែងអាវាស) បានដល់ តាំងនៅហាក់ដូចជាទំពារស៊ីអាវាស ដោយអំណាចនៃសេចក្ដីជាប់ជំពាក់ យ៉ាងខ្លាំង ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់នោះឯង ។*

ចប់អដ្ឋកថា យថាភតគេជសូត្រទី ៧

# អដ្ឋកថា បឋមយថាភតមច្ឆេរសូត្រទី ៨

*(ធ្លាក់នរកព្រោះសេចក្តីកំណាញ់)*

[១៣៨] *ក្នុងសូត្រទី ៨ ងាយយល់ទាំងអស់ហើយ ។*

ចប់អដ្ឋកថា បឋមយថាភតមច្ឆេរសូត្រទី ៨

# អដ្ឋកថា ទុតិយយថាភតមច្ឆេរសូត្រទី ៩

*(ធ្លាក់នរកព្រោះសេចក្តីកំណាញ់)*

[១៣៩] *ក្នុងសូត្រទី ៩ ងាយយល់ទាំងអស់ហើយ ។*

ចប់អដ្ឋកថា ទុតិយយថាភតមច្ឆេរសូត្រទី ៩

# អដ្ឋកថា តតិយយថាភតមច្ឆេរសូត្រទី ១០

*(ធ្លាក់នរកព្រោះសេចក្តីកំណាញ់)*

[១៤០] *ក្នុងសូត្រទី ១០ ងាយយល់ទាំងអស់ហើយ ។*

ចប់អដ្ឋកថា តតិយយថាភតមច្ឆេរសូត្រទី ១០

## ចប់អាវាសិកវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៦ សូត្រ

# ទុច្ចរិតវគ្គវណ្ណនាទី ៥

## អដ្ឋកថា ទុច្ចរិតសូត្រទី ១-៥

*(ទោសរបស់ទុច្ចរិត)*

*គប្បីជ្រាបវិនិច្ឆ័យក្នុងទុច្ចរិតសូត្រទី ១ ដល់ទី ៥ ដូចតទៅនេះ ៖*

[១៤១-១៤៥] *បទថា* ***ទុច្ចរិតេ*** *(បុគ្គលប្រព្រឹត្តអាក្រក់) នេះ ទ្រង់មិនបានត្រាស់ចែកប្រភេទទេ ។ បទជាដើមថា* ***កាយទុច្ចរិតេ*** *(កាយទុច្ចរិត) ទ្រង់ត្រាស់ចែកប្រភេទ មានកាយទ្វារជាដើម ។ បទថា* ***សទ្ធម្មា*** *(ឃ្លាតចាកព្រះសទ្ធម្ម) បានដល់ ឃ្លាតចាកធម៌ គឺ កុសលកម្មបថ ១០ ។ បទថា* ***អសទ្ធម្មេ*** *(ក្នុងអសទ្ធម្ម) បានដល់ ក្នុងអសទ្ធម្ម គឺ អកុសលកម្មបថ ។*

ចប់អដ្ឋកថា ទុច្ចរិតសូត្រទី ១-៥

# អដ្ឋកថា អបរកាយទុច្ចរិតសូត្រទី ៦

*(ទោសរបស់កាយទុច្ចរិត)*

[១៤៦] *ក្នុងសូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា អបរកាយទុច្ចរិតសូត្រទី ៦

# អដ្ឋកថា អបរវចីទុច្ចរិតសូត្រទី ៧

*(ទោសរបស់វចីទុច្ចរិត)*

[១៤៧] ក្នុងសូត្រនេះ មានសេចក្តីងាយហើយ ។

ចប់អដ្ឋកថា អបរវចីទុច្ចរិតសូត្រទី ៦

# អដ្ឋកថា អបរមនោទុច្ចរិតសូត្រទី ៨

*(ទោសរបស់មនោទុច្ចរិត)*

[១៤៨] *ក្នុងសូត្រនេះ មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា អបរមនោទុច្ចរិតសូត្រទី ៨

# អដ្ឋកថា សីវថិកសូត្រទី ៩

(ទោសរបស់ព្រៃខ្មោច)

គប្បីជ្រាបវិនិច្ឆ័យក្នុង សីវថិកសូត្រទី ៩ ដូចតទៅនេះ ៖

[១៤៩] បទថា **សីវថិកាយ** (ព្រៃខ្មោច) គឺ ព្រៃស្មសាន ។ បទថា **អាភេទនា** (ជាទីទ្រហោយំ) គឺ ជាស្ថានទីទ្រហោយំ ។ បទថា **អសុចិនា** (មិនស្អាត) គឺ គួរឲ្យខ្ពើមរអើម ។

ចប់អដ្ឋកថា សីវថិកសូត្រទី ៩

# អដ្ឋកថា បុគ្គលប្បសាទសូត្រទី ១០

## (ទោសនៃការជ្រះថ្លាក្នុងបុគ្គល)

*គប្បីជ្រាបវិនិច្ឆ័យក្នុង បុគ្គលប្បសាទសូត្រទី ១០ ដូចតទៅនេះ ៖*

*[១៥០] បទថា បុគ្គលប្បសាទេ (ព្រោះសេចក្តីជ្រះថ្លាក្នុងបុគ្គល) បានដល់ ព្រោះសេចក្តីជ្រះថ្លាដែលកើតឡើងក្នុងបុគ្គលតែម្យ៉ាង ។ បទថា អន្តេ និសីទាបេតិ (ត្រូវសង្ឃបង្គាប់ឲ្យអង្គុយក្នុងទីខាងចុងសង្ឃ) បានដល់ ឲ្យលោកអង្គុយលើអាសនៈខាងចុងរបស់ពួកភិក្ខុ ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ។*

ចប់អដ្ឋកថា បុគ្គលប្បសាទសូត្រទី ១០

### ចប់ទុច្ចរិតវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០៧ សូត្រ

# វគ្គសង្គហិតសុត្តន្តៈ

## (ព្រះសូត្រមិនសង្គ្រោះចូលក្នុងវគ្គ)

### អដ្ឋកថា ឧបសម្បទាវគ្គ

[១៥១] *បទថា ឧបសម្បាទេតព្វំ (គប្បីឲ្យកុលបុត្តឧបសម្បទាបាន) បានដល់ គួរជាឧបជ្ឈាយ៍ឲ្យឧបសម្បទាបាន ។*

[១៥២] *បទថា និស្សយោ ទាតព្វោ (គប្បីឲ្យនិស្ស័យបាន) បានដល់ គួរជាអាចារ្យឲ្យនិស្ស័យបាន ។*

[១៥៣] *បទថា សាមណេរោ ឧបដ្ឋាបេតព្វោ (គប្បីឲ្យសាមណេរបម្រើបាន) បានដល់ គួរជាឧបជ្ឈាយ៍ទទួលសាមណេរឧបដ្ឋាកបាន ។ ទាំងបីសូត្រនេះ ត្រាស់សំដៅដល់ព្រះខីណាស្រព ក្នុងបឋមពោធិកាល ដោយប្រការដូច្នេះ ។*

[១៥៤-១៦០] *សូត្រទី ៤ ជាដើម មានអត្ថងាយយល់ហើយ ព្រោះធ្លាប់អធិប្បាយទុកហើយ ។ បទវិនិច្ឆ័យកត្តុទ្ទេសក៍ជាដើម គប្បីជ្រាបដោយន័យដែលពោលទុកហើយក្នុងអដ្ឋកថាព្រះវិន័យ ឈ្មោះសមន្តប្បាសាទិកា ។*

[១៦១] បទថា *សម្មតោបិ ន បេសេតព្វោ (សន្មតហើយ ក៏មិនគប្បីប្រើឲ្យធ្វើការ)* បានដល់ ភិក្ខុបានទទួលសន្មតតាមប្រក្រតី ក៏មិនគួរប្រើទៅដោយពាក្យប្រើថា លោកចូលទៅ ចូរសម្តែងកត្តទាំងឡាយ ។

[១៦២] បទថា *សាដិយគ្គាហាបកោ (អ្នកឲ្យទទួលសំពត់សាដក)* បានដល់ ជានាទីភិក្ខុចែកសំពត់ងូតទឹកភ្លៀង ។ បទថា *បត្តគ្គាហាបកោ (អ្នកប្រើគេឲ្យទទួលបាត្រ)* បានដល់ ភិក្ខុដែលសង្ឃបានសន្មតឲ្យចែកបាត្រដែលលោកពោលទុកក្នុងសិក្ខាបទនេះថា បាត្រណាជាបាត្រចុងក្រោយរបស់ភិក្ខុបរិស័ទនោះ បាត្រនោះគួរប្រគល់ឲ្យដល់ភិក្ខុនោះ ។

[១៦៥] បទថា *អាជីវកោ (អាជីវក)* បានដល់ អ្នកបួសស្រាត ។

[១៦៦] បទថា *និគ្គណ្ឋោ (និគ្រន្ថ)* បានដល់ អ្នកបិទកាយខាងលើ ។ បទថា *មុណ្ឌសាវកោ (សាវកនិគ្រន្ថ)* បានដល់ សាវករបស់និគ្រន្ថ ។ បទថា *ជដិលកោ (ជដិល)* បានដល់ បរិព្វាជកអ្នកស្លៀកសំពត់ ។ សូម្បីអ្នកបួស មានពួកមាគណ្ឌិកៈជាដើម ក៏ចាត់ជាតិរ្ថិយដូចគ្នា ។ ចំណែកល្អទ្រង់មិនបានកាន់យក ព្រោះអ្នកបួសទាំងនោះមិនមានការធ្វើឲ្យបរិបូណ៌ក្នុង

*សីលទាំងឡាយ ។ បទដ៏សេសក្នុងទីគ្រប់កន្លែង ងាយយល់ហើយ ។*

ចប់អដ្ឋកថា វគ្គាសង្គហិតសុត្តន្តៈ

# ចប់អដ្ឋកថា បញ្ចកនិបាត
# នៃអង្គុត្តរនិកាយ ឈ្មោះមនោរថបូរណី

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 USA |
| -ភិក្ខុ ចៅ សៀប វត្តអូស្ត្រាលី | $ 500 AUS |
| -ភិក្ខុធម្មបញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ សហរដ្ឋអាមេរិក ព្រមទាំងពុទ្ធបរិស័ទ | $ 920 USA |
| -ឧបាសកសោម រតនៈព្រមទាំងភរិយា និងបុត្ត | $ 200 USA |
| -ឧបាសក តាំង សុផល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ | កុំព្យូទ័របត់មួយគ្រឿង |